00838760

E1/113.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Aug-2012, 09:50
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី១០១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉េង ហ៊ត់

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក គីម ម៉េងឃី

លោកស្រី បេនី យេ *(Ms. Beini YE )*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក គឹម វុន (TCW-338) | ខ្មែរ |
| លោក អែម អឿន (TCCP-28) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក គឹម ទុន ហៅ ឆោម** (TCW-338)

សួរដោយលោក សុន អរុណ ផ្តើមពី៖........................................ទំព័រ ៣

សួរដោយលោក ហ្សាស្តេ ប៉ៅ ផ្តើមពី៖........................................ទំព័រ២៦

សួរដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖........................................ទំព័រ៣៣

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក អែម អឿន ហៅ អៀប ឡូន** (TCCP-28)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖........................................ទំព័រ៤០

សួរដោយលោក គឹម ម៉េងឃី ផ្តើមពី៖........................................ទំព័រ៤៤

សួរដោយលោក ពេជ អង្គ ផ្តើមពី៖........................................ទំព័រ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ សវនាការនៅព្រឹកនេះនឹងបន្តដោយការតាំងសំណួរដេញដោលរបស់ក្រុមមេធាវីការពារក្តីចំនួនពីរក្រុម ចំពោះសាក្សី គឹម វុន។ គឺក្រុមមេធាវីការពារក្តីលោក នួន ជា និងក្រុមមេធាវីការពារក្តីលោក អៀង សារី។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ។ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធី ដោយផ្ទាល់ពីបន្ទប់សវនាការ សម្រាប់រយៈពេលពេញ១ថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី ដែលមកផ្តល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មលោក គឹម វុន គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-28។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:០៥:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក អៀង សារី។ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយសូមនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍

សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត កឹម សមសាន្ត គ្រូពេទ្យទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់នៅមន្ទីរឃុំឃាំង អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ។ ហើយបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំងពេលធ្វើចលនាបន្តិចបន្តួច ក្អក អង្គុយយូរឈឺចង្កេះហើមជើងខ្លាំង ពេលអង្គុយ ឬឈរយូរ។ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី បានលះបង់សិទ្ធិ ដែលចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ គាត់មានបញ្ហាសុខភាព ដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយ និងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

[០៩:០៧:១៩]

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេល -- តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:០៨:១១]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ សូមជម្រាបសួរលោក គីម វុន សាក្សី។ ខ្ញុំឈ្មោះ សុន អរុណ ជាក្រុមមេធាវីការពារលោក នួន ជា។ ការសួរដេញដោលចំពោះភាគីទាំងអស់ និងជាមួយលោកសាក្សីបានប្រើពេលយូរមកដែរហើយ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** បន្ទាប់ទៅនេះ ខ្ញុំក្នុងនាមលោក នួន ជា ខ្ញុំសូមសួរដូចតទៅនេះ៖ លោកបានឆ្លើយចំពោះចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារលេខ E3/380 ថា "លោកបានចូលបដិវត្តន៍ទាំងពីឆ្នាំ១៩៧១" ហើយលោក -- ហើយចៅក្រមបានសួរតទៅទៀតថា "ហេតុអ្វីបានជាលោកចូលបដិវត្តន៍?"។ ក្នុងសំណួរទាំងអស់នេះ ខ្ញុំសូមសួរលោកថា -- លោកបានឆ្លើយបន្តទៅទៀត សូមទោស បានឆ្លើយថា "ឪពុកខ្ញុំជាមន្ត្រីខ្មែរឥស្សរៈខាងសម្តេច សីហនុ"។ ត្រង់ឃ្លានេះ លោក -- តើលោកមានចង់និយាយពន្យល់ទៅចៅក្រមថាម៉េច? ព្រោះអីខ្ញុំអានក្នុងឯកសារនេះ ដូចជា -- ហាក់ដូចជាមិនសូវយល់ត្រង់ពាក្យថា "ឪពុកខ្ញុំជាមន្ត្រីខ្មែរឥស្សរៈខាងសម្តេច សីហនុ កាលសម័យនោះ"។

[០៩:១០:០៣]

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំយល់ថាចលនាតស៊ូវើបារាំងជំនាន់នោះ តាមខ្ញុំបានរៀនសូត្រខ្លះ ហើយនិងតាមចាស់ៗនិយាយតៗគ្នា ឥស្សរៈមិនមានតែមួយក្រុមទេ គឺមានក្រុមសម្តេចឪ ហើយនិងក្រុមខ្មែរយៀកមិញ។ អ៊ីចឹងបានខ្ញុំចែកឥស្សរៈដាច់ថា ក្រុមរបស់ឪពុកខ្ញុំគឺមួយពូជពង្សខ្ញុំ គឺនិយាយរួមទៅគឺខាងសម្តេចសីហនុ។ ដូច្នេះមិនមែនជាក្រុមខាងយៀកមិញទេ។

**ស៖** អរគុណ។ សំណួរទី២ របស់ខ្ញុំសួរថា នៅរយៈពេលឆ្នាំ១៩៧០ ពេលនោះលោកសាក្សីមានអាយុ ១២ឆ្នាំ។ គេបានចាត់តាំងឲ្យលោកធ្វើជាអនុប្រធានក្រុម១០ខ្ទង់ តើលោករស់នៅក្រោមរបប -- ពេលនោះ តើលោករស់នៅក្រោមរបប លន់ នល់ ឬក៏អ្នកតស៊ូខាងឥស្សរៈអីអ៊ីចឹងទៅ?

[០៩:១១:៤៩]

**ឆ៖** សម័យនោះ សូម្បីតែអ្នកម្ចាស់សំណួរក៏អាចដឹង ប៉ុន្តែខ្ញុំសូមឆ្លើយថានៅសម័យគឺក្នុងរបប លន់ នល់។ ក្រោយពីរដ្ឋប្រហារហើយគឺនៅទូទាំងប្រទេសកម្ពុជាគ្រប់គ្រងដោយរដ្ឋអំណាចរបស់រដ្ឋប្រហារ។ ដូច្នេះយុវជនក៏ដោយ កុមារក៏ដោយ ឲ្យតែខ្សែ មានអ្នករាជការចាស់គឺគេត្រូវយកចូលឲ្យធ្វើការទាំងអស់។ ហើយខ្ញុំវាមិនដឹងដែរ អាយុវាមិនទាន់គ្រប់ការផង ហេតុអីក៏គេយកខ្ញុំទៅធ្វើអ៊ីចឹង? ខ្ញុំក៏យល់ដែរគ្រាន់តែជំនួយទេ ព្រោះខ្ញុំអ្នកចេះសរសេរអក្សរអីខ្លះអ៊ីចឹង រៀនចេះដឹងទៅ ដូច្នេះគ្រាន់តែជំនួយហ្នឹង ជំនួយគ្រាន់តែគេប្រើគ្មានប្រាក់ខែអីទេ។ ហើយដូចបងខ្ញុំជាស្មៀនឃុំអង្គាល់នុំងក៏អ៊ីចឹងដែរ ពីមុន

បម្រើសម្ដេចដែរ ដូចបងហេង អី, បងយ៉ែនអី ដល់អ៊ីចឹងទៅអ្នកទាំងអស់នោះត្រូវធ្វើការឲ្យ លន់ នល់ ទាំងអស់។ អ៊ីចឹងបានកាលសម័យនោះ ខ្ញុំឃើញថាបើតាមច្បាប់ត្រូវអាយុ ១៨ឆ្នាំបានគេត្រូវធ្វើការ ប៉ុន្តែ សម័យនោះក្មេងមួយហេតុអីក៏គេយកទៅធ្វើការដែរ គឺគេគ្រាន់តែប្រើទេ មែនទែននោះ វាគ្មានមុខងារអី ទេ។ ហើយម៉្យាង ខ្ញុំចាត់ទុកថាហាក់ដូចជាខ្សែអ្នករាជការចាស់ គេចេះតែប្រើទៅ។ ហើយបើគ្រូ បង្រៀនឡើងដល់ស័ក្ដិបី ស័ក្ដិបួន គឺត្រូវដំឡើងអ៊ីចឹងតែម្ដង។ អ៊ីចឹងហើយបានវាបង្កើតទំនាស់នៅក្នុង សង្គមនាពេលនោះ។ ដល់ពេលទម្លាក់សម្ដេចអ៊ីចឹងទៅដល់របណសិរ្សរួបរួមជាតិកម្ពុជាកាន់កាប់តំបន់ រំដោះអ៊ីចឹងទៅ តំបន់ហ្នឹងវាទៅជាតំបន់មួយដែលមានទំនាស់។

[០៩:១៣:៥០]

ខាងយួនហាណូយមក អ្នកមកពីហាណូយមកជាខ្មែរ ក៏ចោទថាពួក លន់ នល់ គ្រាន់តែថា លន់ នល់ ខ្មែរត្រូវស្លាប់ហើយ។ ត្រូវយួនយកទៅបាញ់ចោល ឬពួកភាគខាងជើងយកទៅបាញ់ចោល ឬ ចលនាតស៊ូរបស់សម្ដេច សីហនុ យកទៅបាញ់ចោលបានហើយ។ ដូច្នេះ វារងគ្រោះទាំងអស់ ខ្ញុំឃើញ ថាអត់មានជម្រើសទេ អ្នកណាដែលគេចាត់តាំងគឺត្រូវធ្វើការ ទោះឯង អ្នកឯងក្មេងប៉ុនណាក៏ដោយ។ គឺ ថាយុវជនខ្មែរអត់មានជម្រើស រដ្ឋអំណាចខ្មែរនៅសម័យនោះអត់មានជម្រើសទេ បើយើងមិនធ្វើក៏បញ្ហា បើយើងធ្វើក៏បញ្ហា។ ដូច្នេះបើគ្រាន់គេចោទថាអ្នកឯងជាកម្លាំង លន់ នល់ អ្នកឯងក៏ត្រូវស្លាប់ដូចគ្នាហ្នឹង ខ្លាចអីបងប្អូនចង់បាញ់ចោលមួយគំនរ។ សន ក៏ត្រូវគេបាញ់ចោល, ភិន ក៏ត្រូវគេបាញ់ចោល--

**ស៖** ខ្ញុំសូមកាត់សាក្សី ហើយខ្ញុំមិនសួរដល់ហ្នឹងពេកទេ គ្រាន់ចង់ដឹងថាពេលហ្នឹងលោក សាក្សីនៅក្មេង ហើយលោកធ្វើជាអនុប្រធានក្រុម១០ខ្នង ហើយបើសិនជាអនុប្រធានក្រុម១០ខ្នង ឥឡូវ លោកថាមិនមែនជាអនុប្រធានក្រុម១០ខ្នងទេ គ្រាន់ជាជំនួយការអ៊ីចឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំៗក្បាលមីក្រូប្រតិបត្តិការសិន សាក្សី!

**លោក គីម វុន៖**

**ឆ៖** ខ្ញុំឲ្យន័យថា តាមខ្ញុំយល់ក្នុងពេលនោះ គឺថាខ្ញុំយល់ថាជាជំនួយជាអីទេ ខ្ញុំយល់ថា បើគេ ប្រើអ៊ីចឹង ខ្ញុំមានសិទ្ធិជាអនុក្រុមហើយ។ ដូច្នេះ បានជាខ្ញុំប្រាប់ទៅ -- ដូច្នេះ ខ្ញុំនិយាយក្នុងកាលៈទេសៈ នោះ នៃការយល់របស់ខ្ញុំ។ ព្រោះការរៀនសូត្ររបស់ខ្ញុំ កាលទេសៈនោះ ខ្ញុំមិនចេះច្បាប់រដ្ឋបាលណា

ប៉ុន្តែបើខ្ញុំចូលក្នុងជួរមក ខ្ញុំដឹងខ្លះ។ ហើយសម័យនេះ ខ្ញុំក៏វិភាគ ខ្ញុំដឹងថាអ៊ីចឹង ប៉ុន្តែសម័យនោះ ខ្ញុំឃើញថា សិទ្ធិអ៊ីចឹងដែរ។

[០៩:១៥:៥៧]

ហើយមួយទៀត បានខ្ញុំចេះតែយល់ច្រឡំនឹងអាយុហ្នឹង ដោយសារសូម្បីតែចៅហ្វាយស្រុក ង៉ិន សារឿង អង្កាល់នោះ ក៏ហៅខ្ញុំទៅដែរបាទ។ ហើយបើគិតពីរដ្ឋបាលនៅសម័យនេះ គឺវាខុសហើយ ព្រោះវាមិនត្រូវទេ អាយុបួនប្រាំដណ្តប់ក្តី ពីរដណ្តប់ក្តី វាមិនត្រូវទេ។ ហើយខ្ញុំនិយាយពីដំណាក់កាលបដិវត្តន៍មកវិញ ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា។ ក្រុមកុមារ គឺជាអង្គភាពអ៊ីចឹងតែម្តង គឺមានចាត់តាំងជាអង្គការកុមារស្នេហាជាតិ យុវជន យុវនារីស្នេហាជាតិ កសិករស្នេហាជាតិ។ គឺមានគ្រប់របស់គេទាំងអស់ មានជាសមាគម មានចងក្រងអ៊ីចឹង។ អត់នៅរាត់រាយ ដូចនៅក្នុងសង្គមចាស់ទេ។ អ៊ីចឹង បានជា ដូចខ្ញុំបានលើកជម្រាបពីខាងដើមហើយ ថាសូម្បីតែក្មួយខ្ញុំដែលអាយុមិនទាន់គ្រប់ផង គេចូលបដិវត្តន៍មុនខ្ញុំទៀតហើយ អាអាន។ នេះ សូមពន្យល់ប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ នៅឆ្នាំ១៩៧១ ពេលទ័ពវៀតណាមខាងជើងចូលមកដល់ខេត្តក្រចេះ រតនគិរី មណ្ឌលគិរី ហើយដែលមានសម្តេច សីហនុ ប្រកាសឲ្យប្រជាជនខ្មែរចូលរណសិរ្សព្រៃម៉ាគី។ ពេលនោះ លោកសាក្សីបានសម្រេចចូលទៅនៅថ្នាក់មជ្ឈិមការជ្រើសរើសរបស់លោក គឺនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧១ ដោយសារលោកស្គាល់បុរសម្នាក់ឈ្មោះ វង។ អ៊ីចឹងពិតមែនទេ លោកស្គាល់ -- ពេលហ្នឹង លោកស្គាល់មនុស្សម្នាក់ឈ្មោះ វង?

**ឆ៖** បាទ ពិតប្រាកដ។

[០៩:១៨:១០]

**ស៖** លោក វង ហ្នឹង ជាកម្មាភិបាលមកពីវៀតណាមខាងជើង។ ខ្ញុំសួរថា វង ហ្នឹង ជានរណា? ជាខ្មែរ ឬក៏ជាវៀតណាម? ឬក៏យោធា ឬក៏ជាជនស៊ីវិលធម្មតា? ឬក៏ជាកម្មាភិបាលរបស់ខ្មែរ ឬក៏កម្មាភិបាលរបស់វៀតណាម ដែលមកដឹកនាំលោកឲ្យចូលក្នុងរណសិរ្ស? សូមអរគុណ។

**ឆ៖** ដូចខ្ញុំបាននិយាយចម្លើយរបស់ខ្ញុំពីកាលមុន ក៏ខ្ញុំបានបញ្ជាក់អំពីការចូលបដិវត្តន៍ដែរ។ មែនទែន ក្រោយរដ្ឋប្រហារ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺថាតំបន់ដែលរំដោះហើយ គេមិនទុកឲ្យទំនេរទេ គឺមានការចាត់តាំង តាំងពីកុមារឡើងទៅ។ កុមារ ធ្វើសកម្មភាពអីខ្លះ? សូម្បីតែចម្រៀង សុទ្ធចម្រៀងបដិវត្តន៍ អត់មានច្រៀងចម្រៀង លន់ នល់ អត់មានច្រៀងចម្រៀងសង្គមរាស្ត្រនិយមសង្គមពីមុនទេ។

ដូច្នេះហើយកម្មាភិបាល គឺដូចខ្ញុំនិយាយ គឺមាននៅក្នុងស្រុក និងក្រៅស្រុក។ អ្នកមកពីក្រៅស្រុក គឺមកពី -- ភាគីច្រើន គឺមកពីយួនខាងជើង គឺមកពីហាណូយតែម្តង។ ខ្ញុំសួរបងៗទៅ គាត់ថា គាត់ទៅតាំងពីអាយុ អ្នកខ្លះជាង១០ឆ្នាំ អ្នកខ្លះបួនប្រាំដណ្តប់ឆ្នាំ អ្នកខ្លះ២០ឆ្នាំ។ ដូច្នេះ គាត់ តាំងពីឆ្នាំ១៩៥៣, ៥២ អីហ្នឹង កាលហ្នឹងយួរគេយកទៅអ៊ីចឹង ហើយខ្សែហ្នឹង គឺខ្សែ គេហៅខ្សែខ្មែរយៀកមិញហ្នឹងតែម្តង ហើយគាត់មិនដែលលាក់លៀមទេ។ បើសួរឆ្លល់អីស្រុកយួន យ៉ាងម៉េចៗ ចរិតយួន ទាំងខ្មែរ ទាំងអីនៅស្រុកយួនដែលនោះ គឺ -- ព្រោះគាត់នៅខាងជើងមិនមែនសេរីឯណា គាត់ទៅរៀនពីកុម្មុយនីស្តមក។ ហើយដល់គាត់ចេញមកវិញ អ៊ីចឹងខ្ញុំដែលចូលនៅពេលនោះដោយសារអី។ ដូចខ្ញុំបាននិយាយខាងដើមលើកមុនថា ឥទ្ធិពលសម្តេចព្រះ នរោត្តម សីហនុ គឺវាលើសលប់ណាស់នៅក្នុងប្រជាជន ហើយដល់មានគេមកអំពាវនាវ ជ្រើសរើសកម្លាំងដើម្បីចូលធ្វើការតស៊ូអ៊ីចឹង សូម្បីតែយើងក្រាញយ៉ាងម៉េចក៏មិនមានពេលក្រាញដែរសម័យនោះ គឺដាក់បញ្ហាយ៉ាងម៉េចគឺត្រូវតែអ៊ីចឹង។

[០៩:២០:៤៧]

ប៉ុន្តែក្នុងថា ការគិតនៅក្នុងពេលនោះ គឺខ្ញុំអត់ទេ ខ្ញុំមានចំណងច្រើនណាស់ដែលចងខ្ញុំអង្កាល់នោះ។ ចំណងអីខ្លះ? ម្តាយតែមួយ កូនមួយ ម៉ែមួយ។ ហើយជាប្រពៃណីរបស់ខ្មែរយើង តែងតែចងភ្ជាប់ថា តាំងពីកើតកូនម៉ាមក គឺភ្ជាប់ពាក្យហើយ ដើម្បីរឹតចំណងជាគូដណ្តឹងអីៗនោះ ហើយម្យ៉ាងទៀតក្នុងវ័យខ្ញុំគឺវ័យរៀនសូត្រ តែងតែមានមិត្តភក្តិច្រើនហើយ ដូច្នេះជាក្មេងណាលះបង់ចូលក្នុងព្រៃទេ។ អ៊ីចឹងកម្មាភិបាលគេឃើញសមាសភាពយើងអ៊ីចឹង គេយកចិត្តទុកដាក់ណាស់ ព្រោះក្មេងកំព្រារ គឺថាមនុស្សបែបហ្នឹង គឺអាចលះបង់ ហើយដាច់ណាត់ជាងគេដែរ ហើយក៏អាចធ្វើគំរូគេដែរ ហើយដោយក្នុងត្រកូលខ្ញុំភាគច្រើនជាអ្នក កាន់អំណាចចាស់នៅសម័យនោះដែរ។ ជាត្រកូលគឺវាគ្របដណ្តប់ហើយមានឥទ្ធិពលដែរ ហើយនិយាយជាការស្រលាញ់ថ្នាក់ថ្នម ពីអ្នកស្រុកក៏ឃើញថា មាន។ ដូច្នេះ គេសំដៅថា មានឥទ្ធិពលខាងមនោសញ្ចេតអ៊ីចឹងក៏អាចថាបានដែរ។

[០៩:២២:១១]

ដល់អ៊ីចឹងទាំងខាងស្រុក ទាំងខាង បងវ៉ា ដែលគាត់ជាចៅហ្វាយស្រុកសន្ទុក កាលនោះហៅថាគណៈស្រុកនោះ ក៏អូសទាញខ្ញុំដែរ ហើយខាង បងវង មកភាគខាងជើងក៏អូសទាញខ្ញុំដែរ ហើយគាត់ជាកម្មាភិបាលមជ្ឈិម ហើយគាត់ជាខ្មែរ ខ្មែរមកពីភាគខាងជើង។ ដូច្នេះខ្ញុំមិនងាយសម្រេចចិត្តថា ជ្រើសរើសទេ ព្រោះនៅក្នុងភូមិដូចខ្ញុំបាននិយាយអ៊ីចឹងទាំងកុមារ ទាំងយុវជន គឺមានចាត់តាំង មានការប្រជុំ

ជីវភាព មានចលនាច្រៀងរាំ សប្បាយរីករាយណាស់ ហើយបើយើងចូលទៅព្រៃវាពិបាកនឹងលះបង់នៅនេះ។ ខ្ញុំនៅគិតគូយូរដែរ--

**ស៖** ខ្ញុំសូមកាត់លោកសាក្សី។ ខ្ញុំចង់ដឹងៗគ្រាន់តែឈ្មោះ វង ហ្នឹងជានរណាទេ។ ហើយខ្ញុំសូមសួរបន្តទៅទៀត។ លោក វុន លោកមានដើមកំណើតនៅភូមិ ក្រាំងស្វែង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ប៉ុន្តែដល់ពេលលោកចូលបដិវត្តន៍ លោកចូលដល់ទៅស្ទឹងត្រង់អ៊ីចឹងទេ? ហេតុអីបានជាទៅឆ្ងាយម្ល៉េះ ដោយសារលោក វង ហ្នឹងអី?

**ប្រធានអង្គជំនុំ៖**

លោកៗកុំអាលទាន់ឆ្លើយ! ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការផង ឆ្លើយអំមិញហ្នឹងអត់បានចូលទៅប្រព័ន្ធស្តាប់សំឡេង និងបកប្រែភាសានៅក្នុងនេះទេណា។ ឆ្លើយម្តងទៀត!

[០៩:២៣:៥៧]

**លោក គឹម វុន៖**

**ឆ៖** សំណួរជាការសង្ស័យ។ ខ្ញុំសូមបំភ្លឺបន្តិច។ ធម្មតា ដូនតាខ្ញុំសម័យឥស្សរៈៗ និយាយថាសម័យឥស្សរៈលោកដឹងហើយ មនុស្សតែងតែផ្លាស់ប្តូរទីកន្លែង ហើយមិនមែនធម្មតាទេ វ៉ៃជាមួយបារាំងជាមួយអីហ្នឹង តាមប្រវត្តិដែលឪពុកម្តាយខ្ញុំធ្លាប់និទាន គឺលំបាកខ្លាំងណាស់ ត្រូវលាក់លៀមត្រូវផ្លាស់ឈ្មោះ ត្រូវផ្លាស់ទីកន្លែង ព្រោះនៅក្នុងឥស្សរៈ ដូចខ្ញុំថាអ៊ីចឹងមានអ៊ីចឹង។ ហើយខាងបារាំងនោះមានកម្មង់ដូ មានអីកងជើងក្រហម ជើងលឿង ជើងខ្មៅឯណាទៀត។ ដូច្នេះអ្នកតស៊ូសម័យនោះ ក៏ដូចពីរក្រុមហ្នឹងដូចគ្នា មានការលាក់លៀមដូចគ្នា បើខ្សែណា គឺខ្សែហ្នឹងដដែល។ ដូច្នេះ ដូនតាខ្ញុំអាច -- ខ្ញុំមកដឹងមែនទែននៅកំពង់ធំទេ ដែលខ្ញុំដឹង ព្រោះគាត់និយាយទៅ -- បើនិយាយជីវិតដូនតា គឺនៅខាងកំពង់ស្ពឺច្បាស់ហើយ ប៉ុន្តែដល់យើងមកដឹងក្តី ធំឡើងគឺនៅ -- ដូច្នេះក្នុងរវាងអតីតភាពហ្នឹងវាមានអ៊ីចឹង។

[០៩:២៥:១៣]

**ស៖** អរគុណ។ សំណួរបន្ទាប់ នៅក-២៥ លោកបានជម្រាបតុលាការថា មានបោះពុម្ពទង់បដិវត្ត និងទស្សនាវដ្តីយុវជន យុវនារី ពេលនោះប្រធានក្រុមនិពន្ធឈ្មោះ ឆយ។ ខ្ញុំសួរថា ពេលដែលបោះពុម្ពទង់បដិវត្ត ទង់ទស្សនាវដ្តីយុវជន និងយុវនារី សៀវភៅទស្សនាវដ្តី ឬក៏សៀវភៅទាំងពីរនេះលោកដឹងថាអ្នកណាអ្នកសរសេរទេ? លោកជាអ្នកបោះពុម្ព ប៉ុន្តែលោកបានមានព័ត៌មានថា អ្នកណាអ្នក

សរសេរទង់ទាំងពីរហ្នឹងទេ?

[០៩:២៦:០៧]

**ឆ៖** ពាក់ព័ន្ធនឹងរឿងបោះពុម្ព ខ្ញុំសូមបញ្ជាក់ ថាការងារអស់ទាំងនេះនៅក្នុងសង្គ្រាម៥ឆ្នាំ ខ្ញុំពាក់ព័ន្ធច្រើន តែក្នុងសម័យ៣ឆ្នាំ ខ្ញុំមិននៅពាក់ព័ន្ធច្រើនពីរឿងការបោះពុម្ពនេះទេ ព្រោះខ្ញុំជាអ្នកកាសែត។ ដូច្នេះបែងចែកការងារនេះច្បាស់ណាស់ ទៅខាងថតរូប ទៅខាងកាសែត។ ដូច្នេះការបោះពុម្ពនេះភាគច្រើនខ្ញុំមិនដឹង។

**ស៖** លោកមានន័យថា អ្នកសរសេរដែលខ្ញុំសួរហ្នឹង លោកមិនដឹងថាអ្នកណាសរសេរទេ លោកចង់និយាយអ៊ីចឹង?

**ឆ៖** បាទ អ៊ីចឹងហើយ។

**ស៖** លោកបានបោះពុម្ព ជាអ្នកបោះពុម្ពទង់បដិវត្ត និងទស្សនាវដ្ដីរបស់ -- ទស្សនាវដ្ដីយុវជន និងយុវនារី។ លោកបាន -- មានៗភាគីខ្លះបានសួរលោកទៅហើយ ប៉ុន្តែលោកសួរ ខ្ញុំមិនទាន់ -- ខ្ញុំមានសំណួរកើតឡើងបន្តទៅទៀត។ ពេលដែលលោកបោះពុម្ពហ្នឹង លោកបានអានសៀវភៅមួយចំនួនធំទេ? ខ្ញុំជឿថាអានមិនអស់ទេ ពីព្រោះអីវាមានច្រើនក្បាល លោកបានច្រើនទេ?

[០៩:២៧:៥១]

**ឆ៖** សៀវភៅនេះអាចមានទៅតាមបុគ្គលទេ ដូចខ្ញុំបានជម្រាប។ បើថាយកមកដាក់រួមសម្រាប់ក្រុមនិពន្ធតែម្ដង កម្រយកមកដាក់ណាស់ វាច្រើនតែយកមកផ្សព្វផ្សាយ។ ដូច្នេះខ្ញុំមិនសូវបានអានទេ។ បើចង់អានទស្សនាវដ្ដី ខ្ញុំតែងសុំ បងឆយ។ ដូចជាខ្ញុំចាប់អារម្មណ៍លេខដែលបានដកស្រង់ចម្លើយរបស់លោក កុយ ធួន ហ្នឹងមួយ ហើយមួយទៀតខ្លឹមសារដែលទាក់ទងរឿងដែលប្រពន្ធខ្ញុំបែកគ្នាហ្នឹងមួយ។ ហើយក្រៅពីនោះខ្ញុំមិនសូវបានចាប់អារម្មណ៍ពីរឿងការអានហ្នឹងច្រើនទេ ព្រោះតាមរយៈការប្រជុំផ្សព្វផ្សាយ ឬក៏ដាក់ផែនការ គេលើកទិសឲ្យយើងសរសេររួចជាស្រេច។ ដូច្នេះខ្ញុំអត់សូវមានពេលអានទេ ហើយម្យ៉ាងទៀតការងារយើងសរសេរច្រើនដែរ។ បើចុះទៅមូលដ្ឋាន ត្រូវមកវិញត្រូវនាំគ្នាជុំគ្នា សរុបព័ត៌មាន។ រួចពីហ្នឹងទៀតត្រូវបែងចែក ថាអ្នកណាសរសេរអីខ្លះ។ ដល់អ៊ីចឹងដើម្បីអានទង់បដិវត្ត ហើយម្យ៉ាងក៏មិនជាមុខនាទីយើងត្រូវអានផង ព្រោះធ្វើហ្នឹងគឺសម្រាប់ផ្ទៃក្នុងបក្ស។

[០៩:២៩:២១]

**ស៖** សូមអរគុណលោកសាក្សី។ លោកបានជម្រាបតុលាការថា លោកបានអានខ្លះ។ លោក

មានដែលបានចំណាំមើលថា ទង់បដិវត្តហ្នឹងមានភិនភាគ លក្ខណៈ ទ្រង់ទ្រាយរបស់ទស្សនាវដ្តី និងសៀវភៅហ្នឹងទេ យ៉ាងម៉េច? មានពណ៌យ៉ាងម៉េចពីក្រប? សរសេររបៀបម៉េច? ហើយអក្សរក្នុងសៀវភៅនោះ ជាអក្សរដៃ ឬក៏អក្សរវៃ*ដាក់ទីឡូ*?

**ឆ៖** ដូចខ្ញុំបានឆ្លើយពីថ្ងៃម្សិលមិញជាបន្តបន្ទាប់ គឺនៅពេលសង្គ្រាម៥ឆ្នាំ យើងច្រើនតែសរសេរដៃ។ សរសេរដៃហ្នឹងចែកគ្នាសរសេរ។ ខ្ញុំសរសេរខាងរណសិរ្ស ជុំ សរសេរខាងទង់បដិវត្ត ភួងសរសេរខាងយុវជន យុវនារី។ ដូច្នេះចែកគ្នាដាច់។ ប៉ុន្តែការងារហ្នឹង គឺការងាររួមគ្នាក្នុងរោងពុម្ពតែមួយ។ ប៉ុន្តែអ្នកសរសេរនៅលើ*ស្តង់ស៊ីល*ហ្នឹង គ្រាន់តែចែកគ្នាបីអ៊ីចឹង។

**ស៖** អម្បាញ់មិញលោកបានឆ្លើយថា ពីមុនមកខ្ញុំសួរថា អ្នកណាអ្នកសរសេរទង់បដិវត្ត ហើយនិងទស្សនាវដ្តីយុវជន និងយុវនារី លោកថាលោកអត់ស្គាល់អ្នកសរសេរទេ លោកគ្រាន់ជាបោះពុម្ព។ ដល់ឥឡូវលោកថា ចែកគ្នាសរសេរ។ ចែកគ្នាសរសេរមានគ្នាច្រើន ម្នាក់មុខងារស្អី សរសេរស្អីអ៊ីចឹងទៅ។ ខ្ញុំចង់បញ្ជាក់ថា ពេលដែលយកបោះពុម្ពហ្នឹង សរសេរយកទៅបោះពុម្ពហ្នឹងសរសេរដៃទេ មិនមែនជាៗអក្សរវៃដាក់ទីឡូទេ ទង់បដិវត្ត ហើយនិងទស្សនាវដ្តីយុវជន និងយុវនារីនោះ?

[០៩:៣១:៤៥]

**ឆ៖** ចម្លើយខ្ញុំមានពីរចំណែក។ ពាក្យថា “សរសេរ” មួយមាត់បានន័យថា ឲ្យន័យថាសរសេរនិពន្ធក៏បាន។ ពាក្យថា “សរសេរ” សរសេរលើក្រដាសមិនមែននិពន្ធក៏បាន។ ប៉ុន្តែខ្ញុំប្រាប់អំមិញនេះគឺសរសេរមិនមែននិពន្ធទេ។ សរសេរហ្នឹង គឺសរសេរចម្លងហើយយកទៅបោះពុម្ព ហើយឯម្ចាស់អ្នកសរសេរអត្ថបទហ្នឹង ដូចខ្ញុំបានជម្រាបពីថ្ងៃម្សិលហើយ គឺបើយុវជន យុវនារី គឺលោកស្រី យុន យ៉ាត គាត់ទទួលខុសត្រូវខាងសរសេរហ្នឹងតែម្តង។ ហើយបានមកដល់ភ្នំពេញ យុវជន យុវនារី អាចក្រុមខ្ញុំជាជំនួយគាត់ដែរ ជួយសរសេរជាដំណឹងអីខ្លះ។ ឯទង់បដិវត្តជារឿងកិច្ចការរបស់បក្ស។ ហើយខ្ញុំបាននិយាយពីរឿងចារលើអត្ថបទហ្នឹងទៀត។ នេះចម្លើយខ្ញុំពីម្សិល ខ្ញុំបាននិយាយអស់ហើយ។

**ស៖** រឿងដែលខ្ញុំចង់ដឹងច្បាស់នោះ គឺរឿងដែលលោកយកទង់បដិវត្តទៅបោះពុម្ព លោកឃើញទង់បដិវត្តយកទៅបោះពុម្ពហ្នឹងជាអក្សរសរសេរដៃដោយអ្នកសរសេរស្អាតហើយ ហើយបានយកទៅបោះពុម្ព ឬក៏ថាពេលដែលបោះពុម្ពហ្នឹង ទង់បដិវត្តហ្នឹងវៃដាក់ទីឡូហើយស្រេច? អានេះចំណុចរបស់ខ្ញុំចង់សួរ។

**ឆ៖** អត្ថបទច្បាប់ដើមគឺសុទ្ធតែអក្សរដៃទាំងអស់ វៃអង្គុលីលេខមិនមានទេ គឺប្រើប៊ិក ប្រើស្លាប

ប៉ាកកាសរសេរ។

**ស៖** បើអ៊ីចឹងដល់ពេលយកទៅបោះពុម្ពអក្សរដៃទេ បោះពុម្ពហ្នឹងដើម្បីឲ្យចេញជាទង់បដិវត្ត ហ្នឹង អ៊ីចឹង?

[០៩:៣៤:១២]

**ប្រធានអង្គជំនុំ៖**

សួរម្តងទៀត! ហើយឆ្លើយម្តងទៀតណ៎ះ ឲ្យច្បាស់លាស់! អាចច្រឡំគ្នារវាងឯកសារដែលសរសេរដោយដៃយកទៅហ្វូតូ។ បានន័យថាពេលដែលបោះពុម្ពហ្នឹង គឺយកទៅចេញជារាងអក្សរដៃដដែល។ ពាក្យថា "បោះពុម្ព" មានន័យថា យកឯកសារដើមសរសេរដោយដៃ ធ្វើជាឯកសារមូលដ្ឋាន ហើយរៀបចំអក្សរពុម្ពទៅតាមខ្លឹមសារនៃឯកសារដែលសរសេរដោយដៃហ្នឹង ផលិតចេញជាឯកសារបោះពុម្ព អាហ្នឹងបានគេហៅថាបោះពុម្ព។ ចៀសវាងមានការច្រឡំនៅក្នុងការតាំងសំណួរនេះ។ ទាំងអ្នកសួរ ទាំងអ្នកឆ្លើយគិតឲ្យបានត្រឹមត្រូវហ្មត់ចត់ដើម្បីបញ្ជាក់បញ្ហានេះឲ្យច្បាស់ អាចច្រឡំ ឬអាចបន្លំ។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកចង់ឲ្យខ្ញុំសួរម្តងទៀត ឬក៏ម៉េចបាទ? អរគុណសូមឆ្លើយបាទ។

**លោក គឹម វុន៖**

**ឆ៖** នៅតែបញ្ជាក់ថា ចម្លើយខ្ញុំមានពីរ ហើយពីថ្ងៃម្សិលអាចៗដឹងហើយ ខ្ញុំថាអក្សរដែលអត្ថបទដើម គឺសរសេរដៃទាំងអស់ មិនមែនហ្វូតូដូចលោកប្រធានលើកទេ។ ព្រោះយើងមិនប្រើហ្វូតូកូពីដូចហ្នឹងទេ។ ដូច្នេះ ដែលប្រើហ្នឹងគឺយើងចារលើស្តង់ស៊ីល តែម្តង ហើយតាមធម្មតា ស្តង់ស៊ីល ត្រូវថតជា *អុបសិត* ក៏បាន ប៉ុន្តែយើងអត់ថតទេ ព្រោះយើងមិនមានភ្លើងទេក្នុងព្រៃ។ អក្សរទីប៉ូ ក៏យើងមានដែរ ប៉ុន្តែប្រើវាមិនបានទេ ប្រើតែខាងនិរតី ខាងតាម៉ុកទេ។ ឯខាងរោងពុម្ពខ្ញុំនេះអត់មានទេ។ សូម្បីតែមានអក្សរទីប៉ូហើយក៏មិនប្រើដែរ។ ដូច្នេះ យើងបោះពុម្ពតែសរសរនឹងដៃអ៊ីចឹង លើស្តង់ស៊ីលឡើយ ហើយអត់ថតទៀត។ អត់ៗថតជាអុបសិត ទេ។ សរសេរអ៊ីចឹងហើយគឺ ស្បែកជើងយើងហ្នឹងគឺកាត់វាជាពីរទៅ ហើយកម្មកររោងពុម្ពហ្នឹងអូសទៅ អូសទៅវាចេញអក្សរដូចរ៉ូឡូ យើងអូសអ៊ីចឹងដែរ។ ដល់វាច្បាស់ជាអក្សរមកដាក់ពីរស្បែកជើងទៅវាបានមួយទំព័រហើយ។ ហើយយកអាហ្នឹងទៅប៉ុន្មានរយទំព័រ យកមកចងក្រងជាសៀវភៅ កិបទៅ។ រណសិរ្សគឺធ្វើនឹងក្រដាសសៀវភៅលាយើងនៅយក -- នៅខេត្តក្រចេះហ្នឹងប្រើអាហ្នឹង។

[០៩:៣៦:៥៤]

ឯទស្សនាវដ្ដីទង់បដិវត្ត គឺប្រើក្រដាស។ ក្រដាសស្អាតដែរសម័យសង្គមនិយមមានក្រដាសសម្រាប់បោះពុម្ពកាសែត បោះពុម្ពអីហ្នឹង ស្អាតដែរ។ និយាយរួមក្រដាសរ៉ាមយើងហ្នឹងដែរហ្នឹង ប៉ុន្តែបើអត់មានក្រដាសរ៉ាមទេ មានតែក្រដាសធំយកមកកាត់ធ្វើដូចរ៉ាមដែរ ហើយបោះពុម្ពអ៊ីចឹងទៅ។ បោះពុម្ពនិងមានពីរប្រភេទដែរ ដែលសរសេរចារលើស្ដង់ស៊ីល ហើយយើងអាចយកមកអូសនឹងស្បែកជើងហ្នឹង បើស្ដង់ស៊ីល ចិនគឺវាប្ដូនទំព័រធំៗតែម្ដង។ សរសេរទៅវាចេញជាអក្សរអ៊ីចឹង យកមកឲ្យយើងមើលទៅត្រូវលុបត្រូវអី មានអាទឹកសម្រាប់លុបកន្លែងខុសទៅ។ ខ្ញុំពន្យល់ប៉ុណ្ណឹងយល់ ឬយ៉ាងម៉េច? បើមិនយល់ខ្ញុំពន្យល់ម្ដងទៀត ព្រោះអាហ្នឹងជារឿងបច្ចេកទេសទេ។ មិនមែនរឿងនយោបាយអីឲ្យពិបាកអត់យល់ទេ បើនាក់ដឹងពីរឿងបោះពុម្ព ដឹងតែម្ដង។ ពិសេសបច្ចេកវិទ្យាថ្មីហ្នឹងគឺងាយយល់។

[០៩:៣៧:៥៦]

**ប្រធានអង្គជំនុំ៖**

ដើម្បីបញ្ជាពីបញ្ហានេះច្បាស់ សូមព្រះរាជអាជ្ញា -- លោកមេធាវីគប្បីញែកឲ្យច្បាស់រវាងដំណាក់កាលពីរ។ ដំណាក់កាលតស៊ូ មុន ៧៥ -- មុន ១៧ មេសា ៧៥ ហើយនិងអំឡុង ៧៥-៧៩។ អាហ្នឹងអាចមានលក្ខខណ្ឌខុសគ្នា។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សី លោកបានចូលធ្វើបដិវត្តធ្វើការតាំងពីលោកអាយុ ១២ឆ្នាំ ហើយនៅឆ្នាំ១៩៧១ ខ្ញុំខុសឬត្រូវ? ខ្ញុំបញ្ជាក់ម្ដងទៀត។

**លោក គីម វុន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ពេលនោះ ការតស៊ូបដិវត្តន៍របស់ ហ្វុង មានន័យ -- លោកបានជម្រាបតុលាការថា លោកមានទស្សនៈ សីហានុនិយម តាំងពីហ្នឹងមក តាំងពីបងប្អូនគ្រួសារអីទាំងអស់។ ពេលនុ៎ង ហ្វុងជាមួយនឹងរណសិរ្សបក្សកុម្មុយនីស្ដកម្ពុជាហ្នឹងបានធ្វើការរួមគ្នាហើយ ដោយ លន់ នល់ ទម្លាក់សម្ដេច សីហនុ។ ពេលនុ៎ង លោកបានបញ្ជាក់អំមិញថា សរសេរនៅលើស្ដង់ស៊ីល ហើយយកទៅអូសអ៊ីចឹងឬ? ខ្ញុំនិយាយហ្នឹងត្រូវឬខុស?

[០៩:៣៨:២១]

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** លុះដល់មកដល់នេះ លោកឃើញសៀវភៅទង់បដិវត្ត ឥឡូវនេះដែលព្រះរាជអាជ្ញាហុចជូនលោកអាន -- មើលហ្នឹង តើជាទង់បដិវត្តសរសេរអក្សរពុម្ព ដោយវ៉ៃដាក់ទីឡូ វ៉ៃកុំព្យូទ័រ ឬក៏សរសេរដៃ?

**ឆ៖** ឯកសារនេះ ជាឯកសារពិតប្រាកដ ហើយអក្សរនេះជាអក្សរ ទីប៉ូ គឺមិនមែនជាសរសេរខ្ញុំសរសេរស្តង់ស៊ីល ឬវ៉ៃ ដាក់ទីឡូ ទេ។ អក្សរនេះ គឺអក្សរពុម្ពច្បាស់ធ្វើនៅកន្លែង ស៊ិន ហេង។

**ស៖** បើអ៊ីចឹងមានន័យថា បន្ទាប់ពីលោកសរសេរដៃទាញស្ទង់ស៊ីល ហើយ បានយកទៅ -- ខ្ញុំអត់ចេះទេបច្ចេកទេសរឿងវ៉ៃ ដាក់ទីឡូ ស្អីអស់ហ្នឹង។ ប៉ុន្តែគ្រាន់ថា យកទៅវ៉ៃអី ទីប៉ូ ដូចលោកមាននិយាយអ៊ីចឹងតទៅទៀត បានចេញជាអក្សរពុម្ពអ៊ីចឹងមក ឬយ៉ាងម៉េច? អាហ្នឹងចូលក្នុងបច្ចេកទេសបន្តិចប៉ុន្តែខ្ញុំដូចជា ខ្ញុំអត់ចេះ ហើយខ្ញុំសូមឲ្យលោកពន្យល់?

**ឆ៖** ក្នុងសម័យនោះ ខ្ញុំចង់និយាយថា ទីប៉ូ។ អក្សរដែលគេយកសំណហ្នឹងទៅចាក់ពុម្ពធ្វើជាអក្សរ ដោយមានតាមហ្វុងវាទៅ វាមានខ្នាតប៉ុន្មានៗអ៊ីចឹង។ ហើយក្នុង ទីប៉ូ ហ្នឹងគឺមានកម្មករចាប់អក្សរអ៊ីចឹងទៅ។ កាសែតអីធ្វើពេលនោះ គឺអ៊ីចឹង។ តាំងពីជំនាន់សង្គមរាស្ត្រនិយមមក។ បងខ្ញុំគាត់ធ្វើការនៅរោងពុម្ពសង្គមរាស្ត្រនិយមដែរ។ ហើយខ្ញុំតែងតែចូល ហើយមកជំនាន់៣ឆ្នាំ ក៏ខ្ញុំដឹង ឃើញ។ បោះពុម្ពអ៊ីចឹងហើយបានយកទៅរៀប។ មានថែកដូចយើងកុំព្យូទ័រអ៊ីចឹងដែរ មានប្លុកគេអ៊ីចឹងដែរ។ ដល់អ៊ីចឹងមួយកន្លែងហ្នឹងដាក់ប៉ុន្មានអក្សរទៅ។ បើយើងអស់អាកន្លែង ឧបមាអស់ស្រះអីមួយ យើងថែមស្រះហ្នឹងទៅ។ ស្រះ "ា" អស់ "ក" ដាក់បញ្ចូលថែមហ្នឹងវិញ។ ចាប់អាហ្នឹងហើយ បានយើងយកអក្សរពុម្ពដែលចាំហើយ យកមក យករ៉ូឡូហ្នឹងមកនេះពីលើ មិនមែនដូចអូសស្តង់ស៊ីល ទេ។ ព្រោះបច្ចេកទេស វាទំនើបមកហើយ។ ហើយតាមពិតនៅក្នុងសង្គ្រាមភូមិភាគនិរតីហ្នឹង គឺគេធ្វើរួចជាស្រេចហើយ។ ប៉ុន្តែខាងផ្នែករោងពុម្ពខ្ញុំហ្នឹង អត់ធ្វើអ៊ីចឹងទេ។ ព្រោះអត់មានលទ្ធភាព ព្រោះយើងក្រទឹកខ្មៅយើងអត់មានធ្វើដូចអ៊ីចឹងទេ។

[០៩:៤២:៣៣]

ប៉ុន្តែនៅភ្នំពេញនេះ ដែលបោះពុម្ពសៀវភៅនេះ គឺបោះទីប៉ូហ្នឹងតែម្តង។ ហើយអានេះបោះអុបសិតមិនមែនបោះទីប៉ូទេ។ ក្របវាគឺបោះដោយឡែក នៅ ស៊ិន ហេង ហ្នឹងបោះអុបសិតម្តង។ អុបសិតបានន័យថា យើងថតចម្លងដូច*ហ្វូតូស្តេ្យ*ដែរ ប៉ុន្តែយើងប្រើស្លាកដែកស័ង្កសីភាពធំ។ បើយើងចង់បានប៉ុន្មាន

ទំព័រ បើម៉ាស៊ីនរ៉ូឡង់ គឺបោះផែនទីទាំងមូលបាន បោះធំបាន។ ទៅម្តងអ៊ីចឹង វាចេញជាពណ៌អ៊ីចឹងទៅ។

**ស៖** ខ្ញុំសូមកាត់លោក។ អាហ្នឹងចូលស៊ីជម្រៅបច្ចេកទេស ខ្ញុំចង់ដឹងតែប៉ុណ្ណឹង។ អាហ្នឹងខ្ញុំអរគុណណាស់។ ខ្ញុំសួរតទៅទៀត។ ពេលដែលលោក វុន បានឃើញទស្សនាវដ្តី បានអានខ្លះៗទស្សនាវដ្តីជាអក្សរ សរសេរអក្សរដៃ ឬលោកឃើញបោះពុម្ពអ៊ីចឹងហើយ?

[០៩:៤៣:៤៣]

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ។ ខ្ញុំនៅតែអះអាងថា ការងាររបស់ខ្ញុំនៅឆ្នាំ១៩៧៥ គឺបានបែងចែកទៅខាងផ្នែកថតរូប និងកាសែតរួចជាស្រេចហើយ។ ឯការងារជុំវិញជួយទស្សនាវដ្តីផ្សេងៗនេះ គឺខ្ញុំគ្រាន់តែមានចំណងជើង តែខាងរូបភាព ឬស្អីដែលជាចំណងជើង ឬក៏ធ្វើជា *ហ្វ៊ីស្ស៊េ* ឬក៏ធ្វើជាអុបសិត។ ព្រោះនៅសម័យនោះ ថ្នាក់ដឹកនាំចូលចិត្តអក្សរខ្ញុំ យកទៅធ្វើចំណងជើងច្រើន ព្រោះវាអាចស្អាតដែរដូចទស្សនាវដ្តីកម្ពុជាអីៗ។ ដល់ បងចក់ ធ្វើមុនមិនសូវស្អាតអ៊ីចឹង។ ខ្ញុំមានគំនិតមួយថា ត្រូវកែឱ្យត្រូវលំនាំអក្សរពុម្ព ប៉ុន្តែមិនដូចពុម្ពទាំងអស់នេះ ប៉ុន្តែគ្រាន់តែធ្វើឱ្យស្អាត។ ហើយការអាននៅពេលនោះដូចខ្ញុំបែង -- បានលើកពីខាងដើម ខ្ញុំមិនសូវបានអានទេ។ ព្រោះការងារខ្ញុំ មិននៅបោះពុម្ពទស្សនាវដ្តីហ្នឹងទៀតទេ។

**ស៖** សំណួររបស់ខ្ញុំ គឺគ្រាន់ចង់ដឹងថា លោកអានពេលនោះ លោកបានអានជាអក្សរដៃដែលមិនទាន់យកទៅធ្វើ ដូចពុម្ពឥឡូវហ្នឹងអ៊ីចឹង ដូចឯកសារមួយដែលព្រះរាជអាជ្ញាបានដាក់ជូនលោករួចអ៊ីចឹង បានអានជាអក្សរដៃ ឬបានអានជាអក្សរអ៊ីចឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[០៩:៤៥:០០]

**ប្រធានអង្គជំនុំ៖**

លោកនិយាយតាមក្បាលមីក្រូ! និយាយទទេអ៊ីចឹង។ ចាំក្បាលមីក្រូប្រតិបត្តិការសិនណ៎ះ!

**លោក គឹម វុន៖**

**ឆ៖** ឯកសារហ្នឹង ខ្ញុំបានអានជាទស្សនាវដ្តីដែលគេបោះរួចហើយ ព្រោះការងារក្នុងសម័យហ្នឹងមិនជាប់ពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយអីទៀតទេ។ ព្រោះការងារខ្ញុំទៅខាងកាសែត គឺខាងទស្សនាវដ្តីប៉ុន្តែសំខាន់គឺខាងកាសែត ដូច្នេះបែងចែកការងារហ្នឹងច្បាស់ហើយ។

**លោក សុន អរុណ៖**

**ស៖** ខ្ញុំនៅតែមិនច្បាស់ មុនដំបូងលោកពន្យល់ថា ទស្សនាវដ្ដីទង់បដិវត្ត ហ្នឹងគឺចែកគ្នាសរសេរក្នុងចំណោមមនុស្សមួយចំណោមធំហ្នឹង ហើយបើចែកគ្នាសរសេរ ចែកគ្នាចម្លង ហើយអ៊ីចឹងលោកប្រហែលជាបានឃើញអាដើមហ្នឹង សរសេរអក្សរដៃហ្នឹងនោះ ព្រោះអីចែកគ្នាសរសេរ លោក ហើយយ៉ាងហោចណាស់ក៏លោកបានមួយចំណែកនៃៗអត្ថបទដែលលោកបានសរសេរដែរ?

[០៩:៤៦:២៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ការតាំងសំណួរអាចច្រឡំ អ៊ីចឹងបានយើងជម្រាបលោកថា ចូរលោកគិតអំពីកាលវេលាដែលមានការវិវត្តដំណាក់កាលនៅក្នុងសម័យតស៊ូរណសិរ្សរួបរួមជាតិកម្ពុជាអំឡុង៧០ រហូតដល់ថ្ងៃរំដោះ៧៥ ហើយនិងដំណាក់កាលទី២ គឺក្រោយរំដោះ១៧ មេសា ឆ្នាំ៧៥ រហូតដល់ ៧៩។ ការវិវត្តខាងផ្នែកបច្ចេកទេសខុសគ្នា ដើម្បីសួរហ្នឹងឱ្យបានច្បាស់លាស់។ អ៊ីចឹងដែលគាត់ឆ្លើយមក លោកអាចយកមកបូកចូលគ្នាគឺសួរសំណួរហ្នឹង គឺអាចទាំងលោក ទាំងសាក្សីហ្នឹងគឺអាចវិលវល់នៅតែច្រឡំបល់គ្នាអ៊ីចឹង។ បើសិនជាលោកញែកឱ្យបានច្បាស់លាស់ រវាងពីរដំណាក់កាលហ្នឹង វារបៀបធ្វើដូចគ្នា ការចូលរួមរបស់គាត់ក៏ខុសគ្នាដែរ។

[០៩:៤៧:២០]

ព្រោះយើងស្ដាប់ពីរថ្ងៃហើយ ស្ដាប់គាត់ទាក់ទងនឹងបញ្ហានេះពីរថ្ងៃហើយតាំងពីនៅស្ទឹងជីនិតការចូលរួមរបស់គាត់ក្នុងការងាររោងពុម្ពនេះ វាមានលក្ខណៈដោយឡែកពីការងារដែលគាត់ចូលមកធ្វើការងាររោងពុម្ពនៅភ្នំពេញ វាមានការវិវត្តផ្នែកឧបករណ៍ បច្ចេកទេស ទីកន្លែងខុសគ្នា កាលៈទេសៈខុសគ្នា។ ហើយបើលោកយកសួរសំណួរទី១ យកមកគិតបូកសរុបជាមួយនឹងអាទី២ អាចលោកយល់ឃើញអាចគិតថាខុសគ្នាអ៊ីចឹង។ សូមៗរៀបចំឱ្យបានល្អនូវសំណួរ ហើយនិងវែកញែកឱ្យបានច្បាស់លាស់រវាងពេលវេលានេះ។ ទីកន្លែងណា? ធ្វើរបៀបម៉េច? ទីកន្លែងណា? ធ្វើរបៀបម៉េច? ដើម្បីឱ្យច្បាស់លាស់។

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ដែល

មានវត្តមាននៅទីនេះ។ ខ្ញុំងើបឡើងដើម្បីបញ្ជាក់អំពីបញ្ហានៃការបកប្រែ ពីព្រោះថាវាមានការលំបាកណាស់សម្រាប់ខាងយើង។ ខ្ញុំសូមរំឭកអំពីសារៈសំខាន់នៃការបកប្រែជាភាសាបារាំងនៅពេលដែលមានអ្នកសួរក៏ជាខ្មែរ អ្នកឆ្លើយក៏ខ្មែរនោះ សូមឲ្យមានការសម្រាកបន្តិចមុននឹងសួរហើយនិងឆ្លើយ។ ហើយអម្បាញ់មិញនេះគឺថា មាននិយាយបីនាក់តទល់គ្នាលោកប្រធានផង សាក្សីផង ហើយនិងលោកមេធាវីផង។ ដូច្នេះសូមឲ្យនិយាយ ហើយសម្រាកខ្លះបន្តិចទៅ ដើម្បីឲ្យមានការបកប្រែជាភាសាបារាំងឲ្យបានល្អ។ សូមអរគុណលោកប្រធាន។

[០៩:៤៩:១៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមឲ្យមានការបញ្ជាក់លើការបកប្រែផងដែរ។ គឺនៅពេលនោះគឺនិយាយអំពីការរៀងកសារ ហើយគេប្រើប្រាស់លិខិតម៉ូ ខ្ញុំមិនដឹងថាតើលិខិតម៉ូហ្នឹងគេចង់មានន័យយ៉ាងម៉េចនោះទេ ខ្ញុំស្តាប់អត់យល់។

**ប្រធានអង្គជំនុំ៖**

បាទ វាអត់ខុសគ្នាទេ ខ្មែរក៏ប្រហែលជាការយល់ហ្នឹងក៏មិនយល់ដែរ ពីព្រោះពាក្យបច្ចេកទេសខាងបោះពុម្ព។ ទម្រាំមេធាវីខ្មែរ ក៏ប្រហែលជាខ្ញុំដែរ ពីព្រោះគេប្រើភាសាបច្ចេកទេសនៅរោងពុម្ព ដែលខ្ញុំនឹងមិនដែលស្គាល់ អំពីបច្ចេកទេសរោងពុម្ពហ្នឹងយ៉ាងម៉េចទេ។ អ៊ីចឹងគេប្រើប៉ូហ្នឹង គឺប្រើប៉ូ ជាមួយគេទៅតែប៉ុណ្ណឹងទេ។ ពីព្រោះមិនតម្រូវឲ្យចៅក្រមទៅមើលរោងពុម្ព ហើយរៀនពីរោងពុម្ពសិន សឹមមកអង្គុយស្តាប់នូវការសួរដេញដោល អំពីបច្ចេកទេសរោងពុម្ពទេ។ គ្រាន់តែអាចបែងចែកឲ្យច្បាស់លាស់ថា រវាងបែបផែននៃការអនុវត្តក្នុងការបោះពុម្ពបែបពាក់កណ្តាលបុរាណ ដោយវិធីប្រើស្តង់ស៊ីល របៀបធ្វើយ៉ាងដូចម្តេច។ សរសេរដោយដៃ ចម្លងចេញពីអត្ថបទ ដែលអ្នកនិពន្ធគេធ្វើហើយ គេចែកគ្នាសរសេរដោយដៃ នៅលើស្តង់ស៊ីលរួចហើយ យកទៅរុញ -- ទៅបោះពុម្ពដោយប្រើក្រដាសស្តង់ស៊ីលអ៊ីចឹងទៅ។

[០៩:៥០:៥០]

ហើយមួយទៀត គឺប្រើបច្ចេកទេសទំនើប មិនទើបដូចសព្វថ្ងៃ ប៉ុន្តែទើបជាងអាប្រភេទស្តង់ស៊ីលនេះ។ អ៊ីចឹងហើយ បានជាយើងកំណត់ឲ្យការសួរដេញដោលនេះ បែងចែកឲ្យច្បាស់លាស់រវាងពេល

វេលា នៅក្នុងការអនុវត្តមុខងាររបស់គាត់នៅក្នុងរោងពុម្ព នៅក្នុងសម័យទសវត្សរ៍ឆ្នាំ៧០ មករហូតដល់ ៧៥ និងចន្លោះ៧៥ មក៧៩ វារបៀបធ្វើការនេះ ខុសគ្នា។ បើយើងយកអាបញ្ហា ដែលរបៀបធ្វើការរបស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ៧០, ៧១, ៧២, ៧៣ យកមក មកទូទាត់គ្នា មកបញ្ជាក់លើអ្វីដែលវាមាននៅក្នុងអំឡុង៧៥-៧៩ វាផ្ទុះបញ្ចាំងគ្នាកើតទេ ពីព្រោះបច្ចេកទេសហ្នឹង វាខុសគ្នា។ អ៊ីចឹងហើយ បានជាយើងបញ្ជាក់បញ្ហានេះ ទី១។ ទី២ គឺមេធាវីក្រុម ទាំងពីរក្រុម មានពេលវេលាតែមួយព្រឹកនេះទេ។ នៅមេធាវី អៀង សារី ទៀត ដែលលោកមេធាវី សុន អរុណ។

[០៩:៥១:៥៦]

**លោក សុន អរុណ៖**

ខ្ញុំយល់ថា ចំណុចដែលខ្ញុំសួរនេះ ជាចំណុចមួយសម្រាប់ដោះបន្ទុកកូនក្តីខ្ញុំ ជាចំណុចសំខាន់ណាស់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ហើយ បញ្ហាគឺមេធាវី គឺជាមុខងាររបស់លោក គឺមិនមែនមុខងាររបស់មេធាវីសួរដាក់ -- ដើម្បីដាក់បន្ទុកកូនក្តីរបស់លោកទេ។ ប៉ុន្តែការតាំងសំណួរកុំឲ្យមានការច្រឡំ។ កាលណាច្រឡំទៅ វាទៅមុខអត់រួច តែប៉ុណ្ណឹងទេ។ សូមបែងចែកបញ្ហានេះ ឲ្យច្បាស់ ពីព្រោះរវាងសរសេរដោយដៃ ឥឡូវអំមិញនេះ គឺវាដំណាក់ខុសគ្នា តែប៉ុណ្ណឹងទេ។ យើងចង់ឲ្យលោកហ្នឹង មានការបញ្ជាក់បញ្ហាហ្នឹង ឲ្យនេះច្បាស់ ហើយញែកឲ្យបានច្បាស់លាស់ រវាងពេលវេលាពីរហ្នឹង ខុសគ្នានេះ តែប៉ុណ្ណឹងតើ។

[០៩:៥២:៣៦]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ឥឡូវ ខ្ញុំសូមសួរបន្តទៅទៀត។ សូមសួរលោក វុន ថា លោកបានបញ្ជាក់ជម្រាបភាគីរួចហើយ ពីម្សិលមិញថា ទង់បដិវត្តនេះ សៀវភៅនេះ ជាសៀវភៅមួយ ប្រាកដប្រជា ហើយដែលលោកបានឃើញ។ ខ្ញុំចង់ គ្រាន់តែចង់សួរថាត្រឡប់ក្រោយវិញបន្តិចថា ទង់បដិវត្ត ដែលលោកបានឃើញនេះ ជាអក្សរអ៊ីចឹង ឬក៏អក្សរដៃ? អាហ្នឹង ពេលណាដែលលោកឃើញអក្សរដៃ? ពេលណាដែលលោក

ឃើញបោះពុម្ពអ៊ីចឹង?

**លោក គីម វុន៖**

**ឆ៖** បាទ អក្សរដៃ គឺនៅក្នុងពេលសង្គ្រាម៥ឆ្នាំ ឯនៅក្នុងសម័យឆ្នាំ៧៥ហើយ គឺបច្ចេកទេសបោះពុម្ព គឺថ្មី។ ដូចខ្ញុំថាអ៊ីចឹង បោះពុម្ពជាទីប៉ូ មានឃ្លីស្សេ មានបោះអុបសិត អ៊ីចឹង។ ដូច្នេះ មិនបោះពុម្ពដូចសម័យសង្គ្រាមទេ ខុសគ្នា។ ប៉ុន្តែអត់យល់បច្ចេកទេស ខ្ញុំពិបាកពន្យល់ តែបើយល់ខ្ញុំ ដឹងបច្ចេកទេសអត់ទេ។

**ស៖** ខ្ញុំមិនដឹង មិនចង់សួររឿងបច្ចេកទេសស៊ីជម្រៅទេ គ្រាន់តែចង់ដឹងថា លោកបានឃើញទង់បដិវត្តសរសេរដៃ។ លោកបានឆ្លើយជម្រាបតុលាការ ហើយនិងទង់បដិវត្ត ដែលមានបោះពុម្ព ដែលព្រះរាជអាជ្ញាបានជូនលោកអ៊ីចឹង មុខលោកហ្នឹង។ តើវាស៊ីសង្វាក់គ្នាទេ ទង់បដិវត្តសរសេរអក្សរដៃ? ហើយនិងទង់បដិវត្តដែលនៅមុខលោកហ្នឹង?

[០៩:៥៤:៣៨]

**ឆ៖** ឯកសារនេះ តាមខ្ញុំមើល គឺបោះនៅឆ្នាំ៧៥ហ្នឹងទេ អត់មានសរសេរដៃអីទេ។ សរសេរដៃដែលខ្ញុំនិយាយដែលពាក់ព័ន្ធហ្នឹង គឺនៅលើចំណងជើង ឬក៏ធ្វើក្រប។ ដូច្នេះ អត្ថបទទាំងមូល គឺបោះទីប៉ូទាំងអស់។ បោះពុម្ពតែម្តង បោះពុម្ពដូចកាសែតផ្សេងទៀតដែរ។

**ស៖** សូមអរគុណ។ លោកមានសម្គាល់ឃើញថា ដែលឃើញទង់បដិវត្តសរសេរបោះពុម្ពដាក់នៅមុខលោកហ្នឹង មានលក្ខណៈខុសគ្នា អានេះចំណុចដែលខ្ញុំចង់សួរហ្នឹងណ៎ា ពីដែលលោកឃើញក្នុងរយៈ៥ឆ្នាំនោះទេ? ហើយមានលក្ខណៈដូចជា ក្របសៀវភៅហ្នឹងមានទង់ មានពណ៌ ឬក៏ភិនភាគទូទៅហ្នឹងដូចគ្នា ឬក៏ខុសគ្នា?

[០៩:៥៦:០២]

**ឆ៖** ច្បាប់នេះ ច្បាប់ចតចម្លង ហើយខ្ញុំមើលក្នុងហ្នឹងជាឯកសារពិត របស់ទង់បដិវត្តបោះនៅឆ្នាំ៧៥ ហ្នឹងឯង ព្រោះបច្ចេកទេសនេះវាទំនើបជាងមុន អង្កាល់មុនពួកខ្ញុំធ្វើដោយសរសេរដៃទេ។ តែសម័យនេះ ដល់គេមានរោងពុម្ពបោះទីប៉ូអ៊ីចឹង គេបោះជាទីប៉ូ ឯក្របនេះគេបោះអុបសិតតែម្តង បោះលើស្លាកស័ង្កសី។

**ស៖** បើដូច្នោះ មានន័យថា កាលពីលោកឃើញក្នុងរយៈ៥ឆ្នាំ និងទង់បដិវត្តនេះ មិនដូចគ្នាទេ។ អ៊ីចឹងអីម៉េច? របៀបបច្ចេកទេសធ្វើខុសគ្នាហើយ?

**ឆ៖** ទ្រង់ទ្រាយហ្នឹង ដូចដើមទាំងអស់ គ្រាន់ថា យើងមើលអ៊ីចឹងទៅវាខ្មៅស មែនទែនបោះៗ ស្តង់ស៊ីល ក៏ពណ៌ក្រហមដែរ ទង់ហ្នឹង ទង់ក្រហម អក្សរនេះអក្សរក្រហម ខ្មៅតែកន្លែងលេខនេះទេ។ ឯ បោះពុម្ពនៅឆ្នាំ៧៥ បោះពុម្ពដូចអង្កាល់មុនដែរ ប៉ុន្តែគ្រាន់ថា គ្រាន់តែកែបច្ចេកទេស មិនមានកែរូបរាងអី ថ្មីទៀតទេ។ ឯមានលក្ខណៈកែសម្រួលថ្មី នេះនៅក្នុងឆ្នាំ៧៧ហ្នឹង គឺលែងមានប្រាំហើយ មានតែមួយនេះ ទេ កែគឺកែត្រង់ហ្នឹង បើនេះអត់មានកែទេ នៅឆ្នាំ១៧៦ ហ្នឹងអត់ទាន់កែទេ ទើបមកឆ្នាំ៧៧ បានយើង កែ។

[០៩:៥៨:១៩]

**ស៖** អរគុណ។ ខ្ញុំសួរទៅសំណួរមួយបន្ទាប់ទៀត។ នៅក្នុងឯកសារដែលខ្ញុំសួរអំមិញដដែល នៅលេខ E3/370 ត្រង់ចម្លើយរបស់លោក ស្តីអំពីរចនាសម្ព័ន្ធ និងឋានានុក្រមរបស់រដ្ឋាភិបាល និង សភាតំណាងរាស្ត្រប្រជាជនកម្ពុជា នៃកម្ពុជាប្រជាធិបតេយ្យ។ ចម្លើយរបស់លោកត្រង់ឃ្លាថា "នួន ជា ជាប្រធានតំណាងប្រជាជនកម្ពុជា ជាតំណាងសភា ជាប្រធានសភាតំណាងប្រជាជនកម្ពុជា -- សូម ទោស -- ជា ស៊ីម ជាអនុប្រធានរបស់ នួន ជា"។ សំណួរនេះបាន -- ព្រះរាជអាជ្ញាបានសួររួចហើយ ក៏ប៉ុន្តែខ្ញុំសួរបន្ថែមត្រង់កន្លែងនេះ បន្ទាប់ពី ជា ស៊ីម, មាន ម៉ាត់ លី ម្នាក់ទៀត ជាអនុប្រធានរបស់ នួន ជា។ ចម្លើយរបស់លោកនេះ កាលពីម្សិលមិញ ព្រះរាជអាជ្ញាបានសួរម្តងរួចហើយ ប៉ុន្តែត្រឹមតែអនុ ប្រធានលោក នួន ជា អ៎! លោក ជា ស៊ីម។ ខ្ញុំបន្ថែមលោក ម៉ាត់ លី មួយទៀត ពីព្រោះអីក្នុងឯកសារ មាននិយាយអ៊ីចឹង លោកបានឆ្លើយចំពោះចៅក្រមស៊ើបអង្កេត។ ចម្លើយនេះ លោកនៅរក្សាដដែល ឬ យ៉ាងម៉េច?

[១០:០០:០៦]

**ឆ៖** ពាក្យដែលខ្ញុំនិយាយ គឺនិយាយក្នុងសម័យនោះ ហើយខ្ញុំអះអាងថា ខ្ញុំបាននិយាយមែន។ ប៉ុន្តែការវាយតម្លៃរបស់ខ្ញុំក្នុងសម័យនោះ ខ្ញុំថាអ៊ីចឹង ព្រោះមិត្តភក្តិនៅកន្លែងខ្ញុំ ក៏យល់ថាអ៊ីចឹង។ ដល់ អ៊ីចឹងជាការយល់ខុសត្រូវអី គឺសម័យនោះគឺនិយាយទាំងអស់គ្នាថាអ៊ីចឹង។ ប៉ុន្តែឯកសារពិតដូចនេះខ្ញុំអត់ បានដឹងទេ ព្រោះរឿងផ្ទៃក្នុងរបស់បក្ស ឬការចាត់តាំងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលអី ក៏យើងមិនដឹង អស់ដែរ។ ព្រោះយើងរវល់ចុះទៅស្រែ ទៅចម្ការ ទៅការដ្ឋានអីៗ ម្ល៉ោះហើយមិនសូវស្វែងពីនេះទេ ចេះ តែនិយាយតគ្នាទៅ គឺសម័យនោះ គឺអ្នកខ្លះយល់អ៊ីចឹង។ ប៉ុន្តែជួនកាលសម័យនោះ អាចខ្ញុំនិយាយក៏ខុស ដែរ។ ប៉ុន្តែខ្ញុំថា ខ្ញុំនិយាយត្រូវរបស់ខ្ញុំ ព្រោះការយល់សម័យនោះខ្ញុំយល់ថាអ៊ីចឹង ហើយពេលតុលាការ

ទៅសួរ គឺសួរក្នុងរយៈកាលនោះ។ ដូច្នេះន័យខ្ញុំយល់អង្កាល់ហ្នឹង គឺខ្ញុំអះអាងតែប៉ុណ្ណឹង។ ព្រោះខ្ញុំយល់ថា ការនិយាយរបស់ខ្ញុំហ្នឹងត្រឹមត្រូវ។ ប៉ុន្តែការពិតក្នុងឯកសារ ក្នុងរចនាសម្ព័ន្ធជាក់ស្តែងមែនទែននេះ ក៏អាហ្នឹងទៅតាមហ្នឹង។ អ៊ីចឹងការអះអាងរបស់ខ្ញុំ ខ្ញុំនៅតែអះអាងថា ខ្ញុំយកតាមចម្លើយខ្ញុំដែលឱ្យទៅខាងចម្លើយដើម។

[១០:០១:៤៨]

**ស៖** សូមអរគុណ។ ត្រង់សំណួរមួយទៀត លោកបានឆ្លើយចំពោះចៅក្រមស៊ើបអង្កេតដដែល លោកថា “ចៅក្រមស៊ើបអង្កេត អ៎! សូមទោស! គណៈកម្មការមជ្ឈិមមានលោក ប៉ុល ពត ជាលេខាបក្ស, មានមានលោក នួន ជា ជាអនុលេខាបក្ស និងសមាសភាពផ្សេងទៅទៀត”។ ប៉ុន្តែលោកឆ្លើយនេះ លោកមិនបាននិយាយអំពីសមាជិកផ្សេងទៀតទេ ចៅក្រមសួរថា “រចនាសម្ព័ន្ធគ្រប់គ្រងគណៈកម្មការ -- រចនាសម្ព័ន្ធរបស់គណៈកម្មការមជ្ឈិម”។ ខ្ញុំសូមសួរម្តងទៀតថា គណៈកម្មការមជ្ឈិមនៅក្នុងហ្នឹងមានប៉ុន្មាននាក់បើតាមលោកដឹង? បើលោកមិនដឹង អាហ្នឹងក៏លោកឆ្លើយថា អត់ដឹង។ មានប៉ុន្មាននាក់? ហើយមានឈ្មោះអីខ្លះ បើលោកចាំ?

**ឆ៖** ខ្ញុំអត់ដឹងអីទាំងអស់។ ប៉ុន្តែខ្ញុំដឹងថា អ៊ំទី១, អ៊ំទី២ ច្បាស់ជាមជ្ឈិមតែម្តង ខ្ញុំវាយតម្លៃថាអ៊ីចឹង។ អ្នកផ្សេងទៀតខ្ញុំអត់ដឹង។

[១០:០៣:៤៤]

**ស៖** សូមអរគុណ។ ចម្លើយមួយបន្ទាប់ទៅទៀត នៅក្នុងឯកសារទំព័រដដែល គឺ E3/380 លោកឆ្លើយថា “ខ្ញុំធ្លាប់ជាកម្មាភិបាលខ្មែរក្រហម។ នួន ជា, ខៀវ សំផន, ប៉ុល ពត ធ្លាប់ស្គាល់ខ្ញុំ តែអៀង សារី, អៀង ធីរិទ្ធ ខ្ញុំមិនសូវស្គាល់ទេ”។ លោកស្គាល់បីនាក់ខាងលើនេះ នួន ជា, ខៀវ សំផន និង ប៉ុល ពត ស្គាល់ច្បាស់លាស់ទេ?

**ឆ៖** ដោយខ្ញុំមិនមែនជាកម្មាភិបាលក្នុងបក្ស ខ្ញុំជាសម្ព័ន្ធយុវកក ប៉ុន្តែក៏មានងារជាកម្មាភិបាលក្រៅបក្ស ព្រោះកម្មាភិបាលនេះតាំងក្នុងរណសិរ្សមក។ ឧបមាថា អង្គការយុវជន យុវនារីមួយត្រូវមានគណៈកម្មការរបស់គេបី។ ត្រូវមានចាត់តាំងអ៊ីចឹងនៅៗក្នុងហ្នឹង ក៏យើងហៅថា អ្នកទទួលខុសត្រូវជាកម្មាភិបាលដែរ ប៉ុន្តែមិនមែនកម្មាភិបាលបក្សទេ។ ដូច្នេះជួរកម្មាភិបាលវាមានទាំងក្នុងបក្ស មានទាំងក្រៅបក្ស។ សូម្បីជនចម្រើន ឬជនបង្គោលជាបញ្ញវន្តហ្នឹង ក៏ជាកម្មាភិបាលដែរ ប៉ុន្តែមិនមែនជាកម្មាភិបាលរបស់បក្សទេ ជាអ្នកនៅក្រៅបក្ស។ ហើយខ្ញុំក៏ការរៀបចំការទទួលខុសត្រូវ គឺខ្ញុំជា

កម្មាភិបាល ប៉ុន្តែមិនមែនកម្មាភិបាលក្នុងបក្សទេ។ ព្រោះខ្ញុំទៅទទួលខុសត្រូវអីមួយ ទៅទទួលខុសត្រូវឧបមាថា អត់ពី បងឆយ អត់ពី បងកែ ទៅខ្ញុំទៅទទួលខុសត្រូវប្រធានកាសែត។ អ៊ីចឹងគឺការតែងតាំងជាការចាត់តាំងរបស់រដ្ឋមន្ត្រីគឺខ្ញុំជាកម្មាភិបាលហើយ ប៉ុន្តែនៅជាកម្មាភិបាលក្រៅដែលហ្នឹង ព្រោះមិនមែន -- ព្រោះសម្ព័ន្ធយុវកកវាមិនចូលទៅក្នុងកម្មាភិបាលក្នុងបក្សទេ។

[១០:០៧:១៦]

**ស៖** ចំណុចដែលខ្ញុំចង់សួរលោកសាក្សី ត្រង់ថា លោកថាបានស្គាល់បីនាក់ -- មេដឹកនាំបីនាក់នេះច្បាស់លាស់។ និយាយតាំងពីម្សិលមិញរហូត។ ខ្ញុំចង់សួរថា លោកស្គាល់ច្បាស់លាស់ លោកស្គាល់អត្តចរិតរបស់មេដឹកនាំ ប៉ុល ពត ច្បាស់លាស់ៗទេ? ហើយគាត់មានលក្ខណៈយ៉ាងម៉េច? ជាមនុស្សឃោរឃៅកាប់សម្លាប់ ធ្វើអ្វីដោយគ្មានឧត្តមគតិ ឬក៏គាត់ជាមនុស្សមានឧត្តមគតិល្អ ស្រឡាញ់ជាតិ ហើយធ្វើអ្វីដោយមានការត្រិះរិះត្រឹមត្រូវ?

**ឆ៖** តាំងពីឆ្នាំ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន! លោកមេធាវីកំពុងតែឲ្យសាក្សីធ្វើការសន្និដ្ឋានអំពីអត្តចរិតរបស់បុគ្គលមួយរូប។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅដើមបណ្ដឹងរដ្ឋប្បវេណី។ សំណួរនេះខ្ញុំបានសួរច្រើនមកហើយចំពោះសាក្សី មិនដែលមានខាងដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់ទេ។ អំមិញនេះខ្ញុំសួរដដែលទៀត ខ្ញុំសូម -- បើសិនលោកប្រធានអនុញ្ញាតសូមឲ្យលោកសាក្សីឆ្លើយក្នុងសំណួររបស់ខ្ញុំ។ ខ្ញុំមានសំណួរបន្តពីហ្នឹងទៀត ដើម្បីភ្ជាប់នឹងសំណួរហ្នឹង។

[១០:០៨:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរ! ជំទាស់គ្មានប្រសិទ្ធភាពទេ។

**លោក គឹម វុន៖**

**ឆ៖** តាមការទាក់ទងរស់នៅធ្វើការងារ ចំពោះបុគ្គលទាំងបីហ្នឹង ខ្ញុំអះអាងថាខ្ញុំស្គាល់ច្បាស់។ បើនិយាយនៅលើអត្តចរិត ដូចខ្ញុំបាននិយាយពីម្សិល ជាឧទាហរណ៍ដូចលោក ខៀវ សំផន អ៊ីចឹង។ ដូច្នេះខ្ញុំបាននិយាយពីម្សិលហើយ លក្ខណៈសម្បត្តិរបស់គាត់យ៉ាងម៉េច ការទាក់ទាញយ៉ាងម៉េច មានមនោសញ្ចេតនារបស់ -- ទៅលើមហាជនយ៉ាងម៉េច គឺខ្ញុំបានលើកឧទាហរណ៍ហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះសំណួរសួរចំពោះ ប៉ុល ពត។ សំណួរនេះមិនពាក់ព័ន្ធទេ ប៉ុន្តែវាជាបុព្វបទមួយនឹងអាចសួរភ្ជាប់នឹង នួន ជា។ រឿង ខៀវ សំផន ហ្នឹងដោយឡែក ប្រហែលជាទំនងមេធាវីមិនសួរទេ។ អ៊ីចឹងលោកស្តាប់សំណួរឲ្យបានច្បាស់ ហើយឆ្លើយតបទៅនឹងកម្រិតសមស្រប សមល្មមទៅនឹងសំណួរដែលសួរជាការល្អ។ ចៀសវាងព្យាយាមនិយាយក្រៅ ដែលមិនតបទៅនឹងសំណួរដែលសួរ នាំឲ្យលទ្ធផលនៃចម្លើយរបស់លោកវាអត់តម្លៃជាភស្តុតាងនៅក្នុងរឿងក្តី ហើយវាបាត់បង់ពេលវេលាឥតប្រយោជន៍ ខាតពេលវេលា។ ជាពិសេសលោកនឹងទទួលរងនូវសម្ពាធនៃការតាំងសំណួរដដែលៗនេះ ច្រើនលើក ច្រើនសា។ នីតិវិធីតាំងសំណួរដេញដោលដោយតុលាការ យើងប្រើពាក្យថា “តាំងសំណួរដេញដោល” យើងមិនប្រើពាក្យលើសពីនេះ រហូតដល់ល្បែចសួរចម្លើយទេ គឺវានីតិវិធីវាបង្ខំ អ៊ីចឹងហើយបានយើងប្រើនីតិវិធីតាំងសំណួរដេញដោលចំពោះមុខតុលាការ មិនមែនសួរសាមញ្ញទេ។ លោកឆ្លើយទៅនឹងសំណួររបស់គាត់សួរពីរឿងអត្តចរិតរបស់ ប៉ុល ពត តែម្នាក់គត់។ បើលោកដឹងឆ្លើយថាដឹង បើលោកអត់ដឹងឆ្លើយថា អត់ដឹង។ លោកមិនគប្បីធ្វើសេចក្តីសន្និដ្ឋាន ឬបញ្ចេញនូវការយល់ដឹងផ្ទាល់ខ្លួនទៅលើព្រឹត្តិហេតុហេតុការណ៍ ឬបុគ្គលណាមួយបានទេ។ ពីព្រោះលោកជាសាក្សីមិនមែនជាអ្នកជំនាញទេ យើងបានជម្រាបជូនទៅច្រើនលើកហើយ។

[១០:១១:១៩]

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំនៅតែអះអាងថា ខ្ញុំស្គាល់ច្បាស់លោក ប៉ុល ពត។ ស្គាល់ច្បាស់យ៉ាងម៉េច ព្រោះនៅក្នុងការអប់រំកន្លងមក ជួនកាលមានពេលខ្លះនៅឆ្នាំ៧១ គាត់ចុះទៅ គាត់បានណែនាំ។ ណែនាំ ក្នុងការណែនាំមានតែលើកទឹកចិត្តៗ និងនិយាយអំពើល្អ ប៉ុន្តែខ្ញុំមិនដឹងថា គាត់ប្រព្រឹត្តអីក្រៅពីកាយវិការ ពីអត្តចរិតគាត់ផ្សេងទៀតក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែមើលជាក់ស្តែងការរួសរាយរាក់ទាក់ ការម៉ឺងម៉ាត់ ហើយនិង

ការណែនាំផ្សេងៗ ណែនាំតែអំពើល្អទេ។ ដូចខ្ញុំលើកពីរឿងសីលធម៌ ១២ប្រការ អ៊ីចឹង តែងតែរំឭកៗពីការប្រុងប្រយ័ត្ន ដូច្នេះនៅសម័យនោះ ខ្ញុំយល់ថា គាត់ជាមនុស្សល្អ មានអត្តចរិតល្អ។ ហ្នឹងក្នុងសម័យ ៥ឆ្នាំ ហើយក្នុងសម័យក្រោយក៏ខ្ញុំឃើញថា អាចមានជាកំហុសដែរ ព្រោះអត្តចរិតគាត់ជឿនៅលើរបាយការណ៍ច្រើនដែរ។

[១០:១៣:០៥]

**លោក សុន អរុណ៖**

**ស៖** សូមអរគុណលោក វ៉ុន ហើយចុះចំពោះអ្នកដែលលោកស្គាល់ច្បាស់លាស់ដែរ លោក នួន ជា លោកអាចបានឃើញ បានស្គាល់គាត់ច្បាស់លាស់លោកមានចរិតយ៉ាងម៉េច?

**ឆ៖** នៅលើអត្តចរិតគាត់រួសរាយរាក់ទាក់ធម្មតា រស់នៅសាមញ្ញធម្មតា ហើយការណែនាំក្នុងការរស់នៅអីក៏ឃើញថា មិនមានអីប្លែកពីអ្នកដឹកនាំផ្សេងទៀត។ ឃើញរស់នៅជាសាមញ្ញធម្មតា ហើយការណែនាំឃើញតែណែនាំអំពីការធ្វើការងារយ៉ាងម៉េចឲ្យល្អ ការរស់នៅល្អ។

**ស៖** សូមអរគុណ។ លោកៗជាមន្ត្រីថ្នាក់កណ្ដាលម្នាក់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយមុនកម្ពុជាប្រជាធិបតេយ្យក៏លោកធ្វើការច្រើនទោះបីលោកនៅក្មេងក្ដី។ លោកដឹងថា នៅក្នុងបក្សកុម្មុយនីស្ដកម្ពុជាហ្នឹងមានរចនាសម្ព័ន្ធ ឧទាហរណ៍ថា រដ្ឋាភិបាលគេហៅនីតិប្រតិបត្តិ រដ្ឋសភាជានីតិប្រតិបត្តិ និងបក្ស។ លោកយល់ស្របតាមខ្ញុំអ៊ីចឹងទេ រចនាសម្ព័ន្ធរបស់បក្សកាលសម័យសង្គម -- កាលសម័យ ៧០ មកដល់៧៥ ហើយនិង៧៥ មកដល់៧៩?

[១០:១៥:៣០]

**ឆ៖** ខាងផ្នែកបក្ស ខ្ញុំឃើញថាមាន អ៊ំប៉ុល ទី១, អ៊ំនួន ជា ទី២ ហើយក្រៅពីនោះទៀតក៏ខ្ញុំអត់ដឹង។ នៅផ្នែករដ្ឋាភិបាល គឺមាន អ៊ំប៉ុល ទី១ ហើយនិងមានឧបនាយក អៀង សារី ទទួលបន្ទុកខាងក្រសួងការបរទេស, សុន សេន ទទួលខាងការពារជាតិ និងមួយចំនួនទៀតមិនចាំអស់។

**ស៖** ចុះចំពោះនីតិបញ្ញត្តិខាងរដ្ឋសភា ខាងសភាប្រជាជនកម្ពុជា លោកដឹងថាអ្នកណាអ្នកកាន់កាប់?

**ឆ៖** ខ្ញុំបានឆ្លើយពីខាងដើមហើយ ខ្ញុំនៅតែអះអាងដូចពាក្យខ្ញុំបាននិយាយមុន។ ការយល់របស់ខ្ញុំ និងអ្នកផ្សេងទៀតក្នុងសម័យនោះ។ ខ្ញុំមិនដឹងអ្នកផ្សេងទៀតមានប៉ុន្មានទៀតទេ។ ព្រោះខ្ញុំនិយាយលើកមុន ខ្ញុំនិយាយតែ អ៊ំ នួន ជា, អ៊ំ ជា ស៊ីម និងអ៊ំ ម៉ាត់ លី ហើយក្រៅពីនោះខ្ញុំអត់ដឹង។ អ៊ីចឹងទាំង

អស់គ្នាទៅកាសែតនៅពេលនោះ មិនបានចាប់អារម្មណ៍ពីរចនាសម្ព័ន្ធរបស់សភា របស់រដ្ឋាភិបាលប៉ុន្មានទេ។ ម្នាក់ៗគឺខិតខំតែធ្វើការងារ។ ការស្ទើៗយល់ដោយខ្លួនឯង សូម្បីតែឈ្មោះថ្នាក់ដឹកនាំ អ្នកខ្លះមិនទាន់ស្គាល់ផងហ្នឹង គេចាត់តាំងឲ្យធ្វើអី សម័យនោះគឺយើងធ្វើហ្នឹង។ មិនមែនដូចកាសែតសម័យនេះ គេចេញមកអ៊ីចឹងទៅ យើងដឹងទាំងអស់នោះទេ។

**ស៖** ខ្ញុំសូមអរគុណ ខ្ញុំចង់បាននេះលោកតែប៉ុណ្ណឹង។ លោកដឹងថា លោក ជា ស៊ីម ជាប្រធានសភាប្រជាជនកម្ពុជា។ បន្ទាប់ពីហ្នឹងលោកមានដឹង ដែលឮ ឬក៏ដឹងថាលោក នួន ជា មានមុខងារអ្វីផ្សេងទៀតទេ?

**ឆ៖** ខ្ញុំ--

[១០:១៨:២៨]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! លោកមេធាវីរៀបចំសំណួរម្តងទៀត! សំណួររបស់លោកសួរថាម៉េចទៅ ដូចជាអាចច្រឡំដឹង?

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ។ លោកថាលោកសាក្សី លោកដឹងថា លោក នួន ជា ជាប្រធានសភាប្រជាជនកម្ពុជា ប៉ុន្តែក្រៅពីមុខងារប្រធានសភាហ្នឹង លោកសាក្សីដឹងថា លោក នួន ជា មានមុខងារអ្វីផ្សេងទៀតទេ?

**លោក គឹម វុន៖**

**ឆ៖** មុខងារផ្សេងទៀត ដូចខ្ញុំនិយាយពាក់ព័ន្ធនឹងក្រសួងឃោសនាការ ពេលលោកស្រី យុន យ៉ាត អត់នៅអ៊ីចឹងទៅ គាត់មានភារកិច្ចទៅជាប់ខាងឃោសនាការគឺផ្សាយនាទីអប់រំ។ និយាយពីឯកសារដែលអ្នកបច្ចេកទេសចិនធ្វើការពិសោធនៅមន្ទីរកសិកម្មនៅមេច្បារ ខេត្តបាត់ដំបង។ ផ្សាយម៉្ងៃម្តងៗ រាល់ថ្ងៃ ហើយនិងមានការណែនាំខាងសរសេរទៅខាងគណៈនិពន្ធនៅកន្លែងហ្នឹង។

[១០:២០:១២]

**ស៖** សូមអរគុណ។ ខ្ញុំមានមួយសំណួរទៀតទេ ចប់។ លោកមានងារជាមន្ត្រីថ្នាក់កណ្តាល ដូចខ្ញុំបានជម្រាបតុលាការអំមិញអ៊ីចឹង។ នៅក្នុងបក្សកម្ពុជាប្រជាធិបតេយ្យ លោកអាចដឹង ឬក៏ឃើញឯកសារណា អំពីរចនាសម្ព័ន្ធ និងឋានុនាក្រមរបស់រដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** ដូចខ្ញុំបានឆ្លើយពីខាងដើមហើយ។ ក្រុមខ្ញុំបាទ ក៏ដូចខ្ញុំបាទផ្ទាល់ មិនសូវបានចាប់អារម្មណ៍ពីរឿងរចនាសម្ព័ន្ធទេ។ ព្រោះការងារត្រូវថត ត្រូវអី ពេលគណៈប្រតិភូមក ឬក៏ការប្រកាសតែងតាំងផ្សេងៗនៅក្នុងសភា នៅក្នុងរដ្ឋាភិបាល។ ពួកខ្ញុំអត់ដែលចូលរួមទេ ហើយដល់អ៊ីចឹងហើយ យើងចាប់អារម្មណ៍តែរឿងការងារសរសេរ តែរឿងស្រែ រឿងចម្ការ រឿងសិប្បកម្ម រឿងទំនប់ រឿងប្រឡាយហ្នឹងទេ។

[១០:២១:៣២]

អ៊ីចឹង កាសែតយើងមានមុខងារតែប៉ុណ្ណឹង។ មិនដូចកាសែ គេសព្វថ្ងៃ តែឃើញស្អី សូម្បីតែឡានបុកគ្នា គ្រោះថ្នាក់ចរាចរណ៍អី យើងសរសេរភ្លាម។ ប៉ុន្តែសម័យនោះ មុខងាររបស់ខ្ញុំ គឺមានតែអនុវត្តអ៊ីចឹង។ ដូច្នេះ មិនបានស្វែងយល់ពីរចនាសម្ព័ន្ធអីៗ។ អ៊ីចឹង បានខ្ញុំថា សូម្បីតែថ្នាក់ដឹកនាំឈ្មោះអីមាខមុខងារអីឲ្យពិតប្រាកដ ហើយចេះតែស្មានៗទៅអ៊ីចឹង។ ជួនកាល យូរៗ ទៅ វាទៅទស្សនៈ ថា អ៎! អ៊ំ នួន ជា ហ្នឹង ប្រធានសភា។ អ៊ំ ជា ស៊ីម ហ្នឹង អនុប្រធានសភា។ អ៊ំ ម៉ាត់ លី ហ្នឹង បន្តៗអ៊ីចឹងទៅ។ ដូច្នេះ បើឃើញឯកសារគេឲ្យមកថា មុខងារអ្នកនេះ អ៊ីចេះៗ។ អ៊ីចឹង ការយល់របស់ខ្ញុំ មិនមែនមកយល់ ទើបនេះតឡូវទេ សម័យនោះ គឺពួកខ្ញុំយល់ថាអ៊ីចឹង។ សូមបញ្ជាក់សំណួរហ្នឹងឡើងវិញ។

[១០:២២:២៩]

**ប្រធានអង្គជំនុំ៖**

សាក្សីស្ដាប់សំណួរឲ្យបាន ហើយសួរ ឆ្លើយតបទៅនឹងសំណួរបានហើយ។ លោកសួរថា ដឹងដែរឬទេ? បើលោកអត់ដឹងទេ ឆ្លើយថា អត់ដឹងទៅ។ ហើយលោកទៅរៀបរាប់អីផ្សេង ដែលវាអត់មានការពាក់ព័ន្ធទៅនឹងសំណួរ។ វាអត់តបទៅនឹងសំណួរ។ យើងបានរំឭកច្រើនលើកច្រើនសាហើយ។ សំណួរហ្នឹង ច្រំដែលទៅលើលោកទេ ដែលលោកទទួលរងសម្ពាធហ្នឹងសំណួរហ្នឹង ហើយនិងអូសបន្លាយពេលវេលា អាចខាតពេលវេលាដល់ដំណើរការប្រព្រឹត្តទៅ ដែលអង្គជំនុំជម្រះប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព ហើយឆាប់រហ័សនេះ។ លោកស្ដាប់សំណួរឲ្យយល់ បើមិនយល់ លោកសួរម្ដងទៀត ថាសូមឲ្យតាំងសំណួរសាជាថ្មី។ ហើយស្ដាប់ឲ្យយល់ ហើយឆ្លើយ។

[១០:២៣:២២]

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។ ហើយសូមអរគុណសាក្សី។ ខ្ញុំនឹង សហភាតា

ខ្ញុំនឹងសួរបន្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកដល់សាក្សីរូបនេះនៅបន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅពេលវេលាកំណត់ គឺម៉ោងដប់មួយខ្វះម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:២៤ នាទី ដល់ម៉ោង១០:៤២ នាទី)*

[១០:៤២:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់ ហើយសូមជម្រាបសួរដល់លោកសាក្សី គឹម វុន។ មុនពេលដែលខ្ញុំចាប់ផ្តើម លោកប្រធាន ខ្ញុំសូមបញ្ជាក់បន្តិចគឺថា មេធាវីការពារក្តីបានទទួល ១.៧៥ -- ០.៧៥ ថ្ងៃ ហើយយើងមានពេលរហូតទៅដល់ម៉ោងដប់ពីរថ្ងៃត្រង់នេះ ដើម្បីចោទសួរសាក្សី។ ហើយលោក កាណាវាស ប្រហែលជាមានពេល ប្រហែលត្រឹមសាម -- ប្រហែលជាត្រូវការពេល៣០នាទី ដើម្បីចោទសួរប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

[១០:៤៤:០៧]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក គឹម វុន សូមអរគុណ ដែលលោកបានមកផ្តល់សក្ខីកម្មនៅទីនេះ។ ខ្ញុំគិតថា វាជាការលំបាកមួយ ហើយប្រហែលជាលោកអស់កម្លាំង ហើយខ្ញុំគិតថា យើងនឹងបញ្ចប់ការសួរដេញដោលរបស់លោកនៅព្រឹកនេះ។ ខ្ញុំនឹងនិយាយដោយយឺតៗ ដើម្បីឲ្យខាងបកប្រែ ក៏ដូចជាខាងមេធាវីបារាំងគាត់មានការងាយស្រួលក្នុងការតាមដាន។ ខ្ញុំសូមធ្វើការសួរដេញដោល ដើម្បីបំពេញបន្ថែមទៅលើអ្វីដែលលោកបានជម្រាបដល់ខាងព្រះរាជអាជ្ញា កាលពីម្សិលមិញ។ លោក គឹម វុន ពីពេលកន្លែងមកហ្នឹង គឺលោកបានផ្តល់សក្ខីកម្មថា "យុន យ៉ាត គាត់គ្រប់គ្រងទាំងក្រសួងឃោសនាការ និងក្រសួងអប់រំ"។ តើលោកចាំដែរឬទេ ថាតើនៅក្នុងឆ្នាំណាដែល យុន យ៉ាត គាត់ចាប់ផ្តើមការងារគ្រប់គ្រងទៅលើក្រសួងទាំងពីរនេះ?

**លោក គឹម វុន៖**

**ឆ៖** បាទ ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែដឹងថា ក្រសួងទាំងពីរអាចនៅរវាងឆ្នាំ៧៧, ៧៨។

**ស៖** តាមដែលលោកដឹង តើ យុន យ៉ាត គាត់នៅបន្តគ្រប់គ្រងក្រសួងទាំងពីររហូតដល់ពេលដែលវៀតណាមចូល គឺនៅក្នុងឆ្នាំ១៩៧៩ ដែរឬទេ?

[១០:៤៦:០៨]

**ឆ៖** បាទ ខ្ញុំឃើញថា ការងារនៅពេលនោះ នៅពាក់ព័ន្ធគ្នារហូតបាទ។

**ស៖** លោក វុន យើងបាននិយាយអំពីការផ្ទេរតួនាទីរបស់លោកទៅវិទ្យុកម្ពុជាក្រោម។ ខាងព្រះរាជអាជ្ញាបានចោទសួរមួយ សំណួរមួយចំនួនទៅលើប្រធានបទមួយនេះ។ តើលោកចាំដែរឬទេថាតើគេផ្ទេរលោកនៅឆ្នាំណា? គឺគេផ្ទេរស្ថានីយវិទ្យុកម្ពុជាក្រោមនោះនៅឆ្នាំណា?

**ឆ៖** តាមខ្ញុំចាំនៅឆ្នាំ៧៨។

**ស៖** នៅក្នុងចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ថា

ហើយខ្ញុំសូមដកស្រង់ពីឯកសារ E3/381។ ភាសាអង់គ្លេសគឺមានលេខ 00365526, 00357203 និងភាសាបារាំងគឺមានលេខ 00402996។ ហើយទំព័រដែលយើងមើលគឺ 00365528 ហើយភាសាខ្មែរគឺមានលេខ 00357205។ លោកបាននិយាយថា "បន្ទាប់ពីគេចាប់ប្រពន្ធខ្ញុំនៅចុងឆ្នាំ៧៧ គេផ្ទេរខ្ញុំទៅធ្វើជាប្រធានវិទ្យុកម្ពុជាក្រោម នៅក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនាការ"។ លោកបានជម្រាបយើងថា លោកគិតថា គេបញ្ជូនលោកទៅធ្វើប្រធានវិទ្យុហ្នឹងនៅក្នុងឆ្នាំ៧៨ ហើយនៅក្នុងចម្លើយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយថា វាកើតឡើងក្រោយពេលដែលភរិយារបស់លោកត្រូវបានគេចាប់ខ្លួននៅក្នុងចុងឆ្នាំ៧៧។

[១០:៤៨:៤៣]

វាអាចថានៅក្នុងឆ្នាំ៧៨ ដោយសារតែលោកនិយាយទៅលើចម្លើយ ដែលផ្តល់នៅសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែតើលោកអាចបញ្ជាក់បានដែរឬទេ ថាតើគេផ្ទេរលោកនៅក្នុងឆ្នាំ១៩៧៨ ឬមួយក៏នៅចុងឆ្នាំ១៩៧៧?

**ធ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំទៅពីប្រធានកាសែតទៅ គឺទៅនៅកន្លែងនោះ គឺអត់ទាន់មានមុខងារអីទេ ទៅធ្វើការងារនៅកន្លែងនោះ។ បាននៅក្នុងឆ្នាំ៧៨ បានបង្កើតកម្មវិធីហ្នឹង បានខ្ញុំទៅជាប្រធាននៅកន្លែងនុ៎ងវិញ។ មុនដំបូងនៅធ្វើការងារជាប់នឹងវិទ្យុកម្ពុជាប្រជាធិបតេយ្យ មិនទាន់បែងចែកគ្នាដាច់ស្រឡះទេ។ ដូច្នេះរយៈកាលហ្នឹងវាមានពីរ ពិតមែននៅក្នុងឆ្នាំ៧៧ មែន។ ប៉ុន្តែក្នុង៧៧ ខ្ញុំអត់មាន ទាន់មានមុខងារអីពិតប្រាកទេ។ វាគ្រាន់តែពាក់ព័ន្ធការងារខាងវិទ្យុកម្ពុជាប្រជាធិបតេយ្យ សរសេរ ផ្សៀងកម្មវិធីផង។ ហើយក្រោយមកបានរៀបចំហ្នឹង បានខ្ញុំទៅជាប្រធាននៅឆ្នាំ៧៨ ហ្នឹងឯង។

[១០:៥០:០០]

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។ លោកក៏បានបញ្ជាក់ផងដែរថា វិទ្យុកម្ពុជាក្រោមនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនាការអប់រំ។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរទេ?

**ធ៖** បាទ ត្រឹមត្រូវ។

**ស៖** កាលពីម្សិលមិញ នៅពេលខាងសហព្រះរាជអាជ្ញាបានចោទសួរសំណួរមួយចំនួនអំពីស្ថានីយវិទ្យុកម្ពុជាក្រោមនេះ គឺលោកបាននិយាយដូចតទៅ៖ គឺនៅទំព័រ៣៧ នៃប្រតិចារឹកពង្រាង គឺនៅ

ទំព័រ១៧ ភាសាខ្មែរ ហើយខ្ញុំសូមដកស្រង់នូវចម្លើយដែលសួរ។ “នៅពេលដែលលោកជាប្រធានកម្មវិធីវិទ្យុ ថាតើលោកធ្វើការនៅក្រសួង នៅទីក្រុងភ្នំពេញ ឬក៏នៅទីកន្លែងផ្សេង?” ហើយលោកបានឆ្លើយថា “ខ្ញុំធ្វើការនៅក្រសួងឃោសនាការ ហើយខ្ញុំធ្វើការនៅកន្លែងផ្សេងៗគ្នា នៅកន្លែង -- នៅផ្នែកផ្សេងៗគ្នា”។ ហើយលោកបានបញ្ចប់ចម្លើយរបស់លោកត្រឹមនេះ។ សំណួររបស់ខ្ញុំគឺថា នៅពេលដែលលោកទៅធ្វើការងារនៅវិទ្យុកម្ពុជាក្រោមនោះ តើលោកផ្លាស់ទីកន្លែងធ្វើការទៅអគារថ្មី ឬក៏ផ្នែកថ្មី ឬមួយក៏លោកធ្វើការនៅអគារដដែល?

[១០:៥២:០៣]

**ឆ៖** មុនដំបូង ដូចខ្ញុំបានជម្រាប ដល់ដំណើរការជាប់ទាំងសងខាងអ៊ីចឹង រៀបចំដំណើរការអ៊ីចឹងមិនទាន់បែងចែកច្បាស់ អ៊ីចឹងខ្ញុំត្រូវធ្វើការងារហ្នឹងទាំងសងខាងសិន។ ប៉ុន្តែនៅឆ្នាំ៧៨ ផ្លាស់ប្តូរទីកន្លែងការិយាល័យរៀងខ្លួន។ ប៉ុន្តែស្ថានីយបើកស្ថានីយរួមដដែល។ យើងយកចន្លោះកម្មវិធី ក្នុងផ្សាយភាសាខ្មែរ ភាសាអង់គ្លេស ភាសាយៀកណាមអ៊ីចឹង។ ហើយកម្ពុជាក្រោមនៅក្នុងចន្លោះកម្មវិធីណាមួយដែរ។ ស្ថានីយនៅតែមួយកន្លែងទេ គ្រាន់តែបែកកន្លែងការិយាល័យធ្វើការងារបែងចែក ច្បាស់ជាងមុន អង្កាល់មុននៅជាមួយគ្នា។ ដល់អ៊ីចឹងទៅការងារវាមិនទាន់រៀបរយ។

**សៈ** ដូច្នេះខ្ញុំយល់ថា លោកចង់និយាយថា ការិយាល័យរបស់លោក គឺបែងចែក គឺដាច់ពីគ្នា តើលោកចង់មានន័យថា មានការផ្ទេរមនុស្សផ្សេងៗគ្នាទៅអគារដាច់ៗពីគ្នា តើលោកចង់និយាយបែបនេះមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១០:៥៣:៣៨]

**សៈ** នៅពេលដែលលោកធ្វើការនៅក្នុងអគារនោះ លោកបានចំណាយពេលតិចជាងមុន ប្រសិនបើធៀបជាមួយនឹងការងារដែលលោកធ្វើពីមុននៅក្រសួងឃោសនាការ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**សៈ** ឥឡូវនេះយើងបន្តទៅប្រធានបទថ្មីមួយទៀតលោក គឹម វុន។ ម្សិលមិញគេសួរលោកថា គឺខាងព្រះរាជអាជ្ញាបានសួរលោកអំពីតួនាទីរបស់ នួន ជា នៅមន្ទីរឃោសនាការ។ ឥឡូវនេះខ្ញុំសូមដកស្រង់ពីប្រតិចារឹក គឺទំព័រ៣៦ នៃភាសាអង់គ្លេស គឺប្រតិចារឹកជាភាសាអង់គ្លេស នៅទំព័រ២៩ ជាភាសាខ្មែរនៃពង្រាងប្រតិចារឹក ហើយព្រះរាជអាជ្ញាបានសួរថា៖ “លោកបាននិយាយនៅក្នុងកិច្ចសម្ភាសន៍កាល

ពីមុនថា មានពេលមួយដែល នួន ជា គាត់ទទួលខុសត្រូវខាងឃោសនាការ។ តើវាជាការត្រឹមត្រូវដែរឬទេ?" ហើយលោកបានឆ្លើយថា "តាមពិតទៅតួនាទីជាមេដឹកនាំគឺមិនបាន -- គឺមិនបានច្បាស់លាស់"។ លោក គឹម វុន តើលោកនៅគាំទ្រចម្លើយរបស់លោកដែលថា តួនាទីនៅក្រសួងឃោសនាការ គឺមិនមែនជាតួនាទីរបស់ នួន ជា នោះទេ?

**ឆ៖** បាទ ក្នុងហ្នឹង បើលោកស្រី យុន យ៉ាត អត់នៅឃើញវត្តមានរបស់គាត់។ ប៉ុន្តែក្រោយមកដោយមានកម្មវិធីផ្សាយនាទីអប់រំអំពីកសិកម្មឃើញ គាត់ត្រូវរៀបចំអាហ្នឹង ណែនាំ។

**សៈ** ខ្ញុំនឹងសួរសំណួរលោកបន្ថែមទៀត អំពីកម្មវិធីកសិកម្ម ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកអំពីសំណួរផ្សេងមួយទៀត។ ខ្ញុំបានអាននូវសំណួរដែលគេដាក់ចោទសួរមកលោកដោយខាងព្រះរាជអាជ្ញា ហើយខ្ញុំនឹងអាននូវសំណួរនោះជាថ្មីម្តងទៀត ដើម្បីឲ្យលោកយល់អំពីអ្វីដែលខ្ញុំចង់និយាយ។ ខាងព្រះរាជអាជ្ញាបានសួរលោកថា "លោកក៏បានបញ្ជាក់នូវក្នុងកិច្ចសម្ភាសន៍កាលពេលមុន ដែលថាមានពេលមួយហ្នឹងគឺថា នួន ជា ទទួលខុសត្រូវនៅខាងឃោសនាការ តើត្រឹមត្រូវដែរឬទេ?" ហើយសូមបញ្ចប់នូវការដកស្រង់។ នេះគឺជាសំណួរដែលព្រះរាជអាជ្ញាបានចោទសួរ។ លោក គឹម វុន សំណួររបស់ខ្ញុំដែលចង់សួរនៅថ្ងៃនេះ គឺមានដូចតទៅ៖ តើលោកធ្លាប់ប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែលថា នួន ជា ទទួលខុសត្រូវខាងឃោសនាការទេ?

[១០:៥៧:០៩]

**ឆ៖** ខ្ញុំធ្លាប់និយាយ ប៉ុន្តែក្នុងន័យជំនួសទេ។ ជំនួសលោកស្រី យុន យ៉ាត ពេលដែលគាត់អវត្តមាន។

**សៈ** តើលោកចាំដែរឬទេថា លោកបាននិយាយអំពីតួនាទីរបស់ នួន ជា នៅខាងឃោសនាការនៅពេលដែលគាត់នៅទីនោះ -- នៅពេលដែលគាត់ទៅទីនោះ?

**ឆ៖** ពីមុនខ្ញុំអត់ចាំដែរ ប៉ុន្តែគ្រាន់តែខ្ញុំនៅតែរក្សាដដែលថា គាត់មិនផ្ទាល់នៅទីនោះទេ។ លោកស្រី យុន យ៉ាត ធ្លាប់តែធ្វើការងារក្នុងក្រសួងទាំងពីរនេះ ព្រោះមិនទាន់មានតែងតាំងរដ្ឋមន្ត្រីណានៅដាច់មុខទេ។ អ៊ីចឹងបើអត់ បើអវត្តមានគាត់ គឺលោក នួន ជា ចុះជាប់ទៅកន្លែងនុ៎ង ទៅកន្លែងឃោសនាការ។

[១០:៥៨:៣១]

**សៈ** លោក គឹម វុន តើលោកបានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា នួន ជា ចូលរួមភាគច្រើនក្នុងការអប់រំ ហើយការអប់រំនោះ គឺភាគច្រើនពាក់ព័ន្ធនឹងកសិកម្ម។

តើលោកមានបានប្រាប់បែបនេះទេ?

**ឆ៖** បាទ នាទីអប់រំថ្មី គឺនិយាយពីរឿងកសិកម្មមែន។

**ស៖** កាលពីម្សិលមិញនេះ នៅពេលដែលចៅក្រម ឡាវ៉ែន៍ បានចោទសួរសំណួរដល់លោក លោកបាននិយាយអំពីកម្មវិធីកសិកម្ម គឺកម្មវិធីអប់រំជាដំបូង។ ហើយខ្ញុំសូមដកស្រង់ពីប្រតិចារឹក គឺប្រតិចារឹកកាលពីម្សិលមិញ ទំព័រ៦៩ ភាសាអង់គ្លេស និងទំព័រ៥៥ ភាសាខ្មែរ។ ចៅក្រម ឡាវ៉ែន៍ បានសួរលោកៗថា “ព្រឹកមិញនេះលោកបានប្រាប់ថា លោក នួន ជា មកម្តងម្កាល ថាតើលោកអាចប្រាប់បានដែរឬទេ ថាតើ នួន ជា មកធ្វើអ្វីនៅក្រសួងឃោសនាការអប់រំនោះ?” ហើយចម្លើយរបស់លោកគឺថា “តាមពិតទៅលោក នួន ជា មានតួនាទីមួយនៅក្នុងកម្មវិធីអប់រំ។ គឺកម្មវិធីអប់រំដែលនិយាយអំពីកសិកម្ម”។ ហើយចុះនៅក្រោមបន្តិចចៅក្រម ឡាវ៉ែន៍ បានសួរលោក ហើយខ្ញុំសូមដកស្រង់៖ “តើគាត់ជំនួសលោកស្រី យុន យ៉ាត ឬមួយក៏មកជួយលោកស្រី យុន យ៉ាត?”។ ហើយចម្លើយរបស់លោកគឺថា “កម្មវិធីជាមូលដ្ឋានរបស់គាត់ គឺកម្មវិធីអប់រំកសិកម្ម។ ប៉ុន្តែខ្ញុំមិនដឹងថាតើគាត់ចូលរួមពាក់ព័ន្ធនៅក្នុងផ្នែកអក្សរ ឬក៏អត់នោះទេ។ ព្រោះគេផ្ទេរខ្ញុំទៅខាងវិទ្យុកម្ពុជាក្រោមហើយ នៅពេលដែលគេឲ្យលោក នួន ជា មកកាន់នៅខាងឃោសនាការនោះ” ខ្ញុំសូមបញ្ចប់ការដកស្រង់។ ដូច្នេះកាលពីម្សិលមិញលោកបានជម្រាបថា កម្មវិធីជាមូលដ្ឋានរបស់ នួន ជា គឺការអប់រំអំពីកសិកម្ម ហើយលោកមិនដឹងថាតើគាត់ចូលរួមពាក់ព័ន្ធទៅក្នុងការងារផ្សេងៗទៀត ឬក៏អត់នោះទេ។ ព្រោះថា ដោយសារតែគេផ្ទេរលោកទៅខាងវិទ្យុកម្ពុជាក្រោម។ លោកសាក្សី អ្វីដែលខ្ញុំចង់សួរគឺថាតើជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយថាលោកមិនដឹងអំពីតួនាទីផ្សេងៗរបស់លោក នួន ជា ដោយសារតែគេផ្ទេរលោកទៅអគារមួយផ្សេងមួយទៀត ឬក៏ដោយសារតែលោកចំណាយពេលវេលាច្រើនទៅលើការងារផ្សេង?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:០២:០៧]

**ស៖** លោក គឹម វុន។ លោកបានបញ្ជាក់កាលពីម្សិលមិញថា នៅពេលដែលចៅក្រម ឡាវ៉ែន៍ បានសួរលោក គឺលោកបានបញ្ជាក់ថា “នួន ជា ចូលរួមនៅក្នុងផ្នែកអប់រំពាក់ព័ន្ធទៅនឹងការអប់រំលើកសិកម្ម”។ លោកក៏បាននិយាយបន្តិចបន្តួចផងដែរ អ្វីដែលលោកចាំអំពីកម្មវិធីកសិកម្ម។ ក៏ប៉ុន្តែប្រតិចារឹកជាភាសាអង់គ្លេសមិនបានបង្ហាញឲ្យបានច្បាស់លាស់ដូចទៅនឹងភាសាខ្មែរ។ ដើម្បីជាប្រយោជន៍សម្រាប់ភាគីទាំងអស់នោះ តើលោកអាចជម្រាបយើងខ្ញុំបន្ថែមបន្តិចទៀតបានដែរឬទេ អំពីកម្មវិធី

កសិកម្មដែល នួន ជា បានចូលរួមក្នុងការធ្វើការងារកម្មវិធីកសិកម្មនេះនោះ?

**ឆ៖** ការពិតទៅ នាទីអប់រំផ្នែកកសិកម្មនេះ គឺមានសៀវភៅស្រេចហើយ។ សៀវភៅហ្នឹងបោះពុម្ពក្បាលក្រាស់ ដូច្នេះត្រូវដកស្រង់បន្តិចម្តងៗយកមកផ្សាយ។ ដូច្នេះទាល់តែមានអ្នកចម្លងចេញជាអត្ថបទសម្រាប់ឱ្យគេអាន ដើម្បីថតបញ្ចូលក្នុងកាសែតដើម្បីផ្សាយ។ ហើយប្រភពដែលបានសៀវភៅហ្នឹងមក គឺនៅកន្លែងមន្ទីរពិសោធន៍កសិកម្មនៅមេច្បារ ខេត្តបាត់ដំបង ដែលអ្នកបច្ចេកទេសចិនគេបង្កាត់ពូជស្រូវ ឬក៏ធ្វើស្រែពិសោធន៍នៅកន្លែងនោះ យកមកផ្សព្វផ្សាយពីព្រោះវាមានបទពិសោធន៍ល្អៗ។

[១១:០៤:២៥]

**ស៖** លោក គឹម វុន។ នៅក្នុងចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត លោកហាក់ដូចជាពុំបានឆ្លើយថា "ការអប់រំរបស់ នួន ជា នោះគឺផ្តោតជាសំខាន់ទៅលើការអប់រំផ្នែកកសិកម្មនោះទេ"។ តាមពិតទៅពាក្យ "កសិកម្ម" នោះមិនបានឆ្លើយនៅក្នុងចម្លើយដែលលោកបានឆ្លើយនៅមុខអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតនោះឡើយ ដែលជាចម្លើយលោកបានផ្តិតមេដៃ ចុះហត្ថលេខា ហើយលោកគិតបញ្ជាក់ថា វាជាចម្លើយមួយការពិត។ តើលោកដឹងទេ ហេតុអ្វីបានជាលោកមិនបាននិយាយ និងឆ្លើយអំពីការអប់រំរបស់ នួន ជា ដែលផ្តោតសំខាន់ទៅលើកសិកម្មនោះ ដែលលោកជាចម្លើយមួយ លោកឆ្លើយទៅលោកចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** ខ្ញុំមិនចាំ ប្រហែលជាខ្ញុំ គេមិនបានសួរពីរឿងហ្នឹង ខ្ញុំអត់បានឆ្លើយ។ បើសួរពីរឿងថាគាត់អប់រំអីទៅ ប៉ុន្តែដល់សួរក្រោយ មានប្រធានបទមួយថ្មី និយាយពីរឿងការអប់រំ។ ការអប់រំនូវកម្មវិធីផ្សាយវិទ្យុកាលហ្នឹង ខ្ញុំចាំ មានតែផ្សាយកម្មវិធីអប់រំកសិកម្មហ្នឹងឯង នៅមេច្បារហ្នឹង។ ព្រោះអង្កាល់មុន អ្នកស៊ើបអង្កេត គេមិនសួរលម្អិតអីដល់រឿងហ្នឹង ដូច្នេះ ខ្ញុំមិនទាន់និយាយ។ ហើយពេលនេះគេសួរពីរឿងហ្នឹង ខ្ញុំអាចនិយាយពីរឿងហ្នឹង ព្រោះគេសួរអំពីថាតើតួនាទីរបស់លោក នួន ជា នៅក្នុងក្រសួងឃោសនាការហ្នឹងយ៉ាងម៉េច? អ៊ីចឹង ខ្ញុំក៏យកផ្នែកអប់រំហ្នឹង ដើម្បីធ្វើជាភស្តុតាង ថាជាការងាររបស់គាត់ដែលត្រូវសម្របសម្រួលការផ្សាយហ្នឹងដែរ។

[១១:០៦:៥០]

**ស៖** ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នា ដើម្បីចៀសវាងការយល់ច្រឡំទាំងអស់គ្នា។ តើលោកចាំដែរឬទេ ថាលោកបានលើកឡើងអំពីការអប់រំលើបញ្ហាកសិកម្មនេះ ដែលលោកបានឆ្លើយ

ជូនអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតនោះ តើលោកចាំទេ លោកបានឆ្លើយដូច្នេះ?

**ឆ៖** ខ្ញុំដូចភ្លេចភ្លាំង មិនដឹងសួរៗនៅពេលណា។

**ស៖** សូមអធ្យាស្រ័យ វាមិនបានច្បាស់។ ដូច្នេះខ្ញុំសួរឲ្យមានលក្ខណៈងាយៗចំពោះលោកវិញ។ តើលោកចាំទេ ថាលោកបានប្រាប់អ្នកស៊ើបអង្កេតថា នួន ជា បានចូលរួមការអប់រំពាក់ព័ន្ធនឹងផ្នែកកសិកម្មនោះ?

**ឆ៖** នៅក្នុងទីនេះ ខ្ញុំពិតជាបាននិយាយអ៊ីចឹងមែន។ ព្រោះសំណួរហ្នឹង ពាក់ព័ន្ធថា នឹងគាត់ថាតើមានតួនាទីដែលគាត់ទៅកន្លែងឃោសនាការនោះ? អ៊ីចឹង ខ្ញុំបានឆ្លើយហើយថា ដែលគាត់ទៅហ្នឹងគឺមាននាទីអប់រំថ្មី ខាងផ្នែកកសិកម្ម នៅមេច្បារហ្នឹងឯង។

[១១:០៨:៣៩]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ លោក គឹម វុន។ ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ ដើម្បីជាប្រតិចារឹកនោះ គឺយើងឃើញថា បញ្ហាការអប់រំកសិកម្មនេះ មិនបានលើកឡើងនៅក្នុងកំណត់ហេតុដែលអ្នកស៊ើបអង្កេតបានសួរលោកនោះទេ។ នៅក្នុងថ្ងៃនេះ ខ្ញុំសូមថ្លែងអំណរគុណលោកសាជាថ្មីម្តងទៀត។ ហើយក្នុងនាមអ្នកការពារក្តីរបស់ នួន ជា ខ្ញុំជូនពរឲ្យលោកមានសុខភាពល្អ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាស តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមានសំណួរ។

បាទ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន អស់លោក លោកស្រី -- លោក លោកស្រីនៅក្នុងបន្ទប់ និងក្រៅបន្ទាប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

អរគុណសួស្តីលោកសាក្សី ខ្ញុំ ម៉ៃខល កាណាវាស ជាមួយនឹងលោក អាង ឧត្តម តំណាងលោក អៀង សារី។ ខ្ញុំមានសំណួរមួយចំនួនតូចតែប៉ុណ្ណោះ ភាគច្រើននោះ គឺឲ្យលោកបញ្ជាក់បំភ្លឺបន្ថែម

មិនច្រើនលើសពី១៥នាទីទេ ចំពោះការសួរសំណួររបស់ខ្ញុំ។

**ស៖** សំណួរដំបូងរបស់ខ្ញុំគឺ ពាក់ព័ន្ធទៅនឹងចម្លើយលើកទី២របស់លោក ដែលលោកបានផ្ដល់ជូនអ្នកស៊ើបអង្កេតនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ គឺឯកសារលេខ E3/381 ទំព័រ៤ ជាភាសាអង់គ្លេស។ ខ្មែរ ERN គឺ 00357206 ទៅដល់ 07, បារាំង 00402998 ទៅដល់ 999, អង់គ្លេសគឺ 00365229។ នៅក្នុងចម្លើយលើកទី២របស់លោកនេះ មានការសួរសំណួរសួរទៅកាន់លោក ដូច្នេះ ខ្ញុំសូមសួរបញ្ជាក់បំភ្លឺ។ គេសួរលោកថា លោកបានលើកឡើងថា៖ "ត្រាក់នោះ បានរៀបចំឡើងមុនពេលចាប់ខ្លួន សោ ភឹម។ តើត្រាក់នោះបោះពុម្ពនៅឯណា?" យើងបានស្ដាប់ការសម្ភាសដែលលោកបានឆ្លើយមានរយៈពេលពេល ៤៨:៣១នាទី ហើយវាជាឯកសារសង្ខេបនៃការស្ដាប់ចម្លើយរបស់លោកដែលមានរយៈពេលសរុបជាង២ម៉ោង -- ជិត២ម៉ោង។ ក៏ប៉ុន្តែមិនមាននៅក្នុងខ្សែអាត់ដែលលោកបានលើកឡើងអំពីត្រាក់នោះទេ។ ដូច្នេះ ខ្ញុំសូមសួរលោក តើលោកលើកឡើងឆ្លើយអំពីការបោះពុម្ពត្រាក់នេះលើកដំបូងនោះនៅពេលណាដែរ ដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ?

[១១:១២:១៥]

**លោក គឹម វុន៖**

**ឆ៖** ពេលយូរដែរ មកដល់ពេលនេះ ខ្ញុំដូចជាភ្លេចភ្លាំង។ ប៉ុន្តែខ្ញុំនឹកឃើញថា ដូចជាខ្ញុំបាននិយាយពីរឿងត្រាក់ហ្នឹងដែរ។ ប៉ុន្តែនៅពេលណា ខ្ញុំមិនចាំថ្ងៃខែ។

**ស៖** សូមអរគុណច្រើន។ នៅពេលនេះ ប្រសិនយើងមើលចម្លើយមួយទៀតរបស់លោក គឺ E3/380 វិញ យើងឃើញថាចម្លើយមួយនេះចាប់ផ្ដើមនៅម៉ោងប្រាំបីហាសិបនាពេលព្រឹក និងបញ្ចប់នៅម៉ោងពីរសាមសិបនាទី។ ដូច្នេះ ប្រហែលជាប្រាំម៉ោង។ ខ្សែអាត់នៃការថតសំឡេងនោះ គឺមាន២ម៉ោង ចុច៤៧នាទី ២២សីហ្គុង វិនាទី។ ខ្ញុំសូមសួរលោកអំពីចម្លើយទាំងពីរ ដែលលោកបានឆ្លើយនោះ តើការសន្ទនាដែលលោកបានធ្វើឡើងជាមួយនឹងធ្វើស៊ើបអង្កេតនោះ គឺបានន័យថា គេសួរលោក ហើយឱ្យលោកឆ្លើយមុនពេលដែលគេថតខ្សែអាត់ ឬក៏គេសួរឆ្លើយហើយ គេថតខ្សែអាត់តែម្ដង?

[១១:១៣:៤៤]

**ឆ៖** ខ្ញុំអត់ដឹងខាងបច្ចេកទេសគេធ្វើយ៉ាងម៉េចផង ព្រោះចាប់អារម្មណ៍តែគេសួរ។ ដូច្នេះ ខ្ញុំចេះតែនិយាយទៅតាមខ្ញុំដឹងខ្លះ ឯការថតមាននៅក្នុងឯកសារ ឬនៅក្នុងពេលណាអី ខ្ញុំមកដល់ពេលនេះ ខ្ញុំអត់

ចាប់អារម្មណ៍ថាយ៉ាងណាទេ។

**ស៖** សូមអរគុណ។ ដោយសារតែការស្ដាប់ចម្លើយនេះ គឺចាប់ផ្ដើមនៅម៉ោងប្រាំបីហាសិប ហើយបញ្ចប់នៅម៉ោងដប់ពីរសាមសិបនាទី។ ឯកសារ E3/380 មិនបង្ហាញថាមានការឈប់សម្រាក ក្នុងពេលដែលស្ដាប់ចម្លើយនោះឡើយ។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើការសួរនោះ គឺចាប់ផ្ដើមពីពេលដែលគេជួបលោកនៅម៉ោងប្រាំបីហាសិប ហើយសួរឆ្លើយៗ រហូតទៅដល់ម៉ោងដប់ពីរសាមសិននាទីថ្ងៃត្រង់ ដូចដែលគេបង្ហាញនៅក្នុងសេចក្ដីសង្ខេបចម្លើយនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនច្បាស់ដែរ មិនដឹងជាការថត និងការសរសេរនៅលើឯកសារយ៉ាងម៉េច។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងចម្លើយនេះ តើមាននៅពេលណាមួយដែលគេប្រាប់ថា នៅពេលនេះគេចាប់ផ្ដើមថតខ្សែអាត់ហើយ ឬក៏លោកសន្មតខ្លួនឯងថា គេថតនៅពេលព្រឹក ដែលគេចាប់ផ្ដើមសម្ភាសលោកតែម្ដង។ តើលោកនឹកឃើញទេ?

[១១:១៥:៤៦]

**ឆ៖** បាទ ប្រហែលជាអ៊ីចឹងមែន ព្រោះខ្ញុំមិនយល់ពីបច្ចេកទេសគេថត។ ហើយម៉ាស៊ីនហ្នឹងខ្ញុំមិនដែលប្រើដែរ អ៊ីចឹងចេះតែនិយាយទៅតាមគេសួរទៅ។

**ស៖** សំណួរចុងក្រោយចំពោះការសម្ភាសទាំងពីរ។ ក្នុងពេលសម្ភាសស្ដាប់ចម្លើយនោះ តើគេមានចែកឯកសារឲ្យលោក ឲ្យលោកពិនិត្យមើលដែរឬទេ ដើម្បីឲ្យលោកនឹកឃើញឡើងវិញ នូវហេតុការណ៍ទាំងឡាយ។ តើចាំថា គេមានធ្វើអ៊ីចឹងទេ?

**ឆ៖** នៅពេលនោះអាចមានចែកឯកសារមកឲ្យខ្ញុំ ជួនកាលដល់ធ្វើយូរពេកឯកសារច្រើនអ៊ីចឹង សួរឆ្លើយហត់ហេវពេក ខ្ញុំមិនបានត្រួតពិនិត្យមើលទាំងអស់ទេ។ ប៉ុន្តែក្រោយមក ខ្ញុំឃើញមួយកន្លែងទាក់ទងនឹងឈ្មោះមនុស្ស ធ្វើការនៅកន្លែងមន្ទីរឃោសនាអប់រំ ខ្ញុំសូមកែថា មិនមែនជាកម្មាភិបាលទេ។ ឈ្មោះនារីម្នាក់ហ្នឹងគឺជា អ្នកធ្វើការធម្មតា ហើយក្រៅពីនោះខ្ញុំដូចមិនបានចាប់អារម្មណ៍រឿងកែមើលឲ្យបានគ្រប់ជ្រុងជ្រោយទេ ព្រោះពេលប្រញាប់ហើយ ជួនកាលគាត់បង្ខំធ្វើលើសម៉ោងច្រើនម៉ោងអ៊ីចឹងទៅហត់ហេវមែនទែន។

**ស៖** មានសំណួរមួយទៀត ដើម្បីសួរបន្តលើសំណួរនេះ។ នៅពេលដែលលោកនិយាយថា លោកមិនចាំនោះ បានន័យថា នៅពេលនោះគឺលោកមិននឹកឃើញថា គេបានផ្ដល់ឯកសារឲ្យលោក ដើម្បីឲ្យលោកនឹកឃើញហេតុការណ៍ទាំងឡាយដែលបានកើតឡើងពីមុនទេ ឬក៏យ៉ាងម៉េច?

[១១:១៧:៤២]

**ឆៈ** ជាធម្មតា គេឲ្យច្បាប់ -- មួយច្បាប់មកយើងដែរ។ ប៉ុន្តែមិនបានត្រួតពិនិត្យមើលអីទេ នឹកឃើញថា បើនិយាយហើយចប់។ មិនបានត្រួតពិនិត្យមើលទាំងអស់ទេ។

**សៈ** សូមអរគុណ។ នៅពេលនេះ ខ្ញុំចូលទៅដល់ប្រធានបទចុងក្រោយ ដែលខ្ញុំចង់សួរ។ គេបានសួរលោក នៅពេលដែលលោកចូលមកដល់ទីនេះលើកដំបូង គឺលោកប្រធានបានសួរលោកថាតើមានកិច្ចសម្ភាសន៍នោះពីរ ឬក៏បីដង។ ខ្ញុំសូមសួរបញ្ជាក់ត្រង់ចំណុចនេះ ដោយសារតែយើងមានចម្លើយការស្តាប់ចម្លើយចំនួនពីរ ក៏ប៉ុន្តែភាសាខ្មែរត្រង់ទំព័រ៣៤ ទៅដល់៣៥ ហើយអង់គ្លេស៤០ទៅដល់៤១ បារាំង គឺពីទំព័រ៤៥ដល់៤៦ ប្រតិចារឹកថ្ងៃទី២១ ខែសីហា។ លោកបានឆ្លើយថា "លោកបានផ្តល់ការសម្ភាសនេះបីដង ក៏ប៉ុន្តែមានឯកសារកត់ត្រាផ្លូវការតែពីរទេ ដែលបានកត់ត្រាការសម្ភាសន៍របស់ខ្ញុំ"។ ហើយនៅខាងក្រោមលោកបាននិយាយថា "នៅលើកទី៣ លោកបានចូលរួមសិក្ខាសាលារៀបចំផែនការ ហើយអ្នកស៊ើបអង្កេត គឺមិនអាចចាំយើងបានទេ។ ដូច្នេះហើយគាត់ត្រូវប្រញាប់មកធ្វើការងារនៅកន្លែងផ្សេងវិញ"។ ខ្ញុំចង់ឲ្យយើងយល់ទាំងអស់គ្នា តើលោកបានជួបអ្នកស៊ើបអង្កេតបីដង ហើយមានការសម្ភាសន៍តែពីរដង ឬក៏លោកបាន ត្រូវបានគេសម្ភាសនោះដល់ទៅបីដង?

**ឆៈ** ដូចខ្ញុំជម្រាបពីខាងដើមហើយ គឺបីដង។ ប៉ុន្តែក្រោយមកអត់មានឯកសារនៅខ្ញុំ។

**សៈ** ខ្ញុំសូមសួរបញ្ជាក់លោក ត្រង់ការសម្ភាសលើកទី៣នេះ។ តើនៅការសម្ភាសលើកទី៣ នេះគេមានសួរសំណួរលោក ហើយលោកឆ្លើយទៅវិញដែរឬទេ? ហើយដែលការស្តាប់ចម្លើយការសម្ភាសលើកទី៣ នេះគឺគេមិនបានផ្តល់ឯកសារទៅដល់លោក បើសិនជាតាមការចងចាំរបស់លោកនោះ។

[១១:២០:២៣]

**ឆៈ** នៅលើកទី៣ នេះខ្ញុំមិនលាក់លៀមអីទេ ដូចមានការចម្រូងចម្រាសខ្លះដែរ។ វាជាប់ពាក់ព័ន្ធនឹងរឿងខ្ញុំរវល់ ហើយគាត់ពេលហ្នឹងដែរ។ ដូច្នេះរវាងការរដ្ឋ និងការងារតុលាការហ្នឹង ការងាររបស់អង្គការសហប្រជាជាតិ តើខ្ញុំមិនដឹងយកមួយណាទេ ព្រោះចាំបាច់ដូចគ្នា។ ហើយខ្ញុំបានឲ្យគាត់ចាំបន្តិច ប៉ុន្តែខាងក្រុមគាត់អត់បានចាំខ្ញុំអ៊ីចឹង មកពីការអត់ចិត្តរបស់អ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតជាជនបរទេស ដែលខ្ញុំថាឲ្យគាត់មិនដឹង ឬក៏គាត់ខឹងនឹងខ្ញុំក៏មិនដឹង។ ព្រោះខ្ញុំនិយាយច្រើនដែរ និយាយអត់សូវត្រូវគ្នា ហើយគាត់ប្រមាថចាប់ខ្ញុំមកភ្នំពេញ។ ដល់អ៊ីចឹង គាត់និយាយជាភាសាអង់គ្លេសទេ ប៉ុន្តែស្តាប់ទៅវាបានខ្លះអ៊ីចឹង ក៏ -- អាហ្នឹងជាបច្ចេកទេសរបស់គាត់ទេ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំថាមកចាប់ខ្ញុំអី ខ្ញុំមាន

ឧក្រិដ្ឋជនណាទៅធ្វើអីខុស បើគ្រាន់មកសហការជាមួយខ្ញុំ ដើម្បីសុំព័ត៌មាន សុំសម្ភាសពីខ្ញុំហ្នឹង។ ហ្នឹងសូមអង្គតុលាការជួយ ប៉ុន្តែខ្ញុំមិនដឹងថា អស់លោកហ្នឹងជាជនជាតិអីទេ។ ប៉ុន្តែខ្ញុំ ខ្ញុំស្តីឲ្យដែរ ខ្ញុំមិនទៅខ្លាចអី មកចាប់អីខ្ញុំ បើសហការជាមួយខ្ញុំវាត្រឹមត្រូវ បើថាលោកមកចាប់បង្ខំខ្ញុំ មានអីត្រូវចាប់។

[១១:២១:៥៥]

ដល់អ៊ីចឹងទៅ គាត់និយាយថា សម្រួលមកវិញ ថាគាត់និយាយលេងហ្នឹង។ ដូច្នេះការងារតុលាការមិនមែនជាការងារលេងសើចទេ ខ្ញុំថាអ៊ីចឹង។ អាចជាមូលហេតុហ្នឹងដឹងបានតែខ្ញុំអត់បានផ្ចិតមេដៃ ឬក៏អីៗទេ។ ហើយមិនដឹងនៅក្នុងចំណោមហ្នឹង មិនដឹងថាអស់លោកណាមួយទេ ប៉ុន្តែខ្ញុំថាជាជនបរទេស។ ហើយក្រុមហ្នឹងមិនដឹងជាក្រុមណា បើវាភ្លេចដែរ ប៉ុន្តែបីដង។ លើកចុងក្រោយខ្ញុំថា បើខ្ញុំឲ្យមកមួយស្តុកហ្នឹងហើយ លោកចង់ស្តុកផ្សេងទៀត ស្តុកក្រោយហ្នឹងវាដូចតែស្តុកមុនទេ ខ្ញុំអត់មានចំណីអីលើសពីហ្នឹងទេ។

**ស៖** សូមអរគុណច្រើន។ នៅពេលនេះគឺខ្ញុំសូមឲ្យលោកបញ្ជាក់ចំណុចមួយចំនួនទៀត អ្វីដែលលោកបានឆ្លើយប្រាប់យើងនៅពេលនេះ។ នៅពេលដែលអ្នកស៊ើបអង្កេតអន្តរជាតិរបស់ខាងសហចៅក្រមស៊ើបអង្កេតនេះ បានគំរាមកំហែង គឺគេបានគំរាមកំហែងលោកនៅពេលធ្វើសម្ភាសលើកទី២ ឬក៏នៅពេលសម្ភាសលើកទី៣?

**ឆ៖** សម្ភាសលើកទី៣ ហើយមិនមែនអ្នកទៅសម្ភាសខ្ញុំមុនទេ។

**ស៖** សូមអរគុណ។ តើអ្នកសម្ភាសលោក អ្នកស៊ើបអង្កេតលោកអន្តរជាតិមុនៗនោះ តើមានការខ្វាស់សម្តី ខ្វែងសម្តីគ្នា មិនត្រូវគ្នាដែរឬទេ?

[១១:២៣:៥៧]

**ឆ៖** ការសម្របសម្រួលមានភាពរលូនណាស់ គាត់មិនដែលប្រើពាក្យអីអសុរោះទេ។ ហើយខ្ញុំចាំថា មានអ្នកនោះគេជនជាតិស្បែកខ្មៅ ប៉ុន្តែមិនដឹងជាអាមេរិក ឬសាសន៍ណាទេ ប៉ុន្តែខ្ញុំដឹងថាមានម្នាក់ជាជនជាតិខ្មែរខ្មៅ។ ប៉ុន្តែអស់លោកមុនពីរដងហ្នឹងអត់មានបញ្ហាទីទេ តែលោកក្រោយហ្នឹងតែម្តងខ្ញុំមិនដឹងគាត់ជនជាតិអីដែរ ខ្ញុំមិនស្តាប់ -- មិនបាន។

**ស៖** សូមអរគុណ។ នៅពេលដែលសម្ភាសលើកទី៣ លោកមានការសន្ទនាខ្លះ។ ក៏ប៉ុន្តែនៅពេលនោះ តើលោកមានបានឆ្លើយទៅនឹងសំណួរជាក់លាក់ណាដែលគេសួរដែរឬទេ? ឬក៏អត់មានការជួបសម្ភាសទេ ដោយសារតែនៅពេលនោះ គឺលោកមានការរវល់ធ្វើការងារផ្ទាល់របស់លោក?

**ឆៈ** បាទ ការងារនៅពេលនោះខ្ញុំរវល់មែន។ ហើយសុំណាត់គាត់ថា អាច -- វាខុសថ្ងៃទេ មែនទែនវាមិនត្រូវថ្ងៃធ្វើការ។ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យហ្នឹងលោកអាចផ្លៀតបានទេបើខ្ញុំរវល់អ៊ីចឹង? ហើយគាត់ថា មិនបាន។ ដល់អ៊ីចឹង--

**សៈ** លោកសាក្សី ខ្ញុំសូមកាត់ចម្លើយរបស់លោក ខ្ញុំសួរសំណួរសាមញ្ញមួយដល់លោក។ តើអ្នកស៊ើបអង្កេតមានសួរសំណួរជាក់លាក់ណាមួយ គេសួរលើហេតុការណ៍ណាមួយជាក់លាក់ ហើយលោកបានឆ្លើយទៅនឹងសំណួរទាំងអស់នោះដែរឬទេ? បានន័យថា តើគេមានសួរសម្ភាសលោក ហើយសួរសំណួរជាក់លាក់ឱ្យលោកឆ្លើយដែរឬទេ?

**ឆៈ** មែនទែន ពេលនោះមានទាំងកំណត់ហេតុ ធ្វើកំណត់ហេតុហើយ ប៉ុន្តែគ្រាន់អត់បានសួរខ្ញុំអត់នៅចាំខ្ញុំ ព្រោះខ្ញុំនៅសល់ -- អាចបិទនៅម៉ោងពីរជាងអ៊ីចឹង -- អ៊ូនែ៎! នៅម៉ោងដប់ពីរជាងអ៊ីចឹងទៅគាត់អត់រង់ចាំ គាត់ចេញដំណើរទៅ។

[១១:២៦:១០]

**សៈ** សូមអរគុណ។ ចំណុចចុងក្រោយ ខ្ញុំចង់សួរអំពីការសម្ភាសលើកទី៣នេះ។ ខ្ញុំចង់ឱ្យលោកផ្តល់យោបល់លើឯកសារលេខ D243/4 ថ្ងៃ១៣ ខែមករា ឆ្នាំ២០១០ ដែលជាដីកាបង្គាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍។ នៅត្រង់ទំព័រចុងក្រោយជាភាសាអង់គ្លេស ទំព័រទី៤នោះ ហើយខ្មែរគឺ 00439922, បារាំងគឺ 00485281, អង់គ្លេសគឺ 00429022។ ចៅក្រម ឡឺម៉ុងដ៍ បាននិយាយសរសេរនៅក្នុងនេះដូចតទៅ ក្នុងកថាខណ្ឌ១១ ប្រយោគចុងក្រោយ “នៅខែតុលា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានជួប គឹម វុន ប្រយោជន៍ដើម្បីស្តាប់ចម្លើយគាត់ជាលើកទី៣ ដើម្បីវិភាគបញ្ហាដែលលើកឡើងក្នុងសំណើរបស់សហព្រះរាជអាជ្ញា។ ប៉ុន្តែទោះបីមានសម្ភាសជាមួយគាត់បានពីរដងមុននេះរួចហើយក្តី ក៏មកដល់ដំណាក់កាលនេះ ស្រាប់តែសាក្សីរូបនេះលែងសហការទាំងស្រុង ហើយបដិសេធដាច់អហង្ការមិនឱ្យសម្ភាសគាត់តទៅទៀតទេ។ ដូច្នេះយើងក៏មិនអាចសម្ភាសគាត់បានទៀតដែរ”។

នៅពេលនេះគឺថាគេ -- គេកំណត់នៅពេលគេទៅសម្ភាសលោកលើកទី៣នេះ គេថាលោកនេះលែងសហការទាំងស្រុង ហើយបដិសេធដាច់អហង្ការមិនឱ្យសម្ភាសលោក។ តើចំណុចនេះវាត្រូវទេទៅនឹងហេតុការណ៍ដែលលោកបាន -- ដែលកើតឡើងចំពោះលោកនៅពេលនោះ? ហើយតើវាជាការលើកឡើងត្រឹមត្រូវដែរឬទេ?

[១១:២៨:៣៧]

**ឆ៖** ហេតុការណ៍ដូចខ្ញុំបានលើកហើយ បើគាត់សហការនឹងខ្ញុំមានវិធីស្រួលបួលប្រកបដោយសីលធម៌អត់អីទេ។ ប៉ុន្តែវិជ្ជាជីវៈបែបហ្នឹងខ្ញុំទទួលយកវាអត់បាន បើគាត់ប្រើវាពាក្យអសុរោះអ៊ីចឹង។ ប៉ុន្តែគាត់និយាយថាខ្ញុំមិនសហការគឺនិយាយអត់ អត់ទទួលខុសត្រូវ។ ព្រោះមន្ត្រីការងាររបស់រដ្ឋាភិបាលការងារសហប្រជាជាតិប៉ុនណាណី មន្ទីរខ្ញុំមួយណាដែលមិនសហការ? ប៉ុន្តែគាត់ចេញដំណើរទៅមិនរង់ចាំខ្ញុំគ្រាន់ពេលប៉ុន្មាននាទី គាត់មិនសហការជាមួយខ្ញុំផងហ្នឹង ហើយខ្ញុំណែនាំទៀតថា នៅក្នុងតុលាការហ្នឹង មានទាំងខ្មែរ មានបរទេស។ អ៊ីចឹងសូមឲ្យលោកខាងខ្មែរហ្នឹងខំសួរឲ្យបានច្រើនទៅ កុំចាំតែបកប្រែតាមគេ។ អាហ្នឹងជាសំណូមពររបស់ខ្ញុំទេ។

ហើយមកចោទប្រកាន់ខ្ញុំមិនសហការអីហ្នឹង អាហ្នឹងមកឲ្យមានកំហឹង ទំនាស់គ្នាជាមួយអង្គភាពមួយរបស់រដ្ឋ។ ទៅចោទប្រកាន់អ៊ីចឹងវាមិនសមហេតុផលទេអាហ្នឹង។ ហើយខ្ញុំមានអំណាចអី មានសិទ្ធិអីដែលប្រឆាំងនឹងតុលាការ ដែលមានខ្មែរនិងបរទេសរួមគ្នាបង្កើតបានដល់ថ្ងៃនេះ។ អាហ្នឹងមកពីគាត់អគតិ ចំពោះខ្ញុំដែលៗរឿងហ្នឹងហើយ បានជាចោទប្រកាន់ថា ខ្ញុំមិនសហការ។ អ៊ីចឹងអត្ថបទនេះ ខ្ញុំអត់ទទួលស្គាល់ទេ ខ្ញុំមិនបានទទួលផ្តិតមេដៃអីណា បើគាត់មិននៅចាំខ្ញុំផងហ្នឹង។ អ៊ីចឹងបានន័យថា គាត់តក់ក្រហល់អន់ចិត្តជាមួយខ្ញុំហើយ ព្រោះអី? ព្រោះតែពាក្យពេចន៍អសីលធម៌ហ្នឹងហើយដែលៗវានាំឲ្យមានបញ្ហាហ្នឹង។ ហើយដល់ធ្វើឯកសាររួចហើយ គ្រាន់តែរង់ចាំបន្តិច គាត់មិននៅរង់ចាំហើយមកចោទប្រកាន់ខ្ញុំថា មិនសហការ។

**ប្រធានអង្គជំនុំ៖**

បានហើយ សូមអញ្ជើញបន្តសំណួរ ផ្សេងទៀតលោកមេធាវី! សំណួរនេះ ជាកិច្ចការពាក់ព័ន្ធទៅនឹងកិច្ចដំណើរការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតទេ។ ហើយការដែលចេញនូវដីកាដំណោះស្រាយគឺកិច្ចការអស់នេះ គឺចប់សព្វគ្រប់អស់ហើយ មិនមានបញ្ហាអីទៀតទេ។

[១១:៣១:០២]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់បញ្ហាពាក់ព័ន្ធទៅនឹងការលើកឡើងចំពោះសាក្សីនេះ នៅក្នុងសេចក្តីសង្ខេប។ លោកសាក្សី ខ្ញុំមិនមានសំណួរទៀតទេ ក្នុងនាមមេធាវីការពារក្តី អៀង សារី ជាមួយនឹងលោក អាង ឧត្តម នោះខ្ញុំសូមថ្លែងអំណរគុណលោក ដែលលោកមកផ្តល់សក្ខីកម្ម

នៅទីនេះ ហើយសូមជូនពរលោកឲ្យមានសំណាងល្អ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី លោក គឹម វុន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់សព្វគ្រប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោកដែលបានធ្វើដំណើរមកពីទីឆ្ងាយ ហើយនិងចំណាយពេលវេលាជាច្រើនថ្ងៃដ៏មានតម្លៃ អញ្ជើញចូលរួម និងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះប៉ុន្មានថ្ងៃកន្លងមកនេះ ដោយមានភាពអំណត់អត់ធ្មត់ ហើយនិងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិត នៅក្នុងរឿងក្តីនេះ។ សូមជួបតែសំណាងល្អ និងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១១:៣២:២០]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនិងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងជូនសាក្សីនេះវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ឬក៏កន្លែងជាគោលដៅដែលគាត់ចង់ទៅ មានបំណងទៅបានហើយ។

លោក គឹម វុន លោកអាចចាកចេញត្រឡប់ទៅវិញបានហើយនាពេលនេះ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១១:៣៣:១៩]

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តនេះ គឺចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី TCCP-28 ដែលនឹងសួរដេញដោលដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀត បន្ទាប់ពីសំណួរបឋមរបស់អង្គជំនុំជម្រះ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-28 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

លោកស្រី សែ កុលវុឌ្ឍី ទៅអញ្ជើញសាក្សី អ៎! ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ!

[១១:៣៥:៣០]

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

[១១:៣៦:៣១]

**ប្រធានអង្គជំនុំ៖**

សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! លោកស្តាប់យល់ហើយអំមិញគឺ មន្ត្រីរដ្ឋបាលតុលាការពន្យល់លោកហើយ។ លោកប្រើប្រាស់នូវឧបករណ៍ក្បាលមីក្រូស្រូបសំឡេងនៅចំពោះមុខលោកហ្នឹងគឺ លោកនឹងអាចនិយាយបានលុះត្រាតែភ្លើងសញ្ញាក្រហម សឹមលោកចាប់ផ្តើមនិយាយ ទើបសំឡេងរបស់លោកហ្នឹងចូលក្នុងប្រព័ន្ធសំឡេងដែលបានភាគីពាក់ព័ន្ធបានស្តាប់ ហើយនិងប្រព័ន្ធសំឡេងរបស់គាត់ចូលទៅប្រព័ន្ធនៃការបកប្រែភាសាផ្សេងទៀត មានភាសាអង់គ្លេស និងភាសាបារាំង។ ប្រហែលជាលោកយល់ហើយណ៎ះ! អ៊ីចឹងពេលដែលនិយាយ ពេលដែលតាំងសំណួរ ភាគីផ្សេងៗសួរទៅលោក គឺលោកមិនគប្បីនិយាយភ្លាមទេ គឺរង់ចាំមើលភ្លើងក្រហមនៅក្បាលមីក្រូជាមុនសិន។ បានន័យថា ក្បាលមីក្រូដំណើរការហើយ សឹមលោកនិយាយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ**

**ស៖** តើលោកមានឈ្មោះអ្វីទៅ?

**លោក អែម អឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ អែម អឿន។

**ស៖** បាទ អរគុណ។ តើលោកមានដែលឈ្មោះ -- មានប្រើឈ្មោះហៅអ្វីផ្សេង ក្រៅពី អឿន ដែលឬទេ?

**ឆ៖** បាទឈ្មោះដែលធ្លាប់ហៅធម្មតា បើនិយាយក្នុងដំណើរបដិវត្តន៍ ខ្ញុំបាទឈ្មោះ អៀប ឡុន។

**ស៖** ម្តងៗទៀត ឈ្មោះអីៗ?

**ឆ៖** ឈ្មោះហ្នឹងខ្ញុំមិនដែលប្រើទេឥឡូវ។ ព្រោះប្រើជាប់ ប្រើឈ្មោះ អែម អឿន តែឈ្មោះហៅក្នុងដំណើរបដិវត្តន៍ខាងដើមមក គឺ អៀប ឡុន។

[១១:៣៨:២០]

**ស៖** បាទ អរគុណ។ ហើយតើលោកមានអាយុប៉ុន្មាន?

**ផ៖** ខ្ញុំមានអាយុ ៦១។

**ស៖** បាទ អរគុណ។ តើលោកអាចប្រាប់ដល់អង្គសវនាការបានដែរឬទេ អំពីទីកន្លែងកំណើតរបស់លោក តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ផ៖** បាទ សុំថ្វាយបង្គំប្រណិប័តន៍ អស់លោកប្រធាន។ ខ្ញុំអាចនិយាយបានពីដំណើររបស់ខ្ញុំផ្ទាល់តែម្តង។ ខ្ញុំបាទឈ្មោះ អែម អឿន។ ភូមិកំណើត កើតនៅភូមិត្រពាំងផ្លុង ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង។

**ស៖** អរគុណ។ ចុះលំនៅដ្ឋានបច្ចុប្បន្ន តើលោកនៅទីកន្លែងណា?

**ផ៖** បច្ចុប្បន្ន គឺខ្ញុំស្ថិតនៅក្នុងភូមិឈូកស ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម។

**ស៖** បាទអរគុណ។ ហើយឥឡូវនេះលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ផ៖** បច្ចុប្បន្ន រកស៊ីបច្ចុប្បន្ន គឺធ្វើស្រែចម្ការ។

**ស៖** បាទ អរគុណ។ ហើយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តើលោករស់នៅទីកន្លែងណា? ហើយប្រកបមុខរបរអ្វីដែរ?

[១១:៤០:00]

**ផ៖** សូមទោសលោកប្រធាន ខ្ញុំក្នុងចំណុចនេះ ខ្ញុំអាចបកស្រាយបានខ្លះ មិនអាចបានខ្លះ ព្រោះការគិតទៅ វារឿងយូរអង្វែងទៅហើយ លោកប្រធាន។

**ស៖** លោកអាចប្រាប់ជាគោលបានហើយ ថាលោកជាចម្បង គឺលោកនៅទីកន្លែងណាក្នុងចន្លោះពី១៧ មេសា ៧៥ រហូតដល់០៦ មករា ៧៩។ ហើយមុខងាររបស់លោកដែលលោកធ្លាប់បានធ្វើខ្លះៗហ្នឹង តើលោកធ្វើអីជាសំខាន់នៅក្នុងចន្លោះពេលពីឆ្នាំ៧៥ ដល់ ៧៩ហ្នឹង?

**ផ៖** សូមគោរពលោកប្រធាន ក្នុងចន្លោះពីឆ្នាំ ១៧ ខែមេសា ឆ្នាំ១៩៧៥ មុននេះ គឺខ្ញុំបាទធ្វើពេទ្យ។ បាទ ក្រោយឆ្នាំ១៩៧៥ ខ្ញុំបាទនៅធ្វើពេទ្យ។ ការធ្វើពេទ្យរបស់ខ្ញុំ មូលដ្ឋានធ្វើពេទ្យគឺនៅពេទ្យតំបន់២០។ ការធ្វើពេទ្យនេះ ខ្ញុំបានឆ្លងកាត់មករៀនសូត្រនៅទីក្រុងភ្នំពេញ ហៅថា ពេទ្យ១៧មេសា។

[១១:៤១:១៨]

**ស៖** បាទ អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកឈ្មោះអី?

**ផ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ អ៊ូច សាអែម។

**ស៖** បាទអរគុណ។ ចុះម្តាយបង្កើតរបស់លោក?

**ឆ៖** ម្តាយបង្កើតរបស់ខ្ញុំ គឺឈ្មោះ អៀប ស្រែម។

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអីដែរ?

**ឆ៖** ប្រពន្ធខ្ញុំបាទ ឈ្មោះ ស៊ឹម អ៊ី។ ព្រោះខ្ញុំសូមបញ្ជាក់ប្រាប់លោកប្រធានឲ្យហើយត្រង់ណេះ កុំឲ្យពិបាកសួរ ព្រោះថាខ្ញុំមានប្រពន្ធពីរ ព្រោះប្រពន្ធមួយគេលែងលះទៅ។ នៅសល់ប្រពន្ធសព្វថ្ងៃ គឺ ឈ្មោះ ស៊ឹម អ៊ី។ តែអតីតកន្លងមក ប្រពន្ធខ្ញុំខាងដើមដែល ប៉ុល ពត ការឲ្យហ្នឹងគឺ អ៊ុង ណេង។ ស្រុកកំណើតអ្នកទាំងពីរនេះ។ ប្រពន្ធដើមគឺស្ថិតនៅក្នុងភូមិរើលលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម។ ហើយប្រពន្ធសព្វថ្ងៃនេះ គឺស្ថិតនៅក្នុងភូមិឈូកស ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម។

[១១:៤២:៣៧]

**ស៖** បាទ អរគុណ។ ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនបច្ចុប្បន្ន គឺបើនិយាយដំណើរ២នាក់នេះ មានម្នាក់កូន២ ម្នាក់កូន៣។ កូន២ គឺនៅកន្លងមក គឺកូន២។ តែបច្ចុប្បន្ន កូន៣នាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងដីកាចាត់តាំងភារកិច្ចឲ្យសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន នេះមុនភាគីដទៃទៀត។ បាទ សូមអញ្ជើញ!

[១១:៤៣:៣៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងអង្គសវនាការទាំងមូល។ មេធាវីដែលនឹងសួរជាដំបូង គឺលោកមេធាវី គីម ម៉េងឃី បន្ទាប់មកខ្ញុំបាទ ពេជ អង្គ។ ហើយប្រសិនបើថាមានអ្វីត្រូវបន្ថែមលោកស្រី គ្រីស្ទីន ម៉ាទីណូ នឹងបន្ថែម ប្រសិនបើថាមានអ្វីចាំបាច់។

អ៊ីចឹងជាបឋម ខ្ញុំសូមលោកប្រធានអនុញ្ញាត លោក ម៉េងឃី ជាដំបូង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ សូមគោរពអង្គសវនាការទាំងមូល។ ជម្រាបសួរលោកអ៊ំ អែម អឿន។ ខ្ញុំបាទ គីម ម៉េងឃី ជាមេធាវីតំណាងឲ្យលោក ដែលជាមេធាវីនៃក្រុមមេធាវីក្នុងព្រំដែនប្រទេសបារាំង។ ហើយខ្ញុំទទួលបន្ទុកក្នុងការចោទសួរសំណួរពាក់ព័ន្ធទៅនឹងពាក្យបណ្តឹងដែលលោកអ៊ំបានដាក់នៅក្នុងសំណុំរឿង០០២នេះ។ ក៏ប៉ុន្តែមុននឹងចាប់ផ្តើមការសួរសំណួររបស់ខ្ញុំ ខ្ញុំសូមអនុញ្ញាតជម្រាបលោកអ៊ំអំពីសិទ្ធិខ្លះៗ ខ្លីៗ សំខាន់របស់អ៊ំនៅក្នុងសវនាការនេះ គឺថាលោកអ៊ំមានសិទ្ធិត្រូវបានគេស្តាប់សក្ខីកម្ម។ បានន័យថា ស្តាប់សក្ខីកម្មដោយអង្គសវនាការរបស់អ៊ំ។ អ៊ំអាចរៀបរាប់រឿងអ្វីដែលអ៊ំបានជួបប្រទះនៅក្នុងសម័យខ្មែរក្រហម។ អ៊ំមានសិទ្ធិសម្តែងនូវទុក្ខសោករបស់អ៊ំ ដែលហៅថា ជាពាក្យច្បាប់ថា ព្យសនកម្ម និងអ៊ំអាចមានសិទ្ធិទាមទារឬលើកសំណូមពរទៅកាន់អង្គជំនុំជម្រះដើម្បីពិចារណា។

**ប្រធានអង្គជំនុំ៖**

លោកបន្តសំណួរទៅ។ កិច្ចការនោះ ជាមុខងាររបស់ប្រធានសាលាដំបូង ហើយប្រធានមិនប្រាប់សិទ្ធិអំពីនេះ ការងារនេះភ្លាមទេ។ ក្រែងលោច្របូកច្របល់ នៅពេលដែលតាំងសំណួរហ្នឹង គាត់ផ្តើមថ្លែងនូវបញ្ហានោះតែម្តង។ បញ្ហានោះ គឺគាត់នឹងអនុវត្តនូវនាទីចុងក្រោយនៃការមុននឹងចប់តាំងសំណួរដេញដោលរបស់គាត់។ គាត់អាចលើកដូច្នេះបាន។ ក្រែងលោគាត់ច្រឡំ -- លោកច្រឡំភារកិច្ចក្នុងការបំពេញតួនាទីនៅក្នុងកិច្ចដំណើរការសវនាការនេះ យើងផ្តល់ភារកិច្ចជូនទៅលោកក្នុងការតាំងសំណួរដេញដោលអំពីសារធាតុពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលគាត់បានដឹង បានឮ បានឃើញពាក់ព័ន្ធទៅនឹងដីកាចោទប្រកាន់ -- ដីកាដំណោះស្រាយចោទប្រកាន់ទៅលើជនជាប់ចោទ។

[១១:៤៦:១៨]

**លោក គីម ម៉េងឃី៖**

សូមអរគុណនូវការបញ្ជាក់របស់លោកប្រធាន។ ពីព្រោះមុនសវនាការហ្នឹងបន្តិច ដោយកូនក្តីខ្ញុំសួរសំណួរមួយដែលគួរឲ្យភ្ញាក់ផ្អើល គឺគាត់សួរខ្ញុំថា តើគាត់ត្រូវសម្បថដែរឬទេ?

អ៊ីចឹង ខ្ញុំមានអារម្មណ៍ថា គាត់អត់បានទាន់យល់នូវសិទ្ធិរបស់គាត់។ ដូច្នេះ ខ្ញុំឆ្លៀតឱកាសនេះ

ពន្យល់គាត់ដោយខ្លីៗទេ លោកប្រធាន ខ្ញុំមិនប៉ានរំលោភបំពាននូវតួនាទីទេ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** អ៊ីចឹង ខ្ញុំចាប់ផ្តើមនូវសំណួររបស់ខ្ញុំ គឺថា លោកអ៊ំបានដាក់ពាក្យបណ្តឹងនៅក្នុងឆ្នាំ២០១០ ពោលគឺរយៈពេលទើបតែថ្មីៗនេះទេ។ តើលោកអ៊ំអាចជម្រាបអំពីថា តើលោកអ៊ំបានដាក់ពាក្យបណ្តឹងហ្នឹងយ៉ាងម៉េច? លោកអ៊ំអាចរៀបរាប់បានទេ អំពីការដាក់ពាក្យបណ្តឹងរបស់អ៊ំនៅ -- ហេតុអីបានជាមានការយឺតយ៉ាវយ៉ាងនេះ?

[១១:៤៧:១៥]

**លោក អែម អឿន៖**

**ឆ៖** សូមជម្រាបលោកចៅក្រម ដំណើរមូលហេតុដែលយឺតយ៉ាវ ដោយសារខ្ញុំផ្ទាល់តែម្តងមិនបានដឹងថាមានផែនការបែបនេះឯង។ មិនដែលដឹង ឮតែតាមវ៉ាដ្យូ តែច្រកដែលធ្វើ ដាក់ពាក្យដាក់អីមិនដឹងដាក់តាមណា។

**ស៖** បាទ សូមអរគុណ។ ក្រោយមកទៀត លោកអ៊ំបានដាក់ពាក្យបណ្តឹងហ្នឹង គឺលោកអ៊ំបានធ្វើជា មានទម្រង់នៃការបំពេញបែបបទព័ត៌មានជនរងគ្រោះហ្នឹង ចំនួនពីរលើក ដែលលើកទី១ នៅថ្ងៃទី២៥ ខែ០១ ឆ្នាំ២០១០ នៅក្នុងហ្នឹង គេបញ្ជាក់ថា ដាក់ដោយផ្ទាល់ខ្លួន។

[១១:៤៧:៥៨]

មួយទៀតថ្ងៃទី២៩ ខែ០១ ឆ្នាំ២០១០ ដាក់ដោយអង្គភាព ឌី.ស៊ី.ខេម។ តើលោកអ៊ំអាចពន្យល់បានទេ ថាអំពីការដាក់ពាក្យបណ្តឹងមានពីរដងបែបនេះ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំសូមជម្រាបហេតុផលដែលលោកចៅក្រមគាត់សួរអំមិញ។ សួរថាហេតុអ្វីបានកើតជាខ្ញុំដាក់ពីរដង? ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ដើម្បីកុំឲ្យបងប្អូនទាំងអស់ស្តាប់ហ្នឹងថាហេតុអីបានជារតេតរតូត? តែមុននឹងនិយាយអីទាំងអស់ ខ្ញុំបាទសូមអភ័យទោសបងប្អូនទុកជាមុនថាខ្ញុំនិយាយតែតាមដំណើរបច្ចុប្បន្ននេះ មានជំងឺនៅបំពង់ក មិនអាចនិយាយរហ័សបានទេ និយាយក៏ស្អិតមាត់រហូត។ ដូច្នេះ សូមអធ្យាស្រ័យទុកជាមុន ហើយខ្ញុំក៏សូមលើកឡើងបញ្ហាអ្វីដែលៗខ្ញុំចាំបានមកនិយាយ រឿងដែលប្រឌិត ឬរឿងដែលនឹកឃើញដោយខ្លួនឯង ឬឮតាមគេ ខ្ញុំអត់និយាយទេ។ ខ្ញុំសូមលើកហេតុផលមួយ ដែលខាងលោកចៅក្រមគាត់សួរថា ចុះហេតុអ្វីជាកើតជាអ៊ំយឺតយ៉ាវយ៉ាងនេះ?

[១១:៤៩:១២]

**លោក គីម ម៉េងឃី៖**

សូមទោសលោកអ៊ំ ខ្ញុំមេធាវីទេ មិនមែនចៅក្រម។ សូមកែលោកអ៊ំបន្តិច។

**លោក អែម អឿន៖**

**ឆ៖** អូ! សូមទោសបាទ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់សម្តីសំណួរនេះ។ មានន័យថា ហេតុអ្វីបានកើតជាលោកអ៊ំយឺតយ៉ាវ?

ខ្ញុំដាក់ពីរដង ទី១ គឺខ្ញុំដាក់ពាក្យបណ្តឹងទាមទារភាពពិតនៃការធ្វើរបស់តុលាការនេះ។ មួយទៀតចុងក្រោយមកទៀត ខាងមជ្ឈមណ្ឌលឯកសារនេះ ទាមទារខ្ញុំអាចឡើងធ្វើសក្ខីកម្មជាមួយនឹងតុលាការបាន។ ដូច្នេះ ខ្ញុំត្រូវពាក្យបន្ថែមនេះម្តងទៀត តែក្នុងនេះ ខ្ញុំបានប្រើពាក្យមួយ ដោយខ្ញុំយល់ឃើញថាមនុស្សខ្ញុំមិនបានរៀនសូត្រទេ ហើយការយល់ដឹងក៏តិចតួចដែរ។ ម្ល៉ោះហើយ ខ្ញុំសរសេរក៏មិនត្រូវអក្ខរាវិរុទ្ធដែរ។ ដូច្នេះ ខ្ញុំផ្ញើពាក្យ មិនមែនផ្ញើទេ ខ្ញុំពឹងខាងមជ្ឈមណ្ឌលឲ្យសរសេរឲ្យ។ ដូច្នេះ ខ្ញុំគ្រាន់តែបញ្ជាក់ថា អ្វីក៏ដោយដែលមានសាច់រឿងពិតៗរបស់ខ្ញុំ ខ្ញុំនឹងទទួលខុសត្រូវទាំងស្រុង។នេះឯងហើយដែលធ្វើឲ្យខ្ញុំយឺតយ៉ាវបាទ។

[១១:៥០:១១]

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំបន្តសំណួរពាក់ព័ន្ធទៅនឹងពាក្យបណ្តឹងរបស់លោកអ៊ំ។ លោកអ៊ំបានរៀបរាប់នៅក្នុងពាក្យបណ្តឹងហ្នឹង ហើយខ្ញុំចង់ដឹងអំពីប្រវត្តិអ៊ំខ្លះ។ តើនៅមុនឆ្នាំ នៅថ្ងៃ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើអ៊ំនៅទីណាខ្លះ ហើយអ៊ំបានធ្វើអ្វីខ្លះ? អ៊ំអាចរៀបរាប់បានទេបាទ?

**ឆ៖** មុន១៧ មេសា ខ្ញុំបានបញ្ជាក់ក្នុងឯកសារដែលខ្ញុំបានសរសេរ ពាក្យបណ្តឹងបានសរសេរខ្លះៗហើយក្នុងន័យជីវប្រវត្តិរបស់ខ្ញុំ។ ដូច្នេះការរស់នៅរបស់ខ្ញុំទៅតាមដំណើរការជាក់ស្តែង។ ព្រោះថាតាំងពីតូចក្រូចឆ្មារកន្លងមក ខ្ញុំមិនដែលបានចូលសាលារៀនសិក្សាអ្វីទាំងអស់។ ប៉ុន្តែដោយសារការខិតខំប្រឹងប្រែងក្នុងការចេះដឹងដោយសារឪពុកម្តាយក្រផង ហើយឯខ្លួនឯងចង់ដឹងចង់ចេះផង ក្នុងរយៈពេលមុន១៧ មេសា ខ្ញុំរស់នៅក្នុងថ្នាក់ទី -- មានពីរ។ ទី១គឺក្នុងកាតព្វកិច្ចភារកិច្ចជាកូនចិញ្ចឹមម្តាយ អ៎!ជាកូនទទួលខុសត្រូវចិញ្ចឹមឪពុកម្តាយ នេះគឺជាចំណុចទី១។ ទី២ទៀត ដើម្បីបានស្វាយ បានវិជ្ជាខ្លួនឯង ខ្ញុំបានស្ម័គ្រចិត្តមកធ្វើជាកូនគូលីរបស់ឪពុកមាខ្ញុំនៅទីក្រុងភ្នំពេញ។ បាទសូមជម្រាប។

[១១:៥១:៤៤]

**ស៖** សូមអរគុណ។ តើលោកអ៊ំអាយុប៉ុន្មានដែលលោកអ៊ំមកភ្នំពេញ ហើយធ្វើកូនគូលីហ្នឹង ធ្វើផ្នែកអី? លោកអ៊ំអាចបញ្ជាក់បានទេ?

**ឆ៖** ក្នុងហ្នឹងគឺមកធ្វើនៅទីក្រុងភ្នំពេញ ធ្វើជាកូនគូលីហ្នឹង បើនិយាយពាក្យសាមញ្ញរបស់យើងធម្មតាហៅថាកូនគូលី ប៉ុន្តែបើក្នុងន័យពេលដែលខ្ញុំធ្វើហ្នឹង មិនមែនជាលក្ខណៈកូនគូលីទេ គ្រាន់ជាកូនក្មួយ សិក្សាអំពីឪពុកធំហ្នឹងឯង។ អ៊ីចឹងពេលដែលខ្ញុំចាប់ផ្តើមការងារ គឺខ្ញុំចាប់ផ្តើមសិក្សាអំពីចំណេះដឹងមន្ទីរពេទ្យ។ ដោយសារឪពុកធំនោះ គាត់ជាពេទ្យនៅប្រចាំពេទ្យរុស្ស៊ី ម្ល៉ោះហើយគាត់ក៏ចាប់ផ្តើមបណ្តុះបណ្តាលខ្ញុំផ្ទាល់តែម្តងនៅក្នុងដំណើរធ្វើពេទ្យ ហើយការចាប់ផ្តើមដំបូងរបស់គាត់ គឺគាត់ឲ្យខ្ញុំចាប់ផ្តើមក្នុងការសិក្សា ព្យាបាលជំងឺទូទៅ ដែលគាត់បានយកមកដាក់ផ្ទះគាត់។ ហ្នឹងសូមលោកមេធាវីសួរបន្ថែមទៀតចុះ។

[១១:៥២:៤៧]

**ស៖** តើលោកអ៊ំសិក្សាវិជ្ជាហ្នឹងរយៈពេលប៉ុន្មានឆ្នាំ អាយុប៉ុន្មាន ដល់អាយុប៉ុន្មាន? លោកអ៊ំនៅចងចាំទេ?

**ឆ៖** ក្នុងនេះ ខ្ញុំបើនិយាយអំពីពេលវេលាកំណត់ថាឆ្នាំខែថ្ងៃណាខែណាប្រហែលជាខ្ញុំចាំមិនបានអស់ទេ។ ប៉ុន្តែបើនិយាយពេលវេលា ដែលខ្ញុំសិក្សានៅឱកាសណាៗ ខ្ញុំអាចនិយាយពីអាយុប្រហាក់ប្រហែលយើងបានខ្លះ។ ហ្នឹងសូមជម្រាបលោកមេធាវីបាទ។ អ៊ីចឹងដំណើរដែលខ្ញុំបានចូលសិក្សា ក្រេបជញ្ជក់វិជ្ជាតាមរយៈឪពុកមានេះ គឺខ្ញុំបើតាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលជាខ្ញុំអាយុប្រហែលជា១០ឆ្នាំជាងតិចតួច។ តែថាជាងនោះ អាយុប៉ុនណាទៀត ខ្ញុំអត់ដឹងថាប៉ុនណាទេ ព្រោះដឹងថាប្រហែលជាជាង ១០ឆ្នាំ។ សូមលោកមេធាវីបន្តសំណួរទៀតចុះ។

[១១:៥៣:៥៥]

**ស៖** ដូច្នេះនៅក្នុង -- លោកអ៊ំមានប្រសាសន៍ថា អាយុជាង១០ឆ្នាំ។ ដូច្នេះខ្ញុំអាចស្មានថាក្នុងឆ្នាំហុកជាង ហើយចុះបន្តទៀតពីហុកជាងដល់៧៥ លោកអ៊ំ -- ដំណាក់កាលហ្នឹងលោកអ៊ំអាចបញ្ជាក់បន្ថែមទៀតបានទេ លោកអ៊ំទៅណាទៀត? ធ្វើអីខ្លះ?

**ឆ៖** ក្នុងរយៈអាយុនេះ ខ្ញុំក្រោយពីពេលបាននិយាយខ្លះតិចតួច នៅពេលដែលខ្ញុំបានចេះវិជ្ជាពីឪពុកមាហើយ គឺប្រហែលជាខ្ញុំអាយុស្រដៀងគ្នានឹងជិតៗ២០ឆ្នាំ។ ដូច្នេះ ខ្ញុំក៏ពេលឱកាសហ្នឹង បើតាមខ្ញុំចាំបាន ក្នុងពេលដែលខ្ញុំបានវិជ្ជាប៉ុណ្ណឹង ប្រទេសកម្ពុជាយើងកើតសង្គ្រាមជាមួយ -- ខ្មែរក្រហមអ្នក

បង្កើតសង្គ្រាម គឺធ្វើ -- ដូច្នេះឪពុកមាហ្នឹងគាត់ភ័យបារម្ភ ខ្លាចខ្ញុំបែកបាក់ឪពុកម្ដាយ គាត់ក៏ឲ្យខ្ញុំត្រឡប់ទៅនៅស្រុកស្រែវិញ។

ចន្លោះពេលហ្នឹងដែរ ខ្ញុំក៏សូមបញ្ជាក់ជូនទាំងអស់គ្នាឲ្យបានដឹងថា ជីវប្រវត្តិរបស់ខ្ញុំក្រៅពីពេលត្រឡប់ពីភ្នំពេញទៅដល់ផ្ទះសម្បែង គឺមុននឹងរៀនត ខ្ញុំសូមបញ្ជាក់ថា ជីវប្រវត្តិរបស់ឪពុកខ្ញុំផ្ទាល់តែម្ដងអតីតកន្លងមក គាត់ជាប្រវត្តិមេខ្មែរឥស្សរៈ។ ដូច្នេះ គាត់ប្រឹងព្យាយាមក្នុងលក្ខណៈក្រីក្ររបស់គាត់ គាត់ប្រឹងឲ្យកូនក្មួយ -- កូនរបស់គាត់ទៅធ្វើគូលីរបស់ប្អូនរបស់គាត់នៅទីក្រុងភ្នំពេញក្នុងកាលៈដែលគាត់មិនបានមានលុយកាក់ ដើម្បីឲ្យកូនរៀនសូត្រ។

[១១:៥៥:៣១]

នៅពេលដែលខ្ញុំរៀនសូត្រចប់ ឱកាសនោះគឺ ខ្មែរក្រហមនឹងកើតឡើងនៅក្នុងស្រុកខ្មែរ។ អ៊ីចឹងដោយសារឪពុកធំហ្នឹង គាត់ខ្លាចបែកបាក់គ្នា គាត់ក៏ឲ្យខ្ញុំត្រឡប់ទៅនៅស្រុកកំណើត។ ខ្ញុំសូមបន្តនៅលើបញ្ហាទាំងអស់នេះ។ ខ្ញុំសូមឲ្យលោកមេធាវី ចាំតាមដាននូវសម្ដីរបស់ខ្ញុំ បើសិនជាខុសសូមបញ្ជាក់ថាដូចសង្ស័យ អរគុណ។ បើសិនអ៊ីចឹងសូមបញ្ជាក់បន្តទៀតថា នៅពេលចន្លោះពីពេលដែលខ្ញុំទៅពីភ្នំពេញវិញ គឺខ្ញុំរស់នៅជាមួយម្ដាយឪពុកដដែល ដើម្បីក្នុងឋានៈខ្ញុំចិញ្ចឹមឪពុកម្ដាយដដែល។ ចន្លោះនៅពេលនោះក្រោមការដឹងឮរបស់ពពួកខ្មែរក្រហមជំនាន់នោះ គឺឪពុកខ្ញុំអតីតជាមេឥស្សរៈ គាត់ក៏បន្តដំណើរការរបស់គាត់ជារៀងរហូត។

ឆ្លៀតឱកាសនេះទៀត គឺក្នុងដំណើរដែលគាត់ប្រឹងសិក្សា ប្រឹងធ្វើការងាររបស់គាត់ ពួករបស់គាត់ក៏គាត់ដឹងឮថា កូនតាហ្នឹងចេះពេទ្យ។ ដល់ដឹងថា កូនតាហ្នឹងចេះពេទ្យ ខ្មែរក្រហមហ្នឹងឯងគឺ សុំតាឪពុកខ្ញុំហ្នឹង សុំខ្ញុំឲ្យនៅជាមួយខ្មែរក្រហម។ តែពេលណាមិនពេលនណានោះ ខ្ញុំមិនបានចាំថា ខ្ញុំបានចូលធ្វើនៅពេលណា ខ្ញុំមិនបានដឹងទេ សូមអភ័យទោស។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ពេលទៅភ្នំពេញ គឺខ្ញុំបានចូលធ្វើពេទ្យឲ្យខ្មែរក្រហម ក្រោមការបញ្ជារបស់ឪពុកខ្ញុំផ្ទាល់។

ក្រោយមកទៀត ខ្មែរក្រហមគេយល់ឃើញថា ខ្ញុំៗវិជ្ជាវាស្ទើរ ដូច្នេះប្រើមិនទាន់បាននៅឡើយ។ ក្នុងឱកាសនោះទៀត ដោយសារការស្និទ្ធស្នាលរវាងឪពុកខ្ញុំផង រវាងខ្ញុំនិងគាត់ហ្នឹងផង គឺគាត់ក៏ស្គាល់ខ្ញុំច្បាស់ គាត់ក៏បង្ខំឲ្យខ្ញុំ -- មិនមែនបង្ខំទេ គឺបញ្ជាឲ្យខ្ញុំទៅរៀនពេទ្យជាមួយវៀតណាម ហៅថា យៀកកុងនេះឯង គឺអ្នកដែលឲ្យទៅគឺលោក សោ ភឹម ប្រធានភូមិភាគបូព៌ានេះឯង។ ហ្នឹងសូមបញ្ជាក់ឲ្យបានដឹងរឿង។ សូមបន្តទៀតចុះបាទ។

[១១:៥៧:១៨]

**ស៖** បាទ អរគុណលោកអ៊ំ។ ខ្ញុំអត់ទាន់ច្បាស់ពីរឿងពេលវេលាបន្តិច។ លោកអ៊ំមានប្រសាសន៍ថា លោកអ៊ំរៀនពេទ្យហើយ បន្ទាប់មកលោកអ៊ំត្រឡប់ទៅស្រុកហើយ លោកអ៊ំទៅរៀនពេទ្យទៀតជាមួយខាងវៀតកុងទៀត។ ខ្ញុំចង់ដឹងថាតើអាយុប៉ុន្មាន -- ក្នុងអំឡុងអ៊ំមានអាយុប៉ុន្មានដែលអ៊ំរៀនពេទ្យហ្នឹង? ហើយបន្ទាប់មកទៀត អ៊ំត្រឡប់ទៅស្រុកវិញ នៅពេលដែលអ៊ំមានអាយុប៉ុន្មាន? ហើយបានបន្តទៅមួយកន្លែងទៀត។ អ៊ំចាំបានទេ?

**ឆ៖** ខ្ញុំសូមបន្ត។ រឿងដែលថា អាយុថាច្បាស់លាស់ប៉ុនណា ថាប៉ុនណានោះ ខ្ញុំអត់បានច្បាស់ទេ។ ប៉ុន្តែខ្ញុំគ្រាន់តែបានដឹងថា ប្រហែលជាអាយុក្រោម២០ មិនទាន់ដល់២០ទេ ប្រហែលជាក្រោម២០។ អ៊ីចឹងនៅពេលវេលាដែលៗខ្ញុំទៅរៀនពេទ្យផង មើលជំងឺផង ចិញ្ចឹមឪពុកម្តាយផង ចន្លោះនោះ គឺសង្គ្រាមរបស់ខ្មែរក្រហមកាន់តែខ្លាំងឡើងៗ។ ដូច្នេះនៅក្នុងឱកាសនោះ ឪពុកខ្ញុំផ្ទាល់ក៏ឲ្យខ្ញុំធ្វើការងារពេទ្យជាមួយខ្មែរក្រហមផ្ទាល់តែម្តង។ ហើយការចាប់ផ្តើមធ្វើនោះ គឺខ្ញុំធ្វើពេទ្យ នៅតំបន់២០ ក្រោមការរៀបចំរបស់លោក ខឹម ខ្ញុំមិនបានចាំត្រកូលគាត់ទេ លោក ខឹម គឺជាប្រធានតំបន់។ ដូច្នេះបងប្អូនណាស្គាល់ប្រវត្តិរូប ឪពុកម្តាយរបស់គាត់ត្រកូលអត់ស្គាល់ទេ តែស្គាល់ឈ្មោះ ខឹម។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ នៅពេលដែលអ៊ំសិក្សាវិជ្ជាពេទ្យនៅភ្នំពេញហ្នឹងសិក្សាជាលក្ខណៈវិជ្ជាជីវៈមានសញ្ញាប័ត្រត្រឹមត្រូវ ឬក៏គ្រាន់តែចូលធ្វើការអនុវត្តជាក់ស្តែង ឬក៏យ៉ាងម៉េច? លោកអ៊ំអាចបញ្ជាក់កិច្ចការហ្នឹងបន្តិចបានទេ?

[១១:៥៩:២៥]

**ឆ៖** ខ្ញុំសូមបន្តពីចម្លើយរបស់ខ្ញុំ។ សូមបញ្ជាក់ឲ្យបានដឹងជាមុនថាទុកឲ្យហើយថា រយៈពេលដែលខ្ញុំទៅភ្នំពេញវាពីរគន្លាក់។ ទី១ ខ្ញុំទៅពីតូចធ្វើពេទ្យឲ្យឪពុកធំខ្ញុំ មកដល់ខ្ញុំធំចេញពីខ្មែរក្រហម អ៊ំ! ចេញពីយួនមកវិញ គឺខ្ញុំទៅធ្វើពេទ្យម្តងទៀត។ អ៊ីចឹងកាលៈនេះ បើសិនជាមិនបានបកស្រាយទេ អាចនឹងស្តាប់ទៅជាន់គ្នា។ ព្រោះខ្ញុំនៅពេលដែលចេញពីវៀតណាមមក គឺខ្ញុំបានឪពុកខ្ញុំ និងលោកតា សោភឹម ព្រមទាំង តាខឹម ហ្នឹងគាត់សុំខ្ញុំទៅនៅពេទ្យតំបន់ ធ្វើជាពេទ្យតំបន់ គឺពេទ្យបដិវត្តន៍តំបន់២០។ តាមការដឹងរបស់ខ្ញុំប្រហែលៗ ជាអាយុខ្ញុំ២១, ២២, ២៣។ ខ្ញុំមិនទាន់បានស្មានបានទេ ដូច្នេះខ្ញុំសូមអភ័យទោសទុកជាមុន ប្រហែលជាអាចនឹងមានលើក្រោម ក្រោមលើ។ ប៉ុន្តែនេះជារឿងពិតរបស់ខ្ញុំ សូមៗនិយាយរឿងពិត។ សូមសួរបន្តទៀតបាទ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ។ លោកប្រធានខ្ញុំគិតថា ពេលនេះដល់ពេលសម្រាក ឬក៏ខ្ញុំអាចបន្តខ្លះទៀតលោកប្រធាន?

[១២:០០:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ អរគុណលោក អែម អឿន។ ឥឡូវនេះដល់ពេលសមល្មមសម្រាបដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅកន្លែងរង់ចាំសម្រាប់សាក្សី អ្នកជំនាញ ដើម្បីនៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់នេះវិញ នៅវេលាម៉ោងកំណត់ គឺម៉ោងមួយសាមសិបនាទីនៅរសៀលនេះ។

សូមអញ្ជើញលោកមេធាវី!

[១២:០១:៣៥]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំសូមអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោម ដោយសារតែគាត់ឈឺក្បាល ឈឺខ្នង ហើយនិងមិនអាចផ្តង់អារម្មណ៍បាន។ ហើយយើងបានធ្វើការរៀបចំនូវលិខិតលះបង់សិទ្ធិរួចហើយ នឹងដាក់ជូនទៅអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយមូលហេតុមានបញ្ហាសុខភាព អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។

[១២:០២:៣៥]

ហើយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ អង្គជំនុំជម្រះតម្រូវឱ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាក់ជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមកសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម។ ដោយនៅរសៀលនេះឱ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ពីក្រុមសហមេធាវីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីផ្សេងទៀត សូមចាប់អារម្មណ៍ថាកាលពីកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ កន្លងមក អង្គជំនុំជម្រះបានមាន

បំណងលើកទឹកចិត្តដល់ភាគីនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកជំនាញមួយរូបហ្នឹង គឺឲ្យចាត់តាំងនូវក្រុមរបស់ខ្លួនហ្នឹងតែមនុស្សម្នាក់ទេ ដើម្បីតាំងសំណួរដេញដោល ក្នុងន័យដើម្បីចៀសវាងនូវការសំណួរ -- តាំងសំណួរច្រំដែល ឬក៏បាត់បង់នូវពេលវេលា ដើម្បីឲ្យពេលវេលាហ្នឹងមានប្រសិទ្ធភាព ប្រព្រឹត្តទៅឆាប់រហ័ស។

[១៣:៣៣:០១]

ហើយនៅក្នុងនោះ គឺអង្គជំនុំជម្រះបានលើកឡើងផងដែរអំពីការអនុវត្តកន្លងមក គឺក្រុមមេធាវីការពារក្ដីលោក អៀង សារី លោកបានអនុវត្តតាំងពីពេលមុនមក ហើយរហូតដល់ពេលនេះគឺបានអនុវត្តល្អ។ គប្បីពិនិត្យនូវលទ្ធភាពនេះ ដើម្បីអនុវត្តនៅក្នុងកិច្ចប្រឹងប្រែង ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ ដូច្នេះសូមភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានចំណាប់អារម្មណ៍បញ្ហានេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បាទ លោកប្រធាន យើងបានស្ដាប់ឮការលើកទឹកចិត្តនេះហើយ ក៏ដូចជាភាគីផ្សេងទៀត ហើយភាគីទាំងអស់បានគំនិតយោបល់របស់ខ្លួន ហើយមតិខ្លះគឺថាយល់ស្រប ដោយសារតែតុលាការនោះមានលក្ខណៈកូនកាត់។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា យើងមិនមែនមានគ្នាបីនាក់ជាអ្នកសួរទេ ប្រហែលជាពីរនាក់ទេ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ភាគីទាំងអស់ជាទីគោរព! ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា ខ្ញុំនឹងមិនសួរដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ។ យើងខ្ញុំបានជ្រើសរើសឲ្យលោក អង្គ ពេជ ហើយនិងលោក គីម ម៉េងឃី ជាអ្នកសួរដើមបណ្ដឹងរដ្ឋប្បវេណីនេះ ពីព្រោះថា ម្យ៉ាងដោយសារតែការនិយាយភាសាខ្មែរនោះវាមានភាពងាយស្រួល កុំឲ្យមានបញ្ហាក្នុងការបកប្រែ ហើយលោក អង្គ នឹងសួរសំណួរ។ ដូច្នេះខ្ញុំគិតថា ខ្ញុំនឹងមិនសួរសំណួរទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេលោកប្រធាន។

[១៣:៣៤:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយអង្គជំនុំជម្រះគ្រាន់តែជាការរំឭកដើម្បីឲ្យការប្រព្រឹត្តទៅនៃកិច្ចដំណើរការ

របស់យើងហ្នឹងប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព ពីព្រោះយើងបានមានការគិតគូរ អំពីបញ្ហានេះរួចហើយ។ សូមអញ្ជើញ!

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** ហើយសូមជម្រាបសួរសាជាថ្មីដល់លោកអ៊ំ អែម អឿន។ បាទ បន្តសំណួរអំពីព្រឹកមិញ លោកអ៊ំបាននិយាយដំណាក់កាលមុនឆ្នាំ១៩៧៥ អំពីការងាររបស់អ៊ំមករៀនពេទ្យ ហើយនិងធ្វើការងារជាពេទ្យរហូតទៅដល់វិលទៅដល់ស្រុកកំណើតវិញ។ ខ្ញុំចង់ដឹងថា តើពេលដែលលោកអ៊ំទៅដល់ស្រុកកំណើតភ្លាម លោកអ៊ំធ្វើអី? ហើយនៅទីកន្លែងណាលោកអ៊ំអាចបញ្ជាក់ចំណុចនេះបានទេ?

[១៣:៣៥:៥៥]

**លោក អែម អឿន៖**

**ឆ៖** សូមជម្រាបប្រាប់ការសួររបស់លោកមេធាវី ខ្ញុំបាទ សូមបញ្ជាក់ថា នៅពេលដែលខ្ញុំត្រឡប់ពីភ្នំពេញទៅដល់កន្លែងមូលដ្ឋានការងាររបស់ខ្ញុំវិញ គឺខ្ញុំចាប់ផ្តើមទទួលបន្ទុកបង្ហាត់បង្រៀនពេទ្យនៅក្នុងតំបន់ ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រោះអង្កាល់នុំង វាគ្មានពេទ្យ។ ហើយនៅក្នុងទន្ទឹមនឹងនោះទៀតក៏ខ្ញុំត្រូវទទួលកាតព្វកិច្ចថែទាំម្តាយ ព្រោះឪពុកអត់នៅផង។ ហើយចន្លោះពេលនុំងទៀត ក៏មិនយូរប៉ុន្មានឪពុកខ្ញុំក៏ត្រូវបាត់ខ្លួននៅពេលនោះតែម្តង។ នៅក្នុងនាទី ពេលដែលទៅពីភ្នំពេញ ការងារធំបំផុតគឺស្នូលរបស់ខ្ញុំគឺ ការងារធ្វើពេទ្យនេះឯង។

[១៣:៣៦:៥៤]

**ស៖** បាទសូមអរគុណ។ លោកអ៊ំមានប្រសាសន៍ថា បង្ហាត់បង្រៀនពេទ្យនៅក្នុងតំបន់ តើតំបន់ណាដែរ ហើយមាននៅក្នុងភូមិស្រុកឃុំ ឬខេត្តណា គេហៅយ៉ាងម៉េចដែរនៅក្នុងសម័យនោះ?

**ឆ៖** គោលដៅដែលខ្ញុំរាស្ត្ររស់នៅនៅពេលនោះ គឺខ្ញុំស្ថិតនៅក្នុងអង្គភាពតំបន់២០ ស្ថិតក្នុងភូមិភាគបូព៌ា គោលដៅដែលបោះទីតាំងនៅគឺ នៅភូមិជោរ ឃុំគ្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង ក៏ដូចជាតំបន់២០ នេះឯង។

**ស៖** តើលោកអ៊ំអាចបញ្ជាក់បានទេថា តើអ្នកណាដែលជាប្រធាននៃតំបន់២០ ហ្នឹង ហើយអ្នកណាដែលជាអ្នកចាត់តាំងឲ្យលោកអ៊ំធ្វើជាអ្នកបង្ហាត់បង្រៀនវិជ្ជាពេទ្យហ្នឹងដល់អ្នកនៅក្នុងតំបន់នោះ?

[១៣:៣៨:១៧]

**ឆ៖** អ្នកដែលរៀបចំឱ្យខ្ញុំធ្វើជាពេទ្យ តាំងពីខាងដើមរហូតដល់ពេលដែលខ្ញុំចេញ -- រហូតដល់ឆ្នាំ៧៩ -- ៧៥ គឺមានន័យថា ខ្ញុំរស់នៅក្រោមការរៀបចំរបស់លោក ខាំ ជាចៅហ្វាយតំបន់នេះឯង។ បន្ទាប់ក្នុងហ្នឹងដែរ ក៏មានលោកពូរបស់ខ្ញុំ គឺ កុង សុគន្ធ ហៅ ទុយ ហៅ ម៉ក់ ម៉ុក គាត់ហៅ បីជាន់ បាទ។

**សៈ** លោកពូបាននិយាយអំពីរចនាសម្ព័ន្ធទីតាំងហ្នឹងនៅក្នុងមុនឆ្នាំ១៩៧៥ និយាយអំពីតំបន់ហើយនិងភូមិភាគបូព៌ា។ តំបន់ និងភូមិភាគបូព៌ាហ្នឹង នៅក្នុងហ្នឹងគឺជាតំបន់ខ្មែរក្រហម ឬក៏ជាតំបន់យ៉ាងម៉េច លោកអ៊ំសូមបញ្ជាក់កន្លែងហ្នឹងបន្តិច?

[១៣:៣៩:២៣]

**ឆ៖** ខ្ញុំបញ្ជាក់បន្ថែម បញ្ជាក់ការពិតគឺក្នុងខេត្តតំបន់នេះ គឺនៅម្ដុំភូមិខ្ញុំផ្ទាល់តែម្ដង ការរស់នៅរបស់ខ្ញុំគឺមានតែតំបន់រំដោះរបស់ខ្មែរក្រហមផ្ទាល់តែម្ដង។ វា -- បានន័យថា តំបន់របស់ លន់ នល់នោះនៅឆ្ងាយពីហ្នឹង។ អ៊ីចឹងកន្លែងរបស់ខ្ញុំគឺជាកន្លែងតំបន់រំដោះ។

**សៈ** បាទ សូមអរគុណ។ ការដែលគេចាត់តាំងឱ្យលោកពូបង្រៀនពេទ្យហ្នឹង តើលោកពូ បានផ្ដោតសំខាន់ទៅលើការងារអ្វីខ្លះដែលត្រូវបណ្ដុះបណ្ដាលដល់អ្នកដែលនៅក្នុងតំបន់នោះ?

**ឆ៖** ការងារដែលខ្ញុំចាប់ផ្ដើមអនុវត្តនៅក្នុងអង្គភាពដែលខ្ញុំរស់នៅ ក៏ក្រៅពីការតែងតាំងរបស់តំបន់ឱ្យខ្ញុំទទួលខុសត្រូវបង្រៀនពេទ្យ បង្កើតពេទ្យនៅក្នុងតំបន់ៗច្រើននោះ។ ជាគោលការណ៍របស់អង្គការពេលនោះ គឺគោលបំណងគឺបម្រើប្រជាជន។ ក្នុងឱកាសនោះ មានន័យថា ខ្ញុំស្ម័គ្រមិនមែន -- ខ្ញុំស្ម័គ្រ ខ្ញុំត្រូវតែទទួលកាតព្វកិច្ចមួយ គឺទទួលបង្ហាត់បង្រៀនខាងវិជ្ជាពេទ្យ។ អ៊ីចឹងគោលបំណងរបស់ខ្ញុំជាគោលការណ៍ត្រង់ៗ ហ្នឹងគឺថា មានន័យថា ខ្ញុំខំបង្ហាត់បង្រៀនដើម្បីយកចំណេះវិជ្ជានេះទៅ ឱ្យអ្នកដែលចេះដឹងយកទៅបម្រើប្រជាពលរដ្ឋ។

[១៣:៤១:១២]

**សៈ** សំណួររបស់ខ្ញុំផ្ដោតទៅលើការងារជាពេទ្យហ្នឹង បង្រៀនដូចជាឱ្យថ្នាំ ចាក់ថ្នាំ ឬក៏បង្រៀនយ៉ាងម៉េចដែរ លោកពូអាចបញ្ជាក់កន្លែងហ្នឹងបានទេ ការងារពេទ្យហ្នឹង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ពីសកម្មភាពផ្ទាល់របស់ខ្ញុំក្នុងនាមកាតព្វកិច្ចបង្រៀនពេទ្យ គឺជាគោលការណ៍របស់បក្សនៅកន្លែងនោះ គឺបង្រៀនពីមិនចេះ រហូតដល់ចេះ។ ពីធ្វើមិនកើត ឱ្យធ្វើកើត។ នេះជា

គោលការណ៍របស់បក្សពីកាលនោះ។ ឯគិតនេះ គឺវាស្របនឹងគំនិតដែលខ្ញុំចង់ចេះពីវិធីនេះផ្ទាល់តែម្តងម្ល៉ោះហើយ កាលណាទទួលកាតព្វកិច្ចគឺខ្ញុំខំបង្ហាត់បង្រៀនពេទ្យ ពេទ្យឱ្យមានសុជីវធម៌អង្កាល់ -- មានតែសីលធម៌។ ការពិតទៅ ក្នុងសម័យដំបូងបង្អស់ហ្នឹង គឺក្រឹត្យក្រមរបស់គាត់ហ្នឹងគឺល្អ គឺល្អមែនទែនដែរ តាមដំណើរល្អណាស់។ អ៊ីចឹងខ្ញុំឃើញឱកាសល្អរបស់បក្សនុំង ក៏ខ្ញុំប្រឹងប្រែងសាងអំពីល្អឱ្យអ្នកដែលទទួលឥទ្ធិពលពីខ្ញុំឱ្យស្គាល់អំពីល្អ ធ្វើឱ្យបានល្អទីចុងបំផុត។ មានន័យថា បើអ្នកធ្វើអីឱ្យស្គាល់តួនាទីនោះឯង។ បើធ្វើពេទ្យកុំធ្វើឱ្យរួចពីដៃ យ៉ាងណាក៏ដោយបើគេ បើអ្នកឯងស្តាប់គេ អ្នកឯងត្រូវតែទទួលខុសត្រូវ។ ព្យាបាលគេជា ចាំមើល បើមិនជា គួរឱ្យប្រមូលគេប្រមូលឯងឱ្យជួយមើលគ្នា។ នេះជាគោលការណ៍របស់ខ្ញុំបានបង្ហាត់បង្រៀន។

[១៣:៤២:៤១]

ហើយអ្នកដែលចេះចាំពេទ្យទៅតាមដំណាលដែលខ្ញុំបង្ហាត់បង្រៀននេះ គឺខ្ញុំឱ្យគេទាំងអស់នេះឱ្យបានស្គាល់ច្បាស់ពីការកកើតជំងឺមកពីអី មូលថ្នាក់អី មកពីហេតុអី បានជាជាកើតជំងឺ។ ហើយការព្យាបាលទៅវិញ ទាល់តែអ្នកទាំងអស់ហ្នឹងមើលឃើញហេតុ ថាហេតុអីបានកើតជំងឺនេះ កើតជំងឺនោះ។ អ៊ីចឹងខ្ញុំចង់គេទាំងអស់នេះដឹងពីជំងឺ មូលហេតុអីដែលកើត ជំងឺអីហ្នឹង គឺឧបមាថា បើគ្រុនពោះវៀនមកពីហើយបើគ្រុនចាញ់មកពីអី។ អ៊ីចឹងប្រការដែលកើតហេតុ ជួនកាលវាមកពីលក្ខណៈបច្ចេកទេស ជួនកាលមកពីការថែរក្សារបស់យើងមិនស្គាល់ពេលវេលានិងឱកាស។ អាហ្នឹងសូមជម្រាបលោកមេធាវី។

**ស៖** តើលោកអ៊ំអាចពន្យល់បានថា មានន័យថាការរៀនពេទ្យនៅទីនោះ គេយកការអនុវត្តមកធ្វើតែម្តង ដោយមិនបានសិក្សាពីផ្នែកទ្រឹស្តី ឬក៏ឆ្លងកាត់សាលាពេទ្យណា? ពិតជាអ៊ីចឹងមែនទេលោកអ៊ំ?

[១៣:៤៣:៥០]

**ឆ៖** ខ្ញុំសូមនិយាយទាញមកក្រោយវិញ ដើម្បីបងប្អូនអ្នកស្តាប់យល់អំពីដំណើរ ព្រោះខ្ញុំមិនចេះអក្សរ ចុះហេតុអីបានធ្វើកើត? ប៉ុន្តែខ្ញុំសូមអធិប្បាយរឿងពិតថា មុននឹងខ្ញុំបានទៅជាពេទ្យហ្នឹងព្រោះឪពុកមាខ្ញុំបានយកខ្ញុំ ទៅហ្វឹកហ្វឺនរួចទៅហើយ។ អ៊ីចឹងប៉ុន្តែគ្រាន់ថា ខ្ញុំចេះជាលក្ខណៈក្របខ័ណ្ឌ វាអត់មាន។ អ៊ីចឹងហាក់ដូចតែខ្ញុំអត់ចេះដដែល។ មូលហេតុអី? ដោយគ្មានអ្នកណាទទួលស្គាល់នូវឡើយ។ អ៊ីចឹងតែខ្ញុំការធ្វើនេះ គឺខ្ញុំប្រើពាក្យមួយ ខ្ញុំថាធ្វើដោយងងឹតងងុល ដោយសារគ្មាន -- គ្មានការហ្វឹកហ្វឺន ឬការទទួលស្គាល់ពីវេជ្ជបណ្ឌិតណាអត់ទេ។ អ៊ីចឹងខ្ញុំនិយាយតាមពាក្យពិត ក្រោយពីពេលអ្នកធ្វើការស្គាល់ថាខ្ញុំនឹងសិក្សាពេទ្យច្បាស់លាស់ កើតជាអស់លោកហ្នឹងឱ្យខ្ញុំទៅកាន់ការងារក្នុងពេទ្យ អាស្រ័យ

ដោយអ្នកធ្វើការងារនោះសុទ្ធតែសាច់ សំបូរទៅដោយសាច់ឈាមខ្ញុំបាទ។ អ៊ីចឹងហើយបានកើតជា -- ទាំងអស់នោះច្រើនប្រគល់តួនាទីភារកិច្ចនោះមកឲ្យខ្ញុំ។

[១៣:៤៤:៤៥]

ប៉ុន្តែធាតុពិតទៅ ដំណើរដើមកាលពីការរៀបចំខាងដើម ខ្ញុំចាំបានថា អ្នក ពួកហ្នឹងប្រើហាក់ដូចជាមិនយកចិត្តទុកដាក់ថា មើលមនុស្ស ធ្វើពេទ្យដើម្បីមើលមនុស្សដូចជាមិនគិតអ៊ីចឹង។ អ៊ីចឹងឲ្យតែអ្នកណាគេស្រឡាញ់ គេនឹងចាប់ដាក់តែម្តង។ ខ្ញុំសូមជម្រាបរឿងពិត។ អ៊ីចឹងមិនទាន់ដឹងថា អ្នកដែលគេទៅប្រើតើអ្នកឯងមានវិជ្ជាពេទ្យប៉ុនណា? ហើយមានសញ្ញាបត្រដែរឬអី? ហើយអ្នកណាខ្លះទទួលស្គាល់? អ៊ីចឹង ខ្ញុំមើលជាលក្ខណៈរៀបចំពួកគាត់ហាក់ដូចជាមិនចាប់អារម្មណ៍ត្រង់ហ្នឹង។ អានេះជាការពិតសូមលោកមេធាវីបន្ត។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេ នៅពេលដែលមានការបង្ហាត់បង្រៀននោះអាចមានធ្វើឲ្យអ្នកជំងឺហ្នឹងកាន់តែធ្ងន់ធ្ងរ ឬក៏ធូរស្បើយ ឬក៏អាការៈយ៉ាងម៉េចដែរ នៅក្នុងការដកពិសោធន៍នៅពេលនោះ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ការពិត។ រឿងពិត គឺវាស្ថិតនៅលើការពិត ខ្ញុំមិនអាចនិយាយរឿងកុហកបានឡើយ ប៉ុន្តែក្នុងនេះ ខ្ញុំបញ្ជាក់ការពិត អ្វីដែលមិនពិត អ្វីដែលពិតខ្ញុំដាច់ខាតត្រូវតែនិយាយ។ ហើយកន្លែងខ្ញុំធ្វើអី ខ្ញុំត្រូវតែនិយាយដើម្បី ឲ្យបងប្អូនទាំងអស់ដែលមិនបានៗអនុវត្តរោគផ្ទាល់ស្គាល់ហេតុផល តើរឿងហ្នឹងវាអ៊ីចឹងមែនឬអត់? ក្នុងកន្លែងរបស់ខ្ញុំផ្ទាល់ ក្រោយពីពេលដែលខ្ញុំទទួលខុសត្រូវទៅ ខ្ញុំមិនដែលប្រើបុគ្គលណាដែលងងឹតងងុលទៅធ្វើទេ គ្រាន់តែខ្ញុំឃើញអ្នកដែលប្រាប់ពីលើខ្ញុំអត់បានពិចារណាប៉ុណ្ណឹងឯង។ អ៊ីចឹងហេតុផលទាំងអស់នេះ គោលដៅនៃអ្នកព្យាបាល កន្លែងរបស់ខ្ញុំក្រោយពីពេលដែលខ្ញុំទទួលខុសត្រូវដូចជាមិនមានហេតុផលអីជាប់គុកជាប់ច្រវាក់ដោយសារមិនយកចិត្តទុកដាក់ទេ។

[១៣:៤៦:៣៦]

មានតែបក្សហ្នឹងរកហេតុ រកផលពេទ្យតែម្តង។ យ៉ាងណាមិញ ពេទ្យពេលនោះដូចជាខ្ញុំជាដើមការពារចង់បានណាស់អំពើល្អ។ ហើយប្រឹងប្រែងណាស់ ព្រោះអត់ថាលំបាកណាស់ -- របបនោះកាលណាអ្នកឯងធ្វើខុសអី គឺអ្នកត្រូវតែទទួលខុសត្រូវ។ ហើយខ្ញុំជាមនុស្សម្នាក់ចូលចិត្តទទួលការខុសត្រូវនិងការពិត ខ្ញុំមិនប៉ានធ្វើអីខ្ជីខ្ជាទេ ព្រោះខ្លាចងាប់ដោយសារបក្សកំណត់ថាឯង -- ថាយើងក្បត់បក្ស។ អ៊ីចឹងខ្ញុំត្រូវតែយកចិត្តទុកដាក់។ សូមបញ្ជាក់ការពិតអ៊ីចឹង។

**ស៖** បាទ បន្តសំណួរមួយផ្សេងទៀតពាក់ព័ន្ធទៅនឹងដែលអ្វី ដែលលោកអ៊ំនិយាយ ដែលហៅថា តំបន់រំដោះ។ តើលោកអ៊ំអាចរៀបរាប់អំពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់រំដោះ និង តំបន់ក្រៅរំដោះហ្នឹងខុសគ្នាយ៉ាងម៉េចដែរ អំពីការរស់នៅក្នុងសម័យនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជម្រាបជូនបងប្អូនទាំងអស់ដែលបានរស់នៅដល់ថ្ងៃនេះរហូតដូចខ្ញុំដែរ ខ្ញុំសូមបញ្ជាក់ថា ឈ្មោះដែលហៅថា "តំបន់រំដោះ" បានន័យថា "ពួកបដិវត្តន៍នេះ ពួកក្រហមនេះអ្នកកាន់កាប់ការងារទាំងអស់ ធ្វើអ្វីមួយដែលក្រោមការរៀបចំរបស់បក្ស" ហៅថា "តំបន់រំដោះ"ៗ បានន័យថា "រំដោះពីសត្រូវរបស់ខ្មែរក្រហម មកជាតំបន់ខ្មែរក្រហម"។ នោះដែលគេឲ្យឈ្មោះថា "តំបន់រំដោះ" ។ ហ្នឹងតាមការចងចាំរបស់ខ្ញុំទេ អ្នកដែល -- ហើយក្នុងឱកាសនោះទៀត ក្នុងឱកាសនោះខ្ញុំមិនបានស្គាល់ទេ ហៅថា "តំបន់មិនរំដោះ" អត់ស្គាល់ទេ ព្រោះមូលហេតុអី? ព្រោះខ្ញុំរស់នៅក្នុងរបៀបក្រហមហ្នឹង តាំងពីឪពុក តាំងពីខ្ញុំធំដឹងក្តីម្ល៉េះ។ ខ្ញុំសូមបញ្ជាក់ប្រាប់មេធាវីបាទ។

[១៣:៤៨:២៩]

**ស៖** តើមានការចាប់ប្រជាជន ឬក៏ការដាក់ទណ្ឌកម្ម ឬក៏ការបំបិទសិទ្ធិអីទេនៅក្នុងតំបន់រំដោះនោះ?

**ឆ៖** ក្នុងតំបន់រំដោះនៃទីកន្លែងដែលខ្ញុំរស់នៅ ខ្ញុំសូមនិយាយពីរបីៗ បីរបៀប បីវគ្គ។ វគ្គទី១ គឺវគ្គដំបូងហៅថា តំបន់រំដោះ, វគ្គទី២ គឺនៅក្នុងឆ្នាំ៧៥, វគ្គទី៣ គឺក្រោយឆ្នាំ៧៥ ដូច្នេះសូមលោកមេធាវីបានចាំឲ្យច្បាស់សាច់រឿងដែលខ្ញុំត្រូវនិយាយ។ ក្នុងតំបន់រំដោះមានន័យថា បើក្រោយពី -- ក្នុងតំបន់រំដោះបានន័យថាក្នុងៗប្រជាជនទូទៅ គេរៀបចំចាប់ផ្តើមដំបូងបង្អស់គឺគេរៀបចំជាសហករណ៍ ធ្វើរបៀបប្រវាស់ដៃក្នុងប្រជាពលរដ្ឋទូទៅ។ ក្រោយមកទៀត គេរៀបចំទៅជាលក្ខណៈក្រុមប្រវាស់ដៃ។ ក្រោយមកទៀតគេធ្វើទៅជាលក្ខណៈ ហៅថាគេហៅថា សហករណ៍ នេះជាលក្ខណៈក្នុងលក្ខណៈទី១។ បានន័យថាលក្ខណៈសហករណ៍មានន័យថា ក្នុងតំបន់រំដោះត្រូវតែស្តាប់គោលការណ៍របស់បក្សដែលបានបង្កើតឡើងក្នុងការងារអនុវត្តក្នុងតំបន់រំដោះ។ ហើយបន្ទាប់ទៅទៀត នៅក្នុងតំបន់រំដោះដែរ តែនៅក្នុងឆ្នាំ៧០ ណេះចាប់ផ្តើមពីឆ្នាំ៧០ គឺក្រោយពីរដ្ឋប្រហាររបស់ លន់ នល់ ទៅ គឺមានភាពមួយទៀតដែលធ្វើឲ្យខ្ញុំប្លែកនៅក្នុងវគ្គទី១នេះដែរ គឺរបៀបធ្វើនោះ វាបែរទៅជាមានក្រុមយុវជននោះផ្សេង ក្រុមមហាជននោះផ្សេង ឯប្រជាជនទូទៅ ក៏អ៊ីចឹងដែរ។ មានប្រជាជនចម្រើន មានប្រជាជនបក្ស -- អ៊ំ!មានប្រជាជនពេញសិទ្ធិ មានមិនសិទ្ធិ។ នេះគឺក្នុងៗឆ្នាំ៧០ ដែលខ្ញុំបាទចងចាំ។ ដូចជាយុវជន ដូចខ្ញុំ នៅ

កាលណោះ នៅជាយុវជន គឺមានក្រុមយុវជនស្នេហាជាតិ ដែលហៅថា ក្រុមយុវជនកម្លាំងពេញ។

[១៣:៥០:៤០]

យុវជនកម្លាំងពេញ គឺជាកម្លាំងស្នូល ឯប្រជាពលរដ្ឋ ក៏ដូច្នោះដែរ។ កម្លាំងពេញ មានន័យថា អ្នកធ្វើការបាន អាចដើរចោលកូនចៅក្រៅផ្ទះបាន ប៉ុន្តែសភាពនេះ គឺហាក់ដូច មិនមែនហាក់ទេ ពេលនេះ គេធ្វើហាក់ដូចជាមានរបៀបរៀបរយរបស់គេត្រឹមត្រូវតាមដំណើរ រៀបរាប់តាមសណ្តាប់ធ្នាប់។ ក្នុងនោះដែរ គេរៀបចំជាក្រុម ជាពួក តាមដំណើរដែលគេអាចរើសបាន។ អ៊ីចឹងមើលទៅល្បាក់ -- រស់នៅដូចគួរសមនឹងការរស់នៅ ហើយមានការប្រាស្រ័យទាក់ទងគ្នាបាន ដូចជាបានជាធម្មតាទេ ក្នុងចន្លោះឆ្នាំ៧០។ ៧០ គឺថាមុន៧៥ បានន័យថា រាប់អានដូចជាការប្រាស្រ័យទាក់ទងទៅមកៗ រវាងប្រជាជន និងប្រជាជន ដូចជាមានសិទ្ធិសេរីភាពធម្មតាបាន។ នេះ គឺជាវគ្គទី១។ បណ្តា វគ្គទី១ ក្នុងចំណុចទី១។ អ៊ីចឹង ដល់ក្នុងឆ្នាំ៧៥ លក្ខណៈប្លែកមួយទៀត បានន័យថា ចាប់ផ្តើមមានជនបង្កោល មានជនរាវរកស៊ីរ្វូងផ្ទៃក្នុង។ ក្នុងចន្លោះនោះ ខ្ញុំឃើញថា ពី៧០ រហូតដល់៧៥ មានន័យថា ប្រជាជនក្លាយទៅជាបីប្រភេទ។ បីប្រភេទនេះ ទី១ គឺមានប្រជាជនត្រៀម ប្រជាជនពេញសិទ្ធិ ប្រជាជនកំណត់ថា ជាប្រជាជនសត្រូវរបស់បក្ស។ ហ្នឹងខ្លះមើលទៅដូចមានបី មិនមែនដូចទេ គឺលក្ខណៈបីប្រភេទប្រជាជន។

[១៣:៥២:១៦]

ហើយលក្ខណៈបីប្រភេទនេះ ភាពរស់នៅតាមលក្ខណៈបីនេះដែរ។ អ៊ីចឹង សូមបងប្អូនដែលបានធ្លាប់ជួបប្រទះ បើសិនជាខ្ញុំនិយាយខុស សូមបងប្អូនជួយកែតម្រូវផង។ មូលហេតុ ខ្ញុំសូមនិយាយរឿងពិតរបស់ខ្ញុំ ដែលកន្លែងខ្ញុំរស់នៅ។ ត្រង់ហ្នឹង ខ្ញុំមើលទៅ នៅក្នុងឆ្នាំ ពីឆ្នាំនេះ រហូតដល់ឆ្នាំ -- មុនដល់ឆ្នាំ៧៥នេះ ភាពរស់នៅរបស់ប្រជាពលរដ្ឋយើងរកស៊ីហាក់ដូចគ្រាន់តែមានក្រុម មានពួកប៉ុណ្ណោះឯងគ្រាន់ថាទៅជាលក្ខណៈរួម--

**ស៖** អត់ទោសលោកអ៊ំ សូមលោកអ៊ំនិយាយៗបន្តិច។ សូមលោកអ៊ំនិយាយមួយៗ ដើម្បីគេបកប្រែ។

[១៣:៥២:៥១]

**ឆ៖** បាទ អរគុណ។ អ៊ីចឹង ក្នុងនោះ យើងមើលប្រជាពលរដ្ឋយើង យើងរស់នៅដូចមានលក្ខណៈសណ្តាប់ធ្នាប់នៅឡើយទេ។ ដូចជាខ្ញុំធ្វើពេទ្យអ៊ីចឹង ពេទ្យខ្ញុំ ខ្ញុំភារកិច្ចរបស់ខ្ញុំទី១ គឺមើល

ហ្វឹកហ្វឺនខាងពង្រឹងខាងវិជ្ជា -- ខាងបច្ចេកទេសរបស់អ្នកដែលចេះពេទ្យ។ ហើយភ្ជាប់ផ្សំនឹង ឲ្យពេទ្យទាំងអស់ហ្នឹង ស្គាល់អំពីសុជីវធម៌នៃការរស់នៅ, ស្គាល់អំពីការប្រាស្រ័យរវាងពេទ្យ ទៅនឹងអ្នកជំងឺ រវាងអ្នកជំងឺមកពេទ្យ ហើយប្រើប្រាស់សម្ដីទៅតាមលក្ខណៈដែលយើថា មានសុជីវធម៌នេះឯង។ អ៊ីចឹង មើលទៅក្នុងចន្លោះមុនឆ្នាំ៧៥ ដូចជាមានលក្ខណៈមួយសមរម្យនឹងរស់បាន។ នៅក្នុងឱកាសនោះ ខ្ញុំតែងតែលួចសរសើរឪពុកខ្ញុំថា គាត់ដើរ ដូចជាកន្លែងត្រូវដែរ មើលទៅឃើញល្អដែរ គោលការណ៍។ ព្រោះថា ធ្វើវាមានអ្នក -- មើលច្បាស់អ្នកមាន ច្បាស់អ្នកក្រ ច្បាស់លាស់ *(ឮមិនច្បាស់)* ច្បាស់។ នេះគឺការពិតដែលខ្ញុំធ្លាប់ជួប មិនមែននិយាយនេះកាន់ជើងអ្នកណាឡើយ សូមនិយាយរឿងពិត។ ប៉ុន្តែនៅក្នុងចំណុចទី -- គឺថាចំណុចហ្នឹង នៅក្នុងឆ្នាំ៧៥ មើលទៅប្រជាជនទៅជាលក្ខណៈបីប្រទេសវិញ។ អាហ្នឹង ធ្វើឲ្យខ្ញុំហ្នឹងចាប់ផ្ដើមងឿងឆ្ងល់ឡើងវិញ អាហ្នឹង សូមនិយាយប្រាប់អង្គសវនាការឲ្យបានច្បាស់ថា ខ្ញុំបានឆ្លងកាត់គ្រប់ចំណុច ដែលគេបានចែងទៅជាចំណុច។

[១៣:៥៤:១២]

ចំណុចនោះ ស្ថិតនៅក្នុងលក្ខណៈមួយដែលខ្ញុំចាប់ផ្ដើមប្រុងជើងព្រួល ថាខ្ញុំប្រហែលជាមានរឿង ហ្នឹងគិតទុកជាមុន។ អ៊ីចឹង ខ្ញុំតែងតែប្រយ័ត្នខ្លួនឯងរហូត តែចៃដន្យល្អ ឱកាសនោះ នៅក្រោយពេលឆ្នាំ៧៥ ត្រូវបក្ស -- ប្រាក់បក្ស -- បក្សដែលខ្ញុំនិយាយថា បក្សដែលស្រឡាញ់ខ្ញុំ គឺលេខាបក្ស តំបន់នេះ គឺមានចិត្តចរិតស្រឡាញ់ខ្ញុំ ក៏គាត់បន្លំៗ ដែលថាបន្លំប្រវត្តិរូបមួយ ដើម្បីលាក់ខ្លួនខ្ញុំ ដឹងថាឪពុក ខ្ញុំគាត់ដឹងថា បក្សចាប់បាត់ទៅហើយ។ អ៊ីចឹង គាត់ក៏លាក់រឿងនេះ មិនឲ្យខ្ញុំដឹង តែគាត់សូមប្ដូរ ប្រវត្តិរូបរបស់ខ្ញុំ។ ប្ដូរហើយអីហើយ គាត់បញ្ចូលខ្ញុំទៅសមាជិកបក្ស ឲ្យខ្ញុំឡើងមកសិក្សាវិជ្ជាពេទ្យ នៅភ្នំពេញវិញ នៅក្រោយឆ្នាំ៧៥។ តែខ្ញុំមិនចាំបានថា ក្នុងឆ្នាំ៧៥ នៅខែណាៗ ខ្ញុំមិនបានចាំទេ សូមអភ័យទោសដូចយូរណាស់ទៅហើយដែរ។ សូមទោស។ អ៊ីចឹង យ៉ាងណាក៏ដោយ សូមលោក មេធាវីបន្តទៀតចុះបាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ពេលដែលឆ្លើយសូមលោកអ៊ំឆ្លើយមួយៗ ហើយយឺតៗបន្តិច ព្រោះឲ្យលោកអ្នកបកប្រែគាត់អាចបកប្រែបានបាទ ភាសាបរទេស។ ហើយខ្ញុំអត់ទាន់ដល់ឆ្នាំ១៩៧៥ទេ ខ្ញុំត្រឡប់មកចំណុចមួយចំនួននៅក្នុងសម័យរំដោះវិញ។ និយាយអំពីការបែងចែកប្រជាជនជាបីប្រភេទ លោកអ៊ំមានប្រសាសន៍ខាងដើមមានប្រជាជនចម្រើន ប្រជាជនពេញសិទ្ធិ និងមិនពេញសិទ្ធិ តើវាមានការខុសគ្នាជីវភាពរស់នៅយ៉ាងម៉េច ឬក៏សម្គាល់យ៉ាងម៉េចថា ប្រជាជនហ្នឹងជាប្រជាជនចម្រើន? ជា

ប្រជាជនដែលគាត់ពេញសិទ្ធិ និងជាប្រជាជនមិនពេញសិទ្ធិ? ហើយបើមិនពេញសិទ្ធិ តើគាត់ត្រូវធ្វើម៉េច ឲ្យក្លាយទៅជាប្រជាជនដូចគេដូចឯងដែរ? បាទ សូមអរគុណ។

[១៣:៥៦:០២]

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនលោកមេធាវីឲ្យបានច្បាស់សាច់រឿងថា ឈ្មោះថាប្រជាជនបីប្រភេទ ប្រជាជនចម្រើន ប្រជាជនពេញសិទ្ធិ និងមិនពេញសិទ្ធិ។ ក្នុងលក្ខណៈហ្នឹង ខ្ញុំបានសិក្សា មិនមែនសិក្សា បានអនុវត្តផ្ទាល់ ផ្ទាល់ខ្លួនឯង។ ហៅឈ្មោះថាប្រជាជនពេញសិទ្ធិ គឺបើតាមប្រជាជន មិនមែនជាយុវជន គឺតាមភូមិ -- តាមផ្ទះសម្បែងគេហៅថាប្រជាជននោះ បើនិយាយចំហថាប្រជាជនចម្រើន គេហៅថាមហាជន។ ឯប្រជាជនពេញសិទ្ធិ គេហៅថាជនបង្គោល។ ពេលនោះ គឺជនបង្គោលបានន័យថា អ្នកជាប់ជាសម្ព័ន្ធហើយ បើជាប្រជាជនទូទៅពេលនោះ គេហៅថាសមាគមកសិករ។ បើបុគ្គលណាស្ម័គ្រចិត្តចូលជា -- មិនមែនស្ម័គ្រទេ គេតម្រូវឲ្យចូលជាសមាជិក អង្គការៗ សមាគម កសិករនោះគេហៅថាប្រជាជនពេញសិទ្ធិ។ ហើយប្រជាជននោះមានៗអាចៗនឹងឆាប់បានទទួលនាទីក្នុងការងារដែរ តម្រូវបក្សឲ្យធ្វើ ហ្នឹងមួយ។ ឯប្រជាជនអត់សិទ្ធិ គេស្រេចតែនឹងគេប្រើ និយាយត្រង់។ អត់ដែល គ្នាអត់ដែលមានទទួលតំណែងអី ឋានៈអីក្នុងតួនាទីធ្វើអីៗអត់ដែលបានទទួលបានឡើយ។ ហ្នឹងសូមជម្រាបលោកមេធាវី។

[១៣:៥៧:២១]

**ស៖** បាទ បន្តទៅទៀត លោកអ៊ំនិយាយអំពីប្រជាជនត្រៀម ប្រជាជនពេញសិទ្ធិ ហើយនិងសត្រូវ។ មានប្រជាជនបីប្រភេទ អាហ្នឹងយ៉ាងម៉េចដែរ ប្រជាជនហ្នឹង?

**ឆ៖** សូមបញ្ជាក់បន្ថែម បានន័យថា ក្នុងហ្នឹងសួរ ក្នុងចំណុចចុងក្រោយ៧៥ ឬក្នុង៧៥?

**ស៖** នៅមុនៗដែលលោកអ៊ំនិយាយថាមុន៧៥ នៅក្នុងតំបន់រំដោះរបស់អ៊ំហ្នឹង។

**ឆ៖** ត្រង់ហ្នឹងហាក់ដូចជានិយាយអំមិញហើយ ប្រជាជនពេញសិទ្ធិ។ ឈ្មោះថាសត្រូវ មានក្រោយៗអាដែលក្រោយ៧៥ ទេ។ មានសត្រូវ ជាសត្រូវនោះ។ ក្នុងហ្នឹងមានដែរ តែមិនទៅជាលក្ខណៈជាយុទ្ធសាស្ត្ររបស់គេ បានន័យថាគេគ្រាន់តែមើលឲ្យច្បាស់ ឲ្យបានច្បាស់ថាអ្នកណាជាមិត្ត អ្នកណាជាសត្រូវ។ អ្នកដែលថា តាំងថាជាសត្រូវរបស់បដិវត្តន៍គឺបញ្ញវន្ត និស្សិតបញ្ញវន្តនេះឯង។ ហ្នឹងក្នុងមុន ៧៥ បាទ។

[១៣:៥៨:៤១]

**សៈ** សូមអរគុណ។ បន្តទៅទៀត មានការបែងចែកយុវជនទៀត តើគេបែងចែកយុវជនហ្នឹង គេបែងចែកឲ្យធ្វើអី? ហើយយុវជនហ្នឹង គាត់មានឋានៈតួនាទីជាអីបានត្រូវការបែងចែកនៅក្នុងពេលនោះ?

**ឆៈ** ខ្ញុំសូមបញ្ជាក់អំពីពាក្យសម្ដី ខ្ញុំថា យុវជនបីចំណែក មើលសំណៅទៅគោលការណ៍នេះ មិនមែនថា ខ្ញុំថាឲ្យទៅលើទេ មានន័យថាជន ជាជនចម្រើនរបស់គេ មានន័យថាបើសិនជាអ្នកឯងក្រុមយុវជននោះ បើគេឲ្យទៅណា គ្នាត្រូវតែទៅ ត្រូវតែគោរពទង់ គោរពបក្ស។ នោះភាគច្រើនគេឲ្យយុវជនទាំងនោះចេញ ចាកចេញចោលឪពុក ចោលម្ដាយ ទៅធ្វើជាយុទ្ធជន ឬធ្វើទីណាក៏ដោយឲ្យតែបក្សត្រូវការ។ នេះអត់ៗប្រកែកបានឡើយ។ នេះគេហៅថាជនចម្រើនរបស់បក្ស បដិវត្តន៍របស់គាត់។ ប៉ុន្តែឈ្មោះថាជនៗដែលនៅជាមហាជន មហាជនមានន័យថា គេប្រើដូចជាឧបករណ៍ និងហៅថាឧបករណ៍ដាច់ថ្លៃទេ។ យល់ទេ លោកមេធាវី? អ៊ីចឹង គេចង់ត្រូវការម៉ោងណាក៏បាន ឲ្យធ្វើអីក៏បាន ធ្វើអានេះចប់ហើយ ឯងទៅធ្វើនោះទៀត ហ្នឹងជារឿងរបស់បក្សនោះឯង និងប្រើប្រាស់ដោយគ្នាគ្មានសិទ្ធិសេរីភាពនឹងតវ៉ាឡើយ។ ហ្នឹងបញ្ជាក់សូមលោកមេធាវីជ្រាបបាទ។

[១៤:០០:១៥]

**សៈ** តើយុវជនទាំងអស់នោះត្រូវបានគេកែនចូលធ្វើជាទាហានដែរឬទេ ឬក៏គ្រាន់តែជួយកម្លាំងការងារធ្វើស្រែចម្ការ ឬយ៉ាងម៉េច? អ៊ំអាចបញ្ជាក់បានទេ?

**ឆៈ** ក្នុងហ្នឹងសូមបញ្ជាក់មានពីរចំណុច ដើម្បីបញ្ជាក់ឲ្យអស់ហេតុផល កុំឲ្យមានការសង្ស័យបន្តទៀត។ ពាក្យថា យុវជនស្ម័គ្រចិត្ត មិនមែនស្ម័គ្រ យុវជនទទួលការតែងតាំងវាមានន័យសំខាន់បំផុត។ ខ្ញុំសូមនិយាយខ្លះ មិនមែនបរិយាយទេ តែសូមនិយាយរឿងពិត។ យុវជនៗដែលគេត្រូវតែឲ្យបំពេញកាតព្វកិច្ចមានន័យថា ចាប់ពីអាយុ១៦ឡើងទៅ សម័យនោះ ១៦ឡើងទៅ។ អ៊ីចឹងកាតព្វកិច្ច បើសិនជា បក្សតម្រូវឲ្យអ្នកឃ្លាតពីឪពុកម្ដាយបងប្អូន ត្រូវតែធ្វើបដិវត្តន៍ ដាច់ខាតត្រូវតែទៅ មិនមែនមើលទៅហាក់ដូចមិនមែនជាលក្ខណៈ កៀរទេ តែជាលក្ខណៈគ្មានសិទ្ធិ។ ខ្ញុំមិនយល់ថា គ្មានសិទ្ធិយ៉ាងម៉េចទេ បើបក្សឲ្យទៅដាច់ខាតត្រូវតែទៅហើយអាហ្នឹង មិនដឹងថាម៉េចទេ។ វាដូចមិនកៀរ មានឈ្មោះ មិនអត់ទេ ឧបមាថា បើឈ្មោះខ្ញុំហ្នឹងមានចារពីលើថា ឈ្មោះអ្នកឯង ត្រូវតែទៅទ័ពត្រូវតែទៅ។ ហ្នឹងមានថាជាចូលជាលក្ខណៈបង្ខិតបង្ខំ មិនមែនត្រឹមកៀរ វាលើពី -- បើសិនជាអ្នកនោះមិនបានទៅ មានឈ្មោះថាអ្នកប្រឆាំងនឹងបដិវត្តន៍។ ហ្នឹងសូមជម្រាបលោកមេធាវីឲ្យបានដឹង។ នេះហើយដែលៗ ខ្ញុំនិយាយថា

កៀរដូចជាមិនមែនកៀរ។ ប៉ុន្តែមើលទៅហិង្សា ដូចជាអត់ទេ ប៉ុន្តែបើសិនបុគ្គលណាមិនទៅ អ្នកនុ៎ងមានន័យថាប្រឆាំងនឹងបដិវត្តន៍។ ខ្ញុំអាណោចអាធ័មខ្លាំងបំផុតលោកមេធាវី យុវជនណាក៏ដូចយុវជនណាដែរ ខ្ញុំមិនមែនបរិយាយ តែសូមនិយាយរឿងពិត។ ខ្ញុំស្រលាញ់ណាស់ព្រះពុទ្ធសាសនានៅពេលនោះ គឺខ្ញុំជាយុវជនដែរនៅពេលនោះ ខ្ញុំស្រលាញ់ណាស់ព្រះពុទ្ធសាសនា ប៉ុន្តែបក្សតម្រូវឲ្យបំផ្លាញវត្តអារ៉ាម ឬក៏មិនឲ្យលោកសង្ឃបួស តើឲ្យខ្ញុំដោះស្រាយ បើខ្ញុំមិនធ្វើខ្ញុំមានបញ្ហាដល់បក្ស។

[១៤:០២:២៩]

ដូច្នេះដល់ត្រង់ហ្នឹង ខ្ញុំមានពេលខ្លះរហូតដល់បង្ហៀរទឹកភ្នែកចោល ដោយសារខ្ញុំស្រលាញ់ព្រះពុទ្ធសាសនា តែវាបែរទៅជាចំតួនាទីរបស់ខ្ញុំដែលត្រូវធ្វើទៀត។ អ៊ីចឹងខ្ញុំដោះស្រាយអត់ចេញ។ អ៊ីចឹងមានតែ -- មិនមែនមានទេ ក្នុងឱកាសនោះល្អណាស់បានខាងបងម្នាក់ជាលេខាតំបន់ តែងតាំងឲ្យខ្ញុំឡើងទៅរៀននៅភ្នំពេញ ផុតអរគុណមែនទែន។ ប៉ុន្តែទៅដល់ភ្នំពេញរឿងមួយទៀត កាលហ្នឹង អាហ្នឹងសូមបង្វិលមកក្រោយវិញ ប៉ុន្តែអារឿងបើសិនលោកមេធាវីចង់ដឹង សួរទៀតចុះកាលនៅភ្នំពេញ។ ប៉ុន្តែឥឡូវនេះខ្ញុំសូមបរិយាយ មិនមែនបរិយាយទេ សូមនិយាយរឿងពិតនៅក្នុងកម្មវិធីដែលខ្ញុំរស់នៅបាទ។

**ស៖** ការងាររបស់យុវជន បានន័យថា លោកអ៊ំបានរៀបរាប់ធ្វើដោយការបង្ខំ ហើយរហូតដល់ការបំផ្លាញ ហើយក្នុងនោះលោកអ៊ំនិយាយថា លោកអ៊ំត្រូវបានបក្សបង្គាប់ឲ្យបំផ្លាញព្រះពុទ្ធសាសនា លោកអាចអ៊ំរៀបរាប់បានទេ បំផ្លាញយ៉ាងម៉េចទៅ ព្រះពុទ្ធសាសនា ហើយគេធ្វើដឹកនាំយ៉ាងម៉េចទទួលបញ្ជាពីខាងណាមក? សូមលោកអ៊ំបញ្ជាក់កន្លែងហ្នឹងបន្តិចបាទ សូមអរគុណ។

[១៤:០៣:៤៧]

**ឆ៖** ខ្ញុំសូមបន្តបន្ថែមពីសម្តីដែលខ្ញុំនិយាយអម្បាញ់មិញ។ ក្នុងន័យថា បំផ្លាញ គឺការចាប់ផ្តើមអំពីមិនឲ្យយុវជនទៅបួសមួយ។ យុវជនបំពេញកាតព្វកិច្ចបានដាច់ខាតដល់អាយុត្រូវតែធ្វើទ័ពពីរ។ មិនឲ្យចាស់ទុំសាងវត្តអារ៉ាម នេះមានខ្លាំងនៅចន្លោះឆ្នាំ១៩៧២ ឬ៧៣ រហូតដល់៧៥។ នេះជាទស្សនៈមួយដែលមើលទៅឃើញរូបភាពហាក់ដូចជាបម្លែងសាសនា។ មិនមែនហាក់ទេ នៅពិសេសបំផុតនៅក្នុងឆ្នាំ៧៣ និង៧៤ ខ្ញុំចេះតែឆ្ងល់នៅឱកាសនោះ បើខ្ញុំមិនធ្វើ បើខ្ញុំមិនបញ្ជាឲ្យយុវជនខ្ញុំធ្វើ គេនឹងថាខ្ញុំក្បត់បក្ស បើក្បត់ត្រូវតែកម្ទេច។ អ៊ីចឹងខ្ញុំឱកាសនោះដឹងដោះស្រាយយ៉ាងម៉េច អ៊ីចឹងរឿងខ្លះមិនចូលខ្លះជារឿងធម្មតា ដើម្បីដោះស្រាយជីវិត គឺអស់លោកកាលនោះមិនដឹងខឹងអី ខឹងព្រះថ្ម បែរទៅយកព្រះថ្ម ដាក់ទម្លាក់អណ្តូង ឬទម្លាក់ស្រះ ឬទម្លាក់ស្ទឹងបឹងបួ បាត់បង់វត្ថុដែលជាទីសក្ការៈបូជារបស់ចាស់ទុំ

របស់យើង។ អ៊ីចឹងហេតុផលទាំងអស់ហ្នឹង ខ្ញុំគ្រាន់តែលើកឡើង ហេតុផលដែលខ្ញុំបានជួបប្រទះសូមអស់បងប្អូនទាំងអស់គ្នាតើរឿងហ្នឹងមែនឬអត់។ បងប្អូនណាដែលធ្លាប់រស់នៅក្នុង ប្រហែលជាបងប្អូនដឹងហើយក្នុងចន្លោះឆ្នាំ៧៣ ទៅ៧៥ ដឹងហើយ។

[១៤:០៥:១៧]

**ប្រធានអង្គជំនុំ៖**

លោក អែម អឿន លោកគប្បីកំហិតនូវចម្លើយរបស់លោកតបត្រឹមតែភាពចាំបាច់ទៅនឹងសំណួរដែលសួរបានហើយ។ ចៀសវាងការធ្វើអត្ថាធិប្បាយលាតត្រដាងផុតពី ឆ្ងាយផុតពីសំណួរ គោលបំណងនៃការសួរ។ ហើយលោកមេធាវីទទួលសិទ្ធិដូចគ្នា លោកមានពេលសរុបទាំងសហព្រះរាជអាជ្ញាគឺមានមានពេល១ថ្ងៃ បូកជាមួយនឹងមួយភាគបួនថ្ងៃ។ ហើយអង្គហេតុដែលធ្វើសវនាការនេះគឺចាប់ផ្ដើមពី១៧ មេសា ១៩៧៥ ដល់០៦ មករា ៧៩ ហើយយើងបានកំហិតត្រឹមតែសំណុំរឿង០០២/០១។ នេះជាអង្គហេតុដែលត្រូវធ្វើសវនាការ។ ចៀសវាងសំណួរចាកឆ្ងាយពីអង្គហេតុដែលមិនជាប់ពាក់ព័ន្ធ វានឹងមិនមាន នឹងមិនរួមវិភាគទានអ្វីក្នុងការស្វែងរកការពិតទេ ក្នុងដំណើរការដេញដោលនេះ ប្រសិនបើវាមិនចូលទៅក្នុងក្របខ័ណ្ឌនៃអង្គហេតុ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះជនជាប់ចោទ។

[១៤:០៦:៥២]

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ ដូច្នេះខ្ញុំគិតថា ខ្ញុំអាចបន្តសំណួរទៅសំណួរផ្សេងមួយទៀតពាក់ព័ន្ធទៅនឹងសំណុំរឿងដែលត្រូវស្ដាប់សក្ខីកម្មរបស់លោកអ៊ំ អែម អឿន។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** តើបន្តមកទៀតរហូតទៅដល់ពេលរំដោះ តើលោកអ៊ំនៅទីណាដែរ? ហើយធ្វើការអ្វីដែរនៅក្នុងឆ្នាំមួយប្រាំបួនរយ -- នៅអំឡុងពេល១៧ មេសា ១៩៧៥ ហ្នឹង?

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមបន្ត។ ឱកាស កន្លែង ពេលឱកាសនោះខ្ញុំរស់នៅក្នុងតំបន់២០ ក្នុងឋានៈជាពេទ្យ។

**ស៖** តើនៅៗក្នុងតំបន់២០ ដែលលោកអ៊ំរស់នៅនៅក្នុងពេលដែលរំដោះបានហ្នឹង លោកអ៊ំមានឃើញការវិលត្រឡប់របស់ប្រជាជនពីទីក្រុងភ្នំពេញទៅតំបន់អ៊ំរស់នៅដែរឬទេ?

[១៤:០៨:១៤]

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមនិយាយរឿងពិតថា ខ្ញុំបានឃើញ។ បានឃើញការ មិនមែនការវិលត្រឡប់ គឺការចេញពីភ្នំពេញទៅនៅជនបទ អ្នកជម្លៀសណ៎ា។

**ស៖** តើការ -- តើគេចាត់ថ្នាក់ប្រជាជនហ្នឹងយ៉ាងដូចម្ដេចដែរ? ហើយគាត់រស់ ក្រុមប្រជាជនដែលមកពីភ្នំពេញហ្នឹងរស់នៅយ៉ាងម៉េចដែរនៅក្នុងតំបន់២០ហ្នឹង?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមនិយាយពីរចំណុច ដែលត្រូវវិវត្តបត់បែន។ ក្រោយពេលរំដោះ៧៥ ហើយនៅបូព៌ាខ្ញុំ ដូចជាមានលក្ខណៈពីរៗ។ មុនពេលនៅមាននវត្តមានរបស់លោក សោ ភឹម មើលទៅលក្ខណៈរៀបចំប្រជាពលរដ្ឋដូចជារឿងធម្មតានៅឡើយទេ។ អ៊ីចឹងមានន័យថា គ្រាន់តែកើតបង្កើតក្រុមបក្ខពួក មិនទាន់មានប្រជាជន គេថាប្រជាជនចម្រើន ឬប្រជាជនអីមិនទាន់មានច្បាស់លាស់នៅឡើយទេ ចលនាប្រជាជនថ្មីក៏មិនទាន់ច្បាស់ដែរ។ នេះគឺជារឿងពិតដែលខ្ញុំរស់នៅ ប៉ុន្តែអាត្រង់ហ្នឹងសូមឲ្យលោកមេធាវីសួរដោយពិចារណាចុះ។ សូមទោស។

[១៤:០៩:៤៧]

**ស៖** តើប្រជាជនភ្នំពេញហ្នឹង គេហៅថា ប្រជាជនថ្មី ឬក៏ៗប្រជាជនធម្មតាទេនៅពេលនោះ?

**ឆ៖** ត្រង់ចំណុចហ្នឹង ខ្ញុំសុំនិយាយរឿងចំៗ កុំឲ្យវែងឆ្ងាយ បានន័យថា ឲ្យតែប្រជាជនមកពីភ្នំពេញទៅដល់ជនបទ គេឲ្យឈ្មោះថា ជាប្រជាជន១៧ មេសា ហៅថាប្រជាជនថ្មីនេះឯង។ តែពួកនោះឲ្យតម្លៃត្រឹមថា ប្រជាជន១៧ មេសា។

**ស៖** បាទ សូមអរគុណ។ លោកអ៊ំអាចបញ្ជាក់ ថាតើមានចំនួនច្រើន ឬក៏តិច ដែលផ្លាស់មកនៅក្នុងតំបន់២០ ដែលលោកអ៊ំបានឃើញ?

**ឆ៖** ផ្លាស់អី មិនមែនផ្លាស់ទេមនុស្ស យកទៅឲ្យនៅ បានន័យថានាំប្រជាជនពីក្រុងទៅឲ្យនៅ មិនមែនហៅថា ផ្លាស់ បើអត់មានផ្លាស់ផង មានតែបញ្ចូលថែម។ បញ្ចូលពីថ្មីទៅជាមួយអ្នកចាស់ កន្លងមកមិនមានន័យថាផ្លាស់ទេ អត់ទេ។ មានន័យថាភាគច្រើន គឺកន្លែងខ្ញុំច្រើនដែរ ច្រើនដែរ មិនដែរទេ ច្រើន។ គឺប្រជាជនថ្មីមកពីភ្នំពេញច្រើនណាស់ ច្រើន។ ហើយភាពរស់នៅរបស់គាត់ បើភូមិណាមានផ្ទះទូលាយ គេនឹងដកប្រជាជនចាស់ឲ្យនៅជាមួយបងប្អូនគេធម្មតា ហើយគេទុកផ្ទះខ្លះហ្នឹងឲ្យប្រជាជនថ្មីរស់នៅ ដោយខ្លួនគាត់ទៅចុះ។ មានក្រុមអ៊ីចឹងដែរ។ ហ្នឹងអាហ្នឹងមុន មុនការវិវត្តរបស់ -- មុនពេលដែលបាត់ សោ ភឹម និយាយត្រង់ នេះរឿងពិត។

[១៤:១១:៥១]

**សះ** បាទ បន្តមកទៀត តើលោកអ៊ំបន្តការងាររបស់លោកអ៊ំទៅទីកន្លែងណាទៀត បន្ទាប់ពីថ្ងៃរំដោះឆ្នាំ១៩៧៥ហ្នឹង?

**ឆះ** ក្រោយពីថ្ងៃរំដោះ ៧៥ ហ្នឹង ខ្ញុំចាំបាន មិនមែនចាំបានទេ គឺការផ្ញើរបស់ខ្ញុំក្រោមការរៀបចំរបស់លោក ខាំ គណៈតំបន់នេះ ឲ្យខ្ញុំទៅសិក្សាពេទ្យនៅទីក្រុងភ្នំពេញផង ទៅបម្រើការងារនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតហ្នឹងផង។ អ៊ីចឹង ខ្ញុំមានកាតព្វកិច្ចពីរ។ អ៊ីចឹង ក្នុងឱកាសហ្នឹងខ្ញុំទទួលភារកិច្ចមួយ រៀន, ពីរទៀត បើសិនជាមិននៅមូលដ្ឋានខ្វះបុគ្គលិកត្រូវតែគេយកមកវិញ។ អ៊ីចឹងដូចជាមិនពេញលក្ខណៈបុគ្គលិក ដូចជាអត់ពេញលក្ខណៈសិស្ស។ អ៊ីចឹងមានន័យថា ហាក់ដូចជាចល័ត ពេទ្យចល័តហ្នឹង សូមជម្រាបលោកមេធាវីបាទ។

**សះ** នៅពេលដែលគេបញ្ជូនលោកអ៊ំមករៀននៅភ្នំពេញហ្នឹង លោកអ៊ំរៀនប៉ុន្មានខែទៅ ហើយអ្នកណាជាអ្នកបង្រៀន? ហើយអ្នកណាជាអ្នកបញ្ជូនលោកអ៊ំឲ្យមករៀន?

[១៤:១៣:១៨]

**ឆះ** ត្រង់ហ្នឹង បើតាមការកំណត់របស់បក្សនៅពេលនោះ គឺឲ្យខ្ញុំឡើងរៀននៅភ្នំពេញរយៈពេល១ឆ្នាំ។ ប៉ុន្តែរឿងពិត ខ្ញុំរៀនបានតែ ៩ខែ ឬប្រហែលជា១០ខែ ខ្ញុំនិយាយតាមការប្រហែលចុះ ដូចអត់ប៊ានកំណត់ទេ មូលហេតុខ្លាចមិនច្បាស់ ក្រែងលោកជាន់រឿងកាល ព្រោះថាវាវែងឆ្ងាយ វែង ម៉្លោះហើយមិនអាចយកបានថា កំណត់ត្រង់ណាទេ។ ប៉ុន្តែជាគោលការណ៍ទៅតម្រូវខ្ញុំត្រូវសិក្សាតាមវិធីដែលថាជំនាញតាម តាមការតែងតាំងគឺតម្រូវ១ឆ្នាំ។ ប៉ុន្តែក្នុងនោះខ្ញុំសិក្សានេះប្រហែលជា៩ខែ ឬ១០ខែនោះឯង មិនបាន ដល់១២ខែទេ។ ដោយសារនៅ -- ពេលដែលខ្ញុំកំពុងតែរៀន គឺមានសភាពរឿងមួយទៀត នៅបូព៌ាគឺ ការវិវត្តរបស់សង្គ្រាមរវាងព្រំដែនវៀតណាម និងកម្ពុជា។ អ៊ីចឹងខ្ញុំត្រូវវិលត្រឡប់មកវិញ ដោយសារនៅតំបន់រំដោះ តំបន់២០ នេះ សម្បូរទៅដោយជំងឺយុទ្ធជន។ អ៊ីចឹងខ្ញុំត្រូវត្រឡប់មកវិញមុនការចប់។

[១៤:១៤:២០]

**សះ** ខ្ញុំសូមផ្តោតសំណួរលោកអ៊ំ ពាក់ព័ន្ធទៅនឹងរយៈពេល ៩ខែ នៅក្នុងមន្ទីរពេទ្យហ្នឹង។ តើលោកអ៊ំអាចរៀបរាប់អំពីសកម្មភាពរៀនសូត្រ សកម្មភាពការងារ វគ្គបណ្តុះបណ្តាល ឬក៏ទិដ្ឋភាពទូទៅដែល លោកអ៊ំបានឆ្លងកាត់បទពិសោធន៍នៅក្នុង៩ខែ នៅៗពេទ្យនៅភ្នំពេញហ្នឹងបានដែរឬទេ?

**ឆះ** ខ្ញុំអាចនិយាយបានខ្លះ ប៉ុន្តែដល់ចំណុចនេះ ខ្ញុំហាក់ដូចជាចង់លើករឿងពិតៗឲ្យអស់សាច់

រឿង ដើម្បីកុំឲ្យបងប្អូនយើងមានការងឿងឆ្ងល់ច្រើន ដោយសារអី? ដោយសារខ្ញុំបានចូលជ្រៅក្នុងតំបន់នេះឯង។ អីចឹងហេតុផលដែលខ្ញុំបានទៅសិក្សារៀនសូត្រនេះ ខ្ញុំមើលដោយសារខ្ញុំប្រយ័ត្នខ្លួនឯងផង ត្រូវប្រយ័ត្នប្រយែងផ្ទាល់ត្រូវមើលសភាពការណ៍ឲ្យបានច្បាស់។ ច្បាស់ អាការប្រឹងប្រែងមើលឲ្យច្បាស់ ឃើញហេតុផលធ្វើឲ្យយើងខ្លាចណាស់ព្រឺក្បាលណាស់ ខ្ញុំមើលទៅដំណើរយើង មើលទៅអនាគតឲ្យអត់រស់ មើលដំណើរពិត។ អីចឹងមើលឃើញគេចមិនបានប្រើ ថាមិនបាន ដូច្នេះដំណើរថាត្រូវតែស្លាប់ ត្រូវតែស្លាប់គេចមិនរួច អាហ្នឹងធ្វើឲ្យអាណោចអាធ័ម។ ដូច្នេះអាការពិតហ្នឹង បើសិនខ្ញុំនិយាយអស់ប្រហែលជាមិនអាចនិយាយបាន។ ដូច្នេះ ខ្ញុំគ្រាន់តែនិយាយថា ខ្ញុំដឹងហេតុផលខ្លះ។

ក្នុងឱកាសនោះ មូលហេតុដែលខ្ញុំដឹង នៅក្នុងឱកាសដែលខ្ញុំទៅសិក្សាវិជ្ជាពេទ្យប្រហែលជាខ្ញុំនិយាយប្រហែលទៅចុះ សូមទោស ព្រោះខ្ញុំមិនបានច្បាស់ទេ មិនបានថតទុក វាមិនបានដឹងថា រឿងហ្នឹងវាដល់ហ្នឹងទេ។ ឧបមាថា ប្រទេសកម្ពុជាវាមិនស្មានថាមានអីចឹង។ ប៉ុន្តែបើដឹងថាមានអីចឹងប្រហែលជាខ្ញុំចង់ចាំ ប៉ុន្តែអត់គិតធ្វើម៉េចឲ្យតែខ្លួនឯងរស់។ តែអ្វីក៏ដោយដែលខ្ញុំពិចារណាថា ប្រហែលជាខ្ញុំមិនបានរស់ ដោយហេតុផលមួយដែលខ្ញុំទៅរៀនពេទ្យនោះ ខ្ញុំឃើញព្រឹត្តិការណ៍នយោបាយមួយដែលកើតឡើងនៅក្នុងទីក្រុង -- ជាយក្រុងភ្នំពេញ គឺខ្ញុំទទួលឥទ្ធិពលនយោបាយមួយដែលកើតឡើងដោយការបង្កើតរបស់បក្សកុម្មុយនីស្តកម្ពុជា បង្កើតសាលានយោបាយវគ្គ ហៅថា វគ្គឆ្លងកាត់មហាលោតផ្លោះ មហាអស្ចារ្យនេះឯង។

[១៤:១៦:២៤]

អាការឆ្លងកាត់នេះ ខ្ញុំមើលទៅទិដ្ឋភាពបក្សនេះ នយោបាយនេះ ស្ទើរដល់ថ្ងៃនេះខ្ញុំអត់ចង់ហ៊ាននិយាយ វាទាល់តែអស់ ឲ្យលោកតុលាការអនុញ្ញាតឲ្យនិយាយ ឬក៏លោកមេធាវីអនុញ្ញាតឲ្យនិយាយទើបហ៊ាននិយាយបាន ព្រោះថា ហាក់ដូចជាមិនចង់ហ៊ាននិយាយទេ។ សូមប៉ុណ្ណឹង។ សូមទោស។

**ស៖** សូមបញ្ជាក់សំណួរឡើងវិញលោកអ៊ំ ប្រហែលជាមាន ការរៀបចំសំណួរមិនបានត្រឹមត្រូវ ខ្ញុំសូមឲ្យអ៊ំបញ្ជាក់ដំណើរអ្វីដែលអ៊ំបានធ្វើ និងអ៊ំបានបញ្ជាក់ហើយលោកអ៊ំមានសិទ្ធិសេរីភាពក្នុងការនិយាយនូវអ្វីដែលអ៊ំបានឆ្លងកាត់គ្រប់ចំណុចទាំងអស់។ លើកលែងតែអ្វីដែលជាការសន្និដ្ឋាន ឬក៏ការដែលអ៊ំបានទទួលដំណឹងពីអ្នកដទៃយកមកនិយាយ ហ្នឹងគឺជារឿង ដែលខុសឆ្គង។ ដូច្នេះ ខ្ញុំបញ្ជាក់សំណួរខ្ញុំឡើងវិញ ខ្ញុំគ្រាន់តែចង់ដឹងថា តើនៅក្នុងរយៈពេល ៩ខែ លើកឧទាហរណ៍ពីខែទី១ ទៅគេឲ្យអ៊ំធ្វើអី។ ខែទី២ ធ្វើអី ហើយបន្ទាប់មកទៀត ធ្វើអីអ៊ំអាចរៀបរាប់ស្ថានភាពហ្នឹងបានទេ ត្រង់ចំណុចនេះ?

[១៤:១៧:៤៣]

**ឆ៖** ត្រង់ចំណុចហ្នឹងខ្ញុំសូមមុននឹងនិយាយអី សូមបញ្ជាក់ប្រាប់ហេតុផលដែលខ្ញុំត្រូវជួប។ ដំបូងបង្អស់ទៅពីតំបន់២០ ទៅដល់ភ្នំពេញ ខ្ញុំទើបទទួលតំណែងមួយទៀត ក្នុងការងាររបស់ការសិក្សា គឺតំណែងប្រធានសិស្សដែលបានឡើងទៅរៀនភ្នំពេញ គឺខ្ញុំជាប្រធានសិស្ស។ អ៊ីចឹងការងារប្រធានផ្សេងអំពីសមាជិកធម្មតា អស់លោកប្រហែលជាធ្លាប់ដឹងហើយការងារអ៊ីចឹងៗ។ អ៊ីចឹងដាច់ខាតខ្ញុំត្រូវដឹងមុនគេ ប៉ានធ្វើមុនគេ ស្អីក៏ដោយត្រូវតែហ្វឹកហ្វឺនអ្នកដែលនៅក្រោមបញ្ជាឲ្យបានញឹកញាប់។ បើសិនណាកាលនោះ បើសិនជាយើងមិនធ្វើទេ យើងនឹងត្រូវទទួលវិបត្តិមុនឃើញ។ អ៊ីចឹងខ្ញុំតែងតែយកចិត្តទុកដាក់រក្សាជីវិតខ្លួនឯង។

[១៤:១៨:២៨]

អ៊ីចឹងការរក្សាពិបាកណាស់ វិធីពេលនុ៎ងពិបាករស់នៅមែនទែន ខ្ញុំនិយាយថាពិបាកណាស់។ បើសិនជាខ្លួនឯងមហាជនធម្មតាទៅ វាធម្មតា ប៉ុន្តែឯងបក្សដែរ ម្ល៉ោះហើយពិបាកមែនទែន។ សូមជម្រាបអស់លោក អានេះឯងហើយដែលខ្ញុំបាននិយាយអម្បាញ់មិញថា បើសិនជាខ្ញុំនិយាយអស់ទៅប្រហែលជាលោកមេធាវី ឬក៏លោកចៅក្រមមិនអនុញ្ញាត ក៏មិនដឹង។ អាហ្នឹង បើសិនជាការដឹងពិតគឺសុំនិយាយហ្នឹង បញ្ជាក់រឿងឃើញទៅចុះ! មិនយករឿងពិពណ៌នាមកប្រើទេ ខ្ញុំសូមនិយាយរឿងដែលឃើញ។ អ៊ីចឹងភាព ហេតុផលដែលឃើញសូមទោសទុកជាមុនបើសិនជាប៉ះពាល់នូវការដែលឃើញរបស់ខ្ញុំសូមអធ្យាស្រ័យ សូមទោសទុកជាមុនបាទ។

[១៤:១៩:១០]

**ស៖** អ៊ីចឹងលោកអ៊ំ សូមបញ្ជាក់អ្វីដែលលោកអ៊ំបានឃើញ និងលោកអ៊ំបានជួបហ្នឹងបាទ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

ខ្ញុំថា សំណួររបស់លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺជាការ -- ជាសំណួរនាំមុខ ហើយអាចធ្វើឲ្យសាក្សីហ្នឹងវង្វេង។

**លោក គីម ម៉េងឃី៖**

លោកប្រធាន ចំណុចនេះខ្ញុំគិតថា មិនមែនជាសំណួរនាំមុខទេ ហើយក៏មិនមានចេតនាធ្វើឲ្យក្តី

ខ្លួនឯងវង្វេងដែរ។ អ្វីដែលគាត់កំពុងតែឆ្លើយនេះ គឺគាត់មានការបារម្ភថា តើវាមានការប៉ះពាល់បានជាគាត់មិនហ៊ានឆ្លើយ ដូចជាគាត់លើកថាតើលោកចៅក្រមអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់ឆ្លើយ ឬមិនឆ្លើយ។ នេះជាការបារម្ភរបស់កូនក្ដីរបស់ខ្ញុំទេ មិនមែនមកពីរឿងដែលខ្ញុំសួរទេ។ បាទ សូមអរគុណលោកប្រធាន។

[១៤:២០:១០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរឲ្យប្រាកដ អំមិញនេះគឺសំណួរមិនច្រឡំទេ គឺសំណួរថា ក្នុងរយៈពេល ៩ខែហ្នឹង ឧទាហរណ៍ចាប់ពីខែ១ ខែ២ហ្នឹង តើលោកធ្វើអីខ្លះ? សាក្សីត្រូវឆ្លើយអំពីទង្វើរបស់គាត់ដែលគាត់បានធ្វើ។ គាត់មានបំណងឆ្លើយថា គាត់បានឃើញ។ អ៊ីចឹងសំណួរហ្នឹងមិនឆ្លើយតប -- ចម្លើយនេះមិនឆ្លើយតបទៅនឹងសំណួររបស់លោកទេ។ នៅពេលដែលសាក្សីមិនឆ្លើយតបនឹងសំណួរ គាត់ថាបានឃើញ។ លោកដូរសំណួរថា បញ្ជាក់ពីការបានឃើញវិញ។ នេះជារបៀបសំណួរ គឺអត់ប្រាកដប្រជានៅក្នុងការតាំងសំណួរបែបនេះ ធ្វើឲ្យវាកើតមានបញ្ហា។ សូមរៀបចំសំណួរឡើងវិញឲ្យបានជាក់លាក់ហើយគួរតែតាំងសំណួរខ្លីៗបានហើយ ពីព្រោះសាក្សីគាត់ចូលចិត្តនិយាយច្រើន។ គាត់និយាយមិនចំនឹងសំណួរដែលសួរទេ។

[១៤:២១:១៥]

ប្រសិនលោកប្រើសំណួរទូលាយឲ្យគាត់និយាយបែបនេះ ទំនងពេលវេលាដែលកំណត់ឲ្យធ្វើសវនាការចែកជូនទៅភាគីដែលពាក់ព័ន្ធនេះ ជាពិសេសលោកហ្នឹង គឺនឹងបន្តិចទៀត អង្គជំនុំជម្រះនឹងសួរថា តើពេលវេលាអស់នៅ? ព្រោះមួយល្ងាចនេះ គឺសម្រាប់អង្គជំនុំជម្រះនឹងសួរហើយ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះរំឭកអំមិញ ពីព្រោះសំណួរជាច្រើនឃើញថា វាមិនចូលទៅនឹងអង្គហេតុដែលពាក់ព័ន្ធនឹងការធ្វើសវនាការ ជាអង្គហេតុដែលក្នុងដែនយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវពិភាក្សាដេញដោល ហើយមានការចោទប្រកាន់ទៅលើជនជាប់ចោទ ១៧ មេសា ៧៥, ០៦ មករា ៧៩ និងអង្គហេតុដែលបានបំបែកមកជាសំណុំរឿង០០២/០១។

រៀបចំសំណួរឡើងវិញ ឲ្យបានស្រួល ហើយឲ្យបានជាក់ច្បាស់!

[១៤:២២:១៣]

**លោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** ខ្ញុំរៀបចំសំណួរពាក់ព័ន្ធនឹងចំណុចដែលលោកពូបានមកភ្នំពេញហ្នឹង។ តើនៅពេលដែលលោកពូបានមកធ្វើការនៅភ្នំពេញហ្នឹង លោកពូត្រូវបានគេចាត់តាំងឲ្យធ្វើអ្វីខ្លះ? ហើយនិងលោកពូបានឃើញអ្វីខ្លះនៅក្នុងមន្ទីរពេទ្យហ្នឹង? សូមលោកពូបញ្ជាក់?

**លោក អែម អឿន៖**

**ឆ៖** នៅក្នុងការសិក្សារបស់ខ្ញុំរយៈពេល១ឆ្នាំនោះ ការពិតដំណើរការតែងតាំងទៅពីតំបន់ គឺឲ្យខ្ញុំទៅរៀនពេទ្យ។ ប៉ុន្តែដល់ណោះ ដោយសភាពការណ៍វាវឹករវរ បានវាក្លាយទៅជា ខ្ញុំទៅជាពេទ្យផងរៀនផង។ អ៊ីចឹងពេលនោះ ខ្ញុំនៅក្នុងចន្លោះហ្នឹងដែរ ក៏ខ្ញុំទទួលទៅជាសិស្សមួយជាន់ទៀត។ ខ្ញុំថាសិស្សនយោបាយ នៅក្នុងប្លុកបុរីកីឡា។ អាពេលវគ្គនយោបាយ គឺគោលការណ៍របស់បក្ស ប្រហែលជាលោកចង់ឲ្យការផ្លាស់ប្តូររបៀបបក្ស ហៅថា មហាលោតផ្លោះ មហាអស្ចារ្យ បានកើតចេញ បង្កើតខ្លឹមសារសាលាហ្នឹងឆាប់រហ័ស។ ហើយវគ្គនោះមិនមែនជាវែងៗទេ គឺមិនវែងទេ ប្រហែលជា១អាទិត្យទៅ១០ថ្ងៃយ៉ាងយូរ។ អ៊ីចឹងការចូលសិក្សាហែ បានន័យថា ១ខែ ១វគ្គ ឬក៏១ខែ ២វគ្គ មានបន្តបន្ទាប់។ មានន័យថា ហើយថ្នាក់រៀននេះ បើតាមការចូលរួមរបស់ខ្ញុំ ឃើញទាបបំផុតគឺថ្នាក់ -- យើងនិយាយបច្ចុប្បន្នឥឡូវ បានន័យថាប្រធានមន្ទីររបស់ស្រុក ហ្នឹងទាប។ ហើយក្នុងកន្លែងនីមួយៗ ដាច់ខាតត្រូវមានអនុប្រធាន អនុប្រធានរហូតៗគ្រប់ទីកន្លែងទាំងអស់។ សូម្បីនៅទីក្រុងភ្នំពេញ អ៊ីចឹងបានខ្ញុំជាប់នាទីមួយឡើងទៅរៀនដោយសារខ្ញុំមាននាទីជាប្រធានសិស្ស។ ហើយក្នុងនោះទៀត ក៏ខ្ញុំមាននាទីជាសមាជិកបក្ស ម៉្លោះហើយ ខ្ញុំទៅ គឺថាដើរតួអ៊ីចឹងឯង គឺតាមដំណើរដែលបក្ស លោករៀបចំកន្លងមក។ អាហ្នឹងសូមជម្រាបលោកមេធាវី។

[១៤:២៤:២៩]

**ស៖** តើលោកសិក្សានយោបាយហ្នឹង សិក្សាអំពីអ្វីខ្លះដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី -- លោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្ដាយដែលកាត់ផ្ដាច់ជាថ្មីម្ដងទៀត។ តើអាចបន្ថយល្បឿនបានទេ លោកមេធាវី គឺថានៅពេលសួរឆ្លើយនោះសូមឲ្យបន្ថយល្បឿនបន្តិច ហើយលោកសាក្សីៗក៏អ៊ីចឹងដែរ សូមនិយាយឲ្យបានយឺតៗបន្តិច ដើម្បីងាយស្រួលដល់ការបកប្រែ។

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណចំពោះការកត់សម្គាល់របស់មេធាវីការពារក្ដី។ អំមិញហ្នឹង គឺមិនមែនសាក្សីទេ គឺជាដើមបណ្ដឹងរដ្ឋប្បវេណីបាទ។ ខុសគ្នារវាងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីនៅទីនេះ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** ហើយខ្ញុំសូម សួរឡើងវិញ សួរមួយៗ ហើយសូមឲ្យលោកអ៊ំឆ្លើយឲ្យបានយឺត ដើម្បីឲ្យធានាការបកប្រែឲ្យបានល្អ។ ថាតើសិក្សាផ្នែកនយោបាយហ្នឹង គេសិក្សាអំពីអ្វីខ្លះ?

[១៤:២៦:០៦]

**លោក អែម អឿន៖**

**ឆ៖** សិក្សាក្នុងល្បត់ដែលខ្ញុំបានចូលសិក្សានយោបាយក្នុងបុរីកីឡានេះ បើតាមខ្ញុំចាំបានក្នុងប្រធានបទគឺនិយាយសំខាន់អំពី "មហាជ័យជន្នះរបស់បក្ស បដិវត្តន៍កម្ពុជា"។ ត្រង់ហ្នឹងៗ ខ្ញុំតែងតែចោទសួរថា ដូចម្ដេចដែលហៅថា "បក្សលោតផ្លោះ មហាលោតផ្លោះ?" ព្រោះខ្ញុំចង់ដឹងៗថា ដូចម្ដេចដែលហៅថា "មហាលោតផ្លោះ?" ដល់អ្នកដឹកនាំអត្ថាធិប្បាយក្នុងឱកាសនោះ បានបញ្ជាក់ថា "មហាលោតផ្លោះ" គឺយើងលោតពីប្រជាជាតិឡើងទៅកុម្មុយនីស្ដ។ នេះត្រង់ពាក្យថា"មហាលោតផ្លោះ"បាទ។ នេះជាការជួប -- ខ្ញុំសូមបញ្ជាក់បន្ថែម នេះជាការជួប -- ខ្ញុំដើរទៅឃើញពេលកំពុងរៀនឃើញហើយសូមបន្ថែមបាទ។

[១៤:២៧:០០]

**ស៖** បាទ ហើយមានអ្នកណាដែលលោកពូថា ជាអ្នកប្រាប់អំពីនយោបាយហ្នឹង វាគ្មិនដែលបង្ហាញអំពីមេរៀននយោបាយហ្នឹងជានរណាដែរ?

**ឆ៖** ដំណើរក្នុងពេលវេលានោះ បើតាមៗខ្ញុំចាំបាន គឺសាលាហ្នឹងបើកនៅវគ្គសិក្សានយោបាយជាន់ខ្ពស់នៅបុរីកីឡាក្រោមការរៀបចំរបស់ៗអ្នកស្រី យុន យ៉ាត។ លោកជំទាវ យុន យ៉ាត។

**ស៖** ក្រៅពីលោកស្រី យុន យ៉ាត តើមានអ្នកណាទៀតដែលជាអ្នកធ្វើអត្ថាធិប្បាយក្នុងវគ្គសិក្សា

ហ្នឹងដែរឬទេ?

[១៤:២៨:២២]

**ឆ៖** ក្នុងនោះ បើតាមខ្ញុំឃើញអ្នកដែលបានបង្ហាត់បង្រៀនខ្ញុំផ្ទាល់តែម្ដង គឺ -- បើនិយាយថ្នាក់ដឹកនាំជាន់ខ្ពស់នៅឱកាសនោះ មើលទៅឃើញលោកមហាៗ ស្អី ប្រើពាក្យមិនបាន ហៅថា បានន័យថា កាលណោះ ខ្ញុំហៅគាត់ហៅថា តា សមមិត្តៗ ប៉ុល ពត មួយ, មួយទៀតលោក លោកតា នួន ជា នេះមួយ, មួយទៀតលោក ខៀវ សំផន មួយ។ ពេលឱកាសនោះ ខ្ញុំមិនបានឃើញច្បាស់ថាមានលោក អៀង សារី ដែរឬទេអត់ទេ តែខ្ញុំមិនបានពិនិត្យទេដោយសារខ្ញុំមិនបានពិនិត្យ។ ឱកាសនោះដែរ ក៏ខ្ញុំបានឃើញវត្តមានរបស់លោក ខៀវ សំផន និង លោក ហ៊ូ នឹម ដែរ នៅក្នុងឱកាសកាលខ្ញុំសិក្សានៅពេលនុ៎ង។

**ស៖** តើលោកអ៊ំអាចរៀបរាប់បានទេអំពីវាគ្មិនមួយៗ ដែលមានឈ្មោះដូចលោកអ៊ំរៀបរាប់ថាបានចូលរួមហ្នឹង ដូចជាលោក ប៉ុល ពត, នួន ជា, ខៀវ សំផន, ហ៊ូ នឹម ហ្នឹង តើម្នាក់ៗហ្នឹងគាត់និយាយអីខ្លះនៅក្នុងហ្នឹង?

[១៤:២៩:៥០]

**ឆ៖** ក្នុងឱកាសនោះ ខ្ញុំសូមបញ្ជាក់រឿងៗដែលខ្ញុំឃើញ គឺបានន័យថា ឡើងមានវត្តមានជាថ្នាក់ដឹកនាំច្រើន។ ស្គាល់ខ្លះ ខ្ញុំមិនស្គាល់ខ្លះបានរាប់ អ្នកស្គាល់មិនស្គាល់ខ្ញុំអត់រាប់ទេ។ សូមទោស ស្គាល់ខ្ញុំនិយាយ បើមិនស្គាល់មិននិយាយ ។ ក្នុងនោះ អ្នកដែលបានលោក ពាក្យមានពាក្យសម្ដីខ្ញុំនិយាយក្នុងឱកាសនោះ គឺមានលោក នួន ជា, លោក ខៀវ សំផន, និង កាលណោះមានលោកស្រីនៅឬអត់ទេបច្ចុប្បន្ន គឺអ្នក -- លោកស្រី ឡេង សី ក្នុងមានជាគាត់ជាខាងផ្នែកសង្គមកិច្ចនៅពេលនុ៎ង។ តែអ្នកនិយាយមុនគេបង្អស់ គឺលោកមេបក្ស គឺលោក ប៉ុល ពត ហ្នឹងតែម្ដង។

**ស៖** លោក ប៉ុល ពត និយាយអីខ្លះ នៅក្នុងពេលនោះលោកអ៊ំ?

**ឆ៖** ត្រង់ហ្នឹង បើសិនខ្ញុំនិយាយទៅហាក់ដូចជាជាន់គ្នា ប៉ុន្តែដំណើរការពិត ខ្ញុំចាំបានចំណុចៗដែលការចាប់អារម្មណ៍អ្នកទាំងបីនាក់។ គាត់មុននឹងនិយាយបន្តៗគ្នា គាត់ច្រើនប្រើការ ប្រើប្រធានបទភ្ជាប់។ ភ្ជាប់យ៉ាងម៉េច? ឧបមាថាៗខ្ញុំឡើងនិយាយអ៊ីចឹង បានខ្ញុំមុននឹងនិយាយខ្ញុំហៅថាដូចជាប្រសាសន៍ ឧបមាទេ សូមទោស។ ឧបមាថា បានប្រសាសន៍ ឧបមាលោក ខៀវ សំផន បានប្រសាសន៍ ហើយលោកនិយាយថា លោកបាន -- ខៀវ សំផន បាននិយាយក្នុងឱកាស បានថ្លាថ្លែងនេះ និយាយអស់

ហើយអ៊ីចឹង យើងគួរតែស្ដាប់បានហើយឬនៅ បានលោក ខៀវ សំផន លោកមានបន្ថែមតាមគោលការណ៍របស់គាត់បន្ថែមលើពាក្យសម្ដីនិយាយខាងដើមរបស់លោក នួន ជា។ ឧបមាយើងនិយាយរឿងឧបមា សូមទោសឧបមា។ ដើម្បីស្រួលស្ដាប់និយាយឧបមា យើងនិយាយយកពាក្យពិតមកចាក់វាអត់បានព្រោះថាអត់មានសំឡេង។

[១៤:៣១:៥១]

អ៊ីចឹង ដល់កាលណានិយាយពាក្យហ្នឹង ដូចជានិយាយសាថ្មីដដែលៗ ព្រោះថាមុននឹងលោក អស់លោកហ្នឹងនិយាយអីទៅ គាត់តែងបកស្រាយរឿងហ្នឹងមួយបន្ទាត់ពីរបន្ទាត់សិន បាននិយាយបន្តទៀត។ អ៊ីចឹងយើងដល់ខ្ញុំបកស្រាយរឿងទៅហាក់ដូចនិយាយដដែលៗ។ អ៊ីចឹងប្រធានបទរបស់អ្នកដែលឡើងធ្វើអត្ថាធិប្បាយនៅពេលនោះ ចាប់ផ្ដើមដំបូងបំផុតគឺលោកលេខាបក្ស គឺលោក ប៉ុល ពត គាត់ប្រើប្រាស់ក្នុងនាមជាយើងអ្នកកុម្មុយនីស្ដត្រូវឲ្យដឹងឲ្យច្បាស់ថា តួនាទីរបស់ជនជាកុម្មុយនីស្ដធ្វើអី។ ដើម្បីឲ្យស្របទៅតាម "បក្សៗមហាលោតផ្លោះ មហាអស្ចារ្យ" តើមិត្តជាបក្សត្រូវធ្វើអីខ្លះ? នេះជាគោលការណ៍របស់គាត់កាលណោះ។ អ៊ីចឹងលោកបានអត្ថាធិប្បាយអំពីដំណើររបស់បក្សដែលត្រូវធ្វើ។

[១៤:៣២:៣៧]

ធាតុពិតអស់លោក សូមលោកធ្វើឲ្យចំគោលដៅពាក្យដែលថា "មហាលោតផ្លោះមហាអស្ចារ្យ"។ ហើយដល់ខ្ញុំវែកសួរថា "មហាលោកផ្លោះ" ជាស្អី? ហើយបានអស់មិត្តដែលរៀនសូត្រជាមួយគ្នាស្គាល់ថា អេ "មហាអស្ចារ្យ មហាលោតផ្លោះ" គឺជាពាក្យថាលោតចេញពីៗគឺថារបត់ នៃបក្សប្រជាជាតិបក្សប្រជាធិបតេយ្យ បានឆ្លងទៅដល់កុម្មុយនីស្ដ។ តែយើងអត់មានទេ ប្រជាជនធិបតេយ្យ គឺឆ្លងទៅដល់កុម្មុយនីស្ដតែម្ដង។ អានេះឯង ដែលហៅថា "លោតផ្លោះ" ដល់ត្រង់ហ្នឹង លោក ខៀវ សំផន បានបញ្ជាក់ថា "មិត្ត នេះឯងហៅថាៗផ្លូវបត់ទី៣។ អ៊ីចឹងបើសិនជាមិត្តណាមិនបត់មិនទាន់មានន័យថា ទោះបីអ្នកនោះជាមិត្តក៏ដោយ ជាបងក៏ដោយ ជាប្អូនក៏ដោយ ឲ្យតែអ្នកឯងបត់មិនទាន់ មានន័យថាឈ្មោះថាក្បត់ បើសិនជាក្បត់បក្សត្រូវតែកម្ទេច។ នេះជាភាសារបស់លោក ប៉ុល ពត។ អាហ្នឹងហើយដល់ពេលលោក នួន ជា គាត់មកមានប្រសាសន៍ម្ដងទៀត គាត់និយាយអារបត់ហ្នឹងបានមួយៗបន្ទាត់ពីរបន្ទាត់នេះ បានគាត់ឈានទៅអារបត់មួយទៀតរបស់គាត់។ ឯលោកតា ខៀវ សំផន ក៏គាត់និយាយស្រដៀងអ៊ីចឹងដែរ។ ចេះតែបន្ថែមការពិតទៅ យើងមើលទៅហាក់ដូចជា -- បើយើងមិនបានដកមកដាច់ភ្លាមទេ ហាក់ដូចជាតែមួយ។ ប៉ុន្ដែក្នុងឱកាសនេះ ខ្ញុំចង់ឲ្យដាច់ដែរថា ប្រសាសន៍របស់លោក ខៀវ

សំផន យ៉ាងម៉េច? ប្រសាសន៍របស់លោក នួន ជា យ៉ាងម៉េច? ប្រសាសន៍របស់លោក ខៀវ សំផន -- របស់លោក ប៉ុល ពត យ៉ាងម៉េច។

[១៤:៣៤:១១]

**ស៖** តើនៅក្នុងវគ្គនយោបាយហ្នឹង តើប្រព្រឹត្តទៅប៉ុន្មានថ្ងៃដែរ ហើយមានអ្នកចូលរួមប្រហែលប៉ុន្មាននាក់ដែរទៅនៅពេលនោះ?

**ឆ៖** ក្នុងសាលានេះ បើតាមខ្ញុំមិនអាចថាចាំបានទេ ថាតាមដំណើរខ្ញុំគិតឃើញថា ប្រហែលជាលើៗពី១អាទិត្យ ឬក្រោយ១០ថ្ងៃ។ បាទ សាលាឆាប់បានបើកមួយទៀត។ សូមបញ្ជាក់បន្ថែមសំណួរអំមិញ ខ្ញុំភ្លេចថា ពីស្អីខ្លះបាទ?

**ស៖** ចំនួនមនុស្ស ហើយនិងចំនួនថ្ងៃ។

**ឆ៖** សូមបញ្ជាក់បន្ថែមចំនួនមនុស្សខ្ញុំមិនបានរាប់ទេ។ ប៉ុន្តែបើតាមការប្ញូកបោះទៅតាមដំណើរដែលកំណត់ផង ប្ញូកបោះទៅតាមការឃើញជាក់នឹងភ្នែកខ្លះ គឺប្រហែលជាក្រោម២.០០០ ឬលើសតិចតួច។ នេះទិដ្ឋភាពជាក់ស្តែង ព្រោះថា បានខ្ញុំនិយាយពាក្យនេះ ព្រោះថាអាការរៀននេះ បើថ្នាក់ស្រុក គឺហៅថា នាយកដ្ឋានស្រុករបស់គេនោះ គេយកចាប់ -- ប្រធាន អនុ, ប្រធាន អនុ ហើយកន្លែងស្រុកមួយៗច្រើន ហើយយើងទូទៅមួយប្រទេស។ អ៊ីចឹងចាប់ផ្តើមយកពីថ្នាក់ស្រុកឡើងទៅរៀនសូត្របាទ។

[១៤:៣៥:៤៧]

**ស៖** តើនៅក្នុងពេលនោះដែរ លោក នួន ជា គាត់ធ្វើបទអត្ថាធិប្បាយ ផ្តោតសំខាន់លើចំណុចអ្វីបន្តពី ប៉ុល ពត?

**ឆ៖** លោក នួន ជា បន្តពី ប៉ុល ពត មកគឺមានប្រធានបទមួយរបស់គាត់ គឺលោកធ្វើជាគោលការណ៍ពង្រឹងៗ ជនជាកុម្មុយនីស្ត ឲ្យជនកុម្មុយនីស្តធ្វើការពង្រឹង។ ហើយសំខាន់បំផុត គាត់វែករកមើលមុខថា បុគ្គលណា ដែលឈ្មោះហៅថា ស៊ីរូងផ្ទៃក្នុងរបស់បក្ស នៅក្នុងពួជផ្ទៃក្នុងរបស់បក្ស។ អ៊ីចឹងលោកបានមានប្រសាសន៍ យ៉ាងរឹងប៉ឹង ត្រង់ថាយ៉ាងណាក៏ដោយ ក្នុងនាមយើងជាអ្នកដឹកនាំត្រូវតែស្គាល់ឲ្យបានច្បាស់ថា អ្នកណាខ្លះ ស្គាល់ អ្នកណាខ្លះចង់មានគំនិតស៊ីរូងផ្ទៃក្នុងប្រឆាំងនឹងបក្ស។ ចូលអស់មិត្តជាបក្សមើលឲ្យបានច្បាស់ត្រង់ហ្នឹង ឲ្យបានច្បាស់ទើបអ្នកឯងយល់ថា អ្នកឯងជាអ្នកអនុវត្តស្គាល់ហេតុផល បាទ។

**ស៖** តើលោក នួន ជា គាត់មានពន្យល់បន្ថែមអំពីថាតើអ្នកណាខ្លះ ដែលចាត់ទុកថាជាអ្នកស៊ីរូង

ផ្ទៃក្នុងរបស់បក្សដែរឬទេ នៅពេលធ្វើការបង្ហាញនៅពេលនោះ?

**ឆ៖** ត្រង់ហ្នឹងៗបើតាមដំណើរដែលខ្ញុំគិតឃើញក្នុងឱកាសនោះ សំដៅទៅលើអ្នកដែលទី១ អ្នកដែលមានឋានៈនាទីក្នុងរបបចាស់របស់គេ បានន័យថា ក្នុងរបបសង្គមរាស្ត្រនិយមផង ក្នុងរបប លន់ នល់ ផង។ បានន័យថា ឲ្យពួកអ្នកមើលបច្ចុប្បន្នមើលឃើញពួកអស់ហ្នឹង។ ពិសេសបំផុតគោលបំណងត្រង់ចំទៅលើពួកនិស្សិត និងបញ្ញវន្ត។ ពិសេសបំផុតអ្នកដែលបានទៅសិក្សាក្រៅប្រទេស។ ហ្នឹងសូមជម្រាបលោកមេធាវី។

[១៤:៣៧:៥៦]

**ស៖** បាទ បន្តទៀតតើលោក ខៀវ សំផន គាត់បាននិយាយ ធ្វើបទបង្ហាញអ្វីខ្លះនៅក្នុងវគ្គបណ្តុះបណ្តាលនោះលោកពូ?

**ឆ៖** មុននឹងនិយាយបន្តទៅមុខទៀត លោក ខៀវ សំផន គាត់ក៏បានប្រើពាក្យថា ចូរមិត្តមើលទៅ ព្រោះប្រទេសយើងៗត្រូវតែអនុវត្តទៅតាមការប្រើប្រាស់ផ្លូវបត់ទី៣នេះដែរ។ ដូចគ្នាបានគាត់លើកឡើងប្រធានថា ក្នុងនាមគាត់ជាគណៈប្រធានរដ្ឋ ត្រូវតែទទួលខុសត្រូវនូវការធ្វើការងារឲ្យបានរីកចម្រើន បានន័យថា គាត់ៗឲ្យមើលគោលការណ៍របស់អ្នកដែលមានគំនិត មានគំនិតមិនពេញចិត្តនឹងបក្ស មិនពេញចិត្តនឹងគោលការណ៍របស់បក្ស ដាច់ខាតមិត្តមើលឲ្យច្បាស់ យើងចាប់ផ្តើមមិត្ត មិនចាំបាច់មើលពីធំទេ សូម្បីតែការអនុវត្តប្រចាំថ្ងៃចាប់តាំងពីការស្លៀកពាក់នេះទៅ។ អស់លោកមើលឃើញឲ្យច្បាស់ ឲ្យហើយ បានន័យថា បើបុគ្គលណាប្រើប្រាស់ខោអាវខ្ជះខ្ជាយ បើបុគ្គលណាប្រើប្រាស់សម្ភារៈមិនគិតពីផលប្រយោជន៍ រក្សា ហៅថាសន្សំសំចៃ អ្នកនោះឯងហើយ ជាអ្នកក្បត់បដិវត្តន៍ អ្នកនោះឯងហើយជាអ្នក គេថា គឺអ្នកចង់ធ្វើវិទ្ធេទកម្មជាមួយបក្ស។ អ៊ីចឹងសូមអស់មិត្តមើលឲ្យច្បាស់ត្រង់ហ្នឹង។ នេះជាការងារតូចមួយដែលខ្ញុំដកស្រង់មកនិយាយបាទ។

[១៤:៣៩:៣១]

**ស៖** លោកអ៊ំអាចពន្យល់ឲ្យបានលម្អិតជាងនេះទៀតបានទេ ថាតើអ្វីទៅដែលគាត់ពន្យល់ថាជាការខ្ជះខ្ជាយជាការក្បត់បដិវត្តន៍ស្អីហ្នឹង តើនៅក្នុងបទបង្ហាញហ្នឹងមាននិយាយលម្អិតដែរឬទេពីបញ្ហាហ្នឹង?

**ឆ៖** សូមបញ្ជាក់បន្ថែមការលម្អិតច្រើនណាស់ តែខ្ញុំសូមដកពាក្យខ្លះៗ កុំឲ្យថាយើងធ្វើខុស ថាប្រធានអ៊ីខ្ញុំសូមនិយាយខ្លះៗ ទិដ្ឋភាពដែលខ្ញុំឃើញ។ ខ្ញុំនិយាយពីរឿងតូច ដែលខ្ញុំថាអំមិញពីរឿងតូច

រហូតដល់ធំ។ គាត់ចាប់ផ្ដើមយក បើមនុស្សស្រីចាប់ផ្ដើមការប្រើប្រាស់ម្ជុលក៏ដោយ ឡេវអាវក៏ដោយ ដែលប្រើប្រាស់ខ្ជះខ្ជាយហៅថា១ ប្រឆាំងនឹងបក្ស ហ្នឹងឈ្មោះហៅថា អ្នកប្រឆាំងអ្នកក្បត់បដិវត្តន៍។ នេះបើនិយាយពីស្ត្រីភេទ។ បែរទៅជាបុរសវិញ តាំងពីការប្រើប្រាស់នង្គ័ល រនាស់, នង្គ័ល រនាស់ ឧបករណ៍ គោក្របី បើប្រើទៅធ្វើការមិនកើត ឬក៏មនុស្សឧស្សាហ៍ឈឺថ្កាត់ ក៏ចាត់ទុកទៅជាលក្ខណៈ ថាជាអ្នកប្រឆាំងនឹងបក្សដែរ។ ហ្នឹងសូមលោកមេធាវីពិចារណាចុះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលសម្របសម្រួល ផ្តល់កន្លែងសម្រាកសម្រាប់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះ -- នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិការជូនទៅក្រុមសហមេធាវីនាំមុខតំណាង ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** បាទ ខ្ញុំសូមបន្តសំណួរជូនដល់លោកអ៊ំ អែម អឿន ហើយសូមឲ្យលោកអ៊ំឆ្លើយម្ដងមួយៗ ដើម្បីឲ្យមានការបកប្រែបានច្បាស់លាស់។ ពាក់ព័ន្ធទៅនឹងបទអន្តរាគមន៍របស់លោក ខៀវ សំផន ក្រៅពីអ្វីដែលលោកអ៊ំបានរៀបរាប់ពីដើមខាងមុន តើលោកអ៊ំមានអ្វីចង់បន្ថែមទៀតទេ ពាក់ព័ន្ធនឹងបទ

E1/113.1

អន្តរាគមន៍របស់លោក ខៀវ សំផន នៅក្នុងវគ្គសិក្សានយោបាយនៅពេលនោះ?

[១៥:០២:៥៣]

**លោក អែម អឿន៖**

**ឆ៖** សូមសួរចម្លើយម្តងទៀត ប្អូកបន្ថែមអី? ការបន្ថែមអត់យល់ពាក្យថា--

**ស៖** នៅមុនពេលសម្រាកហ្នឹង លោកអ៊ំបាននិយាយអំពីរឿងដែលលោក ខៀវ សំផន បកស្រាយពាក់ព័ន្ធទៅនឹងរឿងការក្បត់បដិវត្តន៍ ហើយឧទាហរណ៍សំដៅទៅលើ តើមនុស្សស្រី ហ្នឹងគាត់មានការប្រើប្រាស់ខ្លះខ្ជាយម្ហូល ធ្វើឱ្យខូចម្ហុល បុរសហ្នឹងធ្វើឱ្យនង្គ័លហ្នឹងចាត់ទុកថា ជាអ្នកដែលក្បត់បដិវត្តន៍ ហើយតើលោកអ៊ំមានចំណុចអ្វីដែលលោកអ៊ំបានរៀនសូត្រអំពីគាត់នៅពេលនោះ លើសពីអ្វីដែលលោកអ៊ំបានជម្រាបនៅអង្គសវនាការ មុនពេលឈប់សម្រាកនេះដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់តែចង់បន្ថែមពាក្យមួយម៉ាត់ដែរទេ មិនច្រើនទេ ព្រោះថា ចំណុចដែលយើងប្រើនុំងមានលក្ខណៈ -- អាហ្នឹងខ្ញុំជឿថា លោកតាមានបានឃើញដែរអត់ ចំណុចដែលថា ពាក្យដែលថា "បើបក្សឱ្យធ្វើអីយើងត្រូវតែគោរពធ្វើតាមជាដាច់ខាត"។ តើខ្ញុំចង់ដឹងថា អត្ថន័យទាំងអស់ហ្នឹង ខ្ញុំមិនយល់ពីថា ត្រូវតែធ្វើ ចុះបើធ្វើមិនកើត អ៊ីចឹងគោលបំណងទាំងអស់នេះ ខ្ញុំចេះតែឆ្ងល់ ពិចារណា តែខ្ញុំមិនដឹងសួរពីណា មិនប៉ានសួរ ពីនោះមកដល់ណេះ ទើបឱកាសនេះខ្ញុំសួរ ខ្ញុំចង់ដឹងបាទ។

[១៥:០៤:៥៥]

**ស៖** លោកអ៊ំលើកជាសំណួរ ឬក៏ចម្លើយអំមិញហ្នឹង ខ្ញុំស្តាប់ដូចជាលើកជាសំណួរទេ មិនមែនចម្លើយអ្វីដែលលោកអ៊ំចង់បន្ថែមនោះទេបាទ។ សូមអរគុណ។

**ឆ៖** ខ្ញុំដូចអត់មានសំណួរបន្ថែមទេ -- ចម្លើយបន្ថែមទេ។

**ស៖** បាទ ចំណុចបន្ទាប់ទៀត លោកអ៊ំបានបញ្ជាក់ថា លោកអ៊ំរៀននូវវគ្គនយោបាយរយៈពេលហ្នឹង គឺ១សប្តាហ៍។ ខ្ញុំចង់សួរថា តើរយៈពេលដែលសេសសល់ក្រៅពី១សប្តាហ៍ហ្នឹង លោកអ៊ំធ្វើការនៅមន្ទីរពេទ្យនៅភ្នំពេញហ្នឹង តើពិតជាអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ការងារដែលនិយាយថា ១សប្តាហ៍ក្រោយពេលចប់ពីវគ្គនយោបាយនេះ គឺខ្ញុំវិលទៅរកមន្ទីរវិញ ដោយសារឱកាស ខ្ញុំវាមានពេលវេលាមករៀនប៉ុណ្ណឹងឯង។ មិនមែនខ្ញុំសុំទេ តែការពិតទៅភារកិច្ចនាទីត្រឹមប៉ុណ្ណឹង។

[១៥:០៦:៣១]

**ស៖** តើប្រធានមន្ទីរពេទ្យដែលលោកអ៊ំទៅធ្វើការហ្នឹង គាត់ឈ្មោះអី ហើយនៅក្នុងមន្ទីរពេទ្យហ្នឹង លោកអ៊ំធ្វើនៅក្នុងផ្នែកអីដែរ?

**ឆ៖** ក្នុងឱកាសដែលខ្ញុំសិក្សា ក្នុងការធ្វើរបស់ខ្ញុំ។ ទី១ ជួយអប់រំផ្នែកនយោបាយជាមួយនឹងឋានៈតំណែងរបស់ខ្លួន។ ទី២ គឺប្រឹងសិក្សារៀនសូត្រអំពីវិជ្ជាដែលបក្សបានតែងតាំងមកពីក្រោម មកពីក្រោមមកដល់ភ្នំពេញ។ ហើយមួយទៀត គឺខិតខំយកចិត្តទុកដាក់សិក្សារៀនសូត្រហ្នឹងឯង ឲ្យបានចេះដឹង។ ក្រៅពីនេះ ខ្ញុំមិនមាននាទីធ្វើអីទេ មាននាទីតែមួយគឺខំប្រឹងរៀនសូត្រ និងមើលកូន --អ៎!មិនមែនមើលកូនទេ មើលតួនាទីជាប្រធាននៃសិស្ស។ អាហ្នឹងការពិត។

**ស៖** តើលោកអ៊ំត្រូវបានគេចាត់តាំងឲ្យទទួលបន្ទុកក្នុងការថែទាំអ្នកជំងឺដែរឬទេ?

**ឆ៖** ត្រង់ការទទួលបន្ទុកថែទាំអ្នកជំងឺ ពេទ្យទាំងអស់សុទ្ធមាននាទីថែទាំអ្នកជំងឺ។ ប៉ុន្តែក្នុងឱកាសនោះទៅតាមវេន។ មានដាក់កម្មវិធី ដាក់វេន។ អ្នកខ្លះធ្វើការវេនថ្ងៃ អ្នកខ្លះធ្វើការវេនយប់។ ប៉ុន្តែពួកខ្ញុំសុទ្ធយប់ទាំងអស់ ព្រោះថ្ងៃរៀន។

**ស៖** លោកអ៊ំអាចរៀបរាប់អំពីស្ថានភាពអ្នកជំងឺនៅទីនោះបានទេ មានមនុស្សប្រភេទណាខ្លះ? ក្មេង ចាស់ ប្រុសស្រី ប្រជាជនសាមញ្ញ ឬក៏មន្ត្រី ឬក៏កម្មាភិបាល ឬក៏អ្នកណាខ្លះ ដែលជាអ្នកជំងឺនៅទីនោះ?

**ឆ៖** ជំងឺដែលមាន -- អ្នកដែលមានជំងឺឡើងទៅដល់មន្ទីរពេទ្យដែលថា ១៧ មេសា ហ្នឹងភាគច្រើនជាបុគ្គលិក មន្ត្រីកម្មករដែលធ្វើការនៅទីក្រុងភ្នំពេញ។

[១៥:០៩:៣៣]

**ស៖** តើអ្នកទាំងអស់ហ្នឹង ទទួលការព្យាបាលយ៉ាងម៉េចដែរ មានប្រសិទ្ធភាពដែរឬទេ? ហើយតើមានអ្នកជំងឺដែលស្លាប់ដោយសារធ្វេសប្រហែសដែរឬទេ?

**ឆ៖** ការធ្វេសប្រហែស បើតាមជាក់ស្ដែងតែខ្ញុំនិយាយមើលអត់ឃើញទេ គ្រាន់តែឮគេថាអីចឹងការស្លាប់ដោយការមិនយកចិត្តទុកដាក់ អាចនឹងមានស្លាប់។ តែរឿងពិតនៅតែឮទេ មិនបានឃើញនឹងភ្នែក ដូច្នេះខ្ញុំអត់និយាយទេ។

**ស៖** ចុះពាក់ព័ន្ធទៅនឹងការផ្ដល់ថ្នាំឲ្យអ្នកជំងឺ តើគេបានថ្នាំមកពីណា ដើម្បីផ្ដល់ និងចាក់ឲ្យអ្នកជំងឺនៅក្នុងមន្ទីរនោះ?

**ឆ៖** ការផ្ដល់ថ្នាំព្យាបាល បើតាមមន្ទីរពេទ្យ គ្រប់មន្ទីរពេទ្យតែងតែមានគេហៅថា ឱសថៗ

ប៉ុន្តែឥឡូវហៅថា ឱសថស្ថាន ប៉ុន្តែអានោះគេហៅថា "ផ្នែកឱសថ" អ្នកឃុំគ្រងឱសថគឺជាអ្នកបើក នៅក្នុងពេទ្យតែមួយ អ្នកណាខ្លះនៅផ្នែកឱសថ ខ្លះខាងផ្នែកព្យាបាល ខ្លះខាងឱសថបូរាណ ខ្លះខាងឱសថសម័យ។ អ៊ីចឹងថ្នាំដែលបានមក បើតាមការប្រើប្រាស់របស់ខ្ញុំពិតជាក់ស្តែងគឺក្នុងៗអំឡុងចន្លោះពេលដែលបូព៌ាមិនទាន់មានការប្រែប្រួលស្ថានការណ៍នយោបាយ ប្រើថ្នាំដូចជាមានលក្ខណៈគ្រប់គ្រាន់ពិសេសបំផុតគឺជួរកម្មាភិបាលមិនសូវខ្វះខាតទេថ្នាំ គឺគាត់បើក បើតាមការដឹងរបស់ខ្ញុំគឺ ថ្នាំទាំងអស់គឺបានមកពីការសេសសល់នៃរបបខាងដើម គឺរបប លន់ នល់។ យើងបានប្រមូលមកទុកដាក់យកមកប្រើនោះ ហើយប្រើ ដល់សួរទៅតាមដំណើរ ដល់ខ្ញុំពិចារណាឃើញទៅ គឺថ្នាំដែលប្រមូលយកមកទុកដាក់ហើយយើងយកប្រើ ថ្នាំដែលសេសសល់ពី -- ទាំងថ្នាំដែលគេលក់ដូរ ទាំងថ្នាំរបស់ពេទ្យខាងដើមមកការសេសសល់ពីខាងដើម។ ឯការរកចំណូលថ្មី ខ្ញុំដូចជាមិនឃើញថាប្រទេសណាជួយ។

[១៥:១២:១៧]

**ស៖** តើនៅក្នុងមន្ទីរពេទ្យ តើមានការវះកាត់ ពិសោធមនុស្សដែរឬទេនៅទីនោះ?

**ឆ៖** នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហៅថា ពេទ្យ១៧មេសានេះ កន្លែងនុំងខ្ញុំមិនឃើញទេ ហើយបើធាតុពិត បើនិយាយពីពេទ្យក្នុង ២០ តំបន់២០ អំ! ក្នុងភ្នំពេញក្នុងចំណោមពេទ្យធំជាង គឺពេទ្យ១៧មេសានេះឯង។ ឯពេទ្យកុមារ នៅពេទ្យកាល់ម៉ែតហ្នឹងពេទ្យកុមារ។ ពេទ្យធំជាងបង្អស់នៅទីក្រុងភ្នំពេញគឺពេទ្យរុស្ស៊ីហ្នឹងឯង មានប៉ុណ្ណឹង។ ឯការធ្វើ ការវះកាត់ពិសោធ ខ្ញុំផ្ទាល់នៅទីនេះអត់បានឃើញទេ ប៉ុន្តែទិដ្ឋភាពហ្នឹងខ្ញុំឃើញនៅមូលដ្ឋានវិញ។ គឺនៅកន្លែងតំបន់របស់ខ្ញុំ ពេលខ្ញុំទៅវិញ ខ្ញុំឃើញអ៊ីចឹងមែន យកអ្នកដែលត្រូវអស់ទោស ប្រហារជីវិតគឺត្រូវយកឲ្យអ្នកសិក្សារៀនសូត្រវះដោយនៅៗ វះមើលតែម្តង។ ហ្នឹងភាពយើងឃើញជាក់ស្តែង។

[១៥:១៣:២៧]

**ស៖** អ៊ីចឹងបានន័យថា ក្រោយពេលដែលលោកអំទៅមូលដ្ឋានវិញបានឃើញការពិសោធមនុស្ស។ តើគេយកមនុស្សទាំងរស់ទៅពិសោធតែម្តង ឬក៏សាកសពដែលគេសម្លាប់ហើយ យកទៅពិសោធ?

**ឆ៖** ក្នុងហ្នឹង ខ្ញុំសូមនិយាយរឿងពិត កន្លែងដែលខ្ញុំធ្វើ ខ្ញុំចាំបានថា ទីតាំង -- រហូតដល់ខ្ញុំមានលូកដៃធ្វើការងាទៀត គឺមិនមែនយកខ្មោចសាកល្បងទេ គឺមនុស្សតែម្តង។ តែមនុស្សដល់ខ្ញុំសួរទៅអ្នកដែលយកទៅឲ្យខ្ញុំភាគច្រើន គឺច្រើនសន្តិសុខ ថាខ្ញុំពេទ្យតំបន់ គឺសន្តិសុខរបស់តំបន់អ្នកយកទៅឲ្យ។ ដាច់ខាត ហើយការវះពិសោធនេះតាមខ្ញុំចាំ ខ្ញុំឈរមើល ឃើញជាក់ស្តែង ខ្ញុំឃើញធម្មតាដាក់សេរ៉ូម

អ្នកជំងឺមុនវះកាត់គេតែងមានតុវះកាត់រួច គេដាក់សេរ៉ូមដៃម៉្យាងអ៊ីចឹង។ ហើយគេចាប់ផ្ដើមឲ្យអ្នកមើល មិនត្រឹមមើលទេ គឺធ្វើជាក់ស្ដែងតែម្ដង។ គឺចាប់ផ្ដើមគឺថា កាត់ដៃ គឺថាគន្លាក់ដៃ ដកគន្លាក់ដៃ គឺចាប់ផ្ដើមធ្វើពីម្រាមដៃរហូតអ៊ីចឹង ដោះៗអ៊ីចឹងទៅ ដោះបោះៗអត់មានទុកទេ ដោះបោះៗ ដោះចោលអស់ទៅ ដល់អាហ្នឹងដោះអាហ្នឹងចេញទៀត ដល់អាហ្នឹងដោះអាហ្នឹងចេញទៀត ពីអស់ដៃនៅសល់ដៃតែមួយគឺដៃទុកដាក់សេរ៉ូមហ្នឹងឯង។ អស់ពីហ្នឹងមក អ្នកដែលត្រូវពិសោធហ្នឹង គឺត្រូវចាក់ថ្នាំសន្លប់។ អ៊ីចឹងអត់មានស្រែកទេ ចាក់ថ្នាំសន្លប់។ ខ្ញុំឃើញរបៀបនេះអស់បីទៅបួននាក់ នៅកន្លែងដែលខ្ញុំឃើញធ្វើអ៊ីចឹង គឺនៅក្នុងមន្ទីរយោធាតំបន់២០។ តាំងនៅភូមិធ្នង់ ឃុំជាខ្លាង ស្រុកព្រៃវែង និងព្រៃវែង តំបន់២០។

**ស៖** សូមអរគុណ។ ខ្ញុំបន្តទៀត។ តើការដែលគេបង្គាប់ឲ្យធ្វើអ៊ីចឹង ទទួលបញ្ជាពីខាងណាមកដែរ? ហើយអ្នកដែលធ្វើហ្នឹង ហេតុអីបានជាគេចាប់គាត់យកទៅៗវះទាំងរស់បែបនោះ?

**ឆ៖** អ្នកដែលធ្វើហ្នឹង ភាគច្រើនគេយក -- គេប្រាប់ខ្ញុំថា នេះគឺជាគិញរបស់ចក្រពត្តិ។ នេះគឺជាពពួកសល់ពីកម្ពែលចាស់។ អ៊ីចឹងគេចាត់ទុកថា ទុកមិនចំណេញ យកចេញមិនខាតនេះឯង។ អ៊ីចឹងមុននឹងយកចេញ វាទាល់តែមិត្ត អស់ពួកមិត្តយើងត្រូវដឹងឮ ក្រេបជញ្ជក់ពីការកម្ចាត់ចោល យើងយកមើលធ្វើ បានន័យថាឲ្យអស់ពួកមិត្តប្រឹងសិក្សាភាពជាក់ស្ដែង ហើយដោះអំមិញនេះសូមនិយាយបន្ថែម ដោះៗមើលទៅមនុស្សម្នាក់ ប្រហែលមួយកំណាត់បាវក៏មាន បានមួយកំណាត់បាវ ដោះកន្លែងដោះដាក់កាធុន អ៊ីចឹងចាក់នៅកាធុនបានពាក់កណ្ដាលបាវ រួចខ្ចប់បាវដាក់ដឹកយកចោលទៅ។ ហ្នឹងភាពជាក់ស្ដែងឡើងដូចកន្លែងខ្ញុំប្រាប់អំមិញហ្នឹង។

[១៥:១៦:៤២]

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំវិលទៅរកពាក្យមួយម៉ាត់ទៀត ដែលលោកអ៊ំនិយាយចុងក្រោយថា "ទុកមិនចំណេញ ដកចេញមិនខាត" ហ្នឹងមានន័យថាម៉េចត្រង់ហ្នឹង? សំដៅលើអីគេ "ទុកមិនចំណេញ ដកចេញមិនខាត" ហ្នឹង?

**ឆ៖** ពាក្យដែលថា "ទុកមិនចំណេញ ដកចេញមិនខាត" មានន័យថា បុគ្គលនោះគឺបក្សកំណត់ថាដាច់ខាតត្រូវតែកម្ទេចចោល ទោះបីបុគ្គលនោះជាអ្នកណាក៏ដោយ គេនឹងប្រើពាក្យហ្នឹង។ អ្នកដែលប្រើខ្លាំងជាងគេ គឺអ្នកដែលជាមាននាទីជាបក្សសម្រេចចិត្តនៅក្នុងទីកន្លែងមួយៗ។

**ស៖** សូមអរគុណ លោកអ៊ំ។ ខ្ញុំសូមត្រឡប់ទៅការងាររបស់លោកអ៊ំនៅមន្ទីរពេទ្យ នៅក្នុងភ្នំពេញវិញ។ តើមានក្រុមអ្នកជំនាញពេទ្យបរទេសមកបង្រៀន ឬក៏បណ្ដុះបណ្ដាលអ៊ំនៅពេលដែលអ៊ំ

ចូលរៀនពេទ្យនៅភ្នំពេញហ្នឹងដែរឬទេ?

[១៥:១៨:០២]

**ឆ៖** ពេលដែលខ្ញុំឡើងទៅរៀនហ្នឹង ខ្ញុំមើលឃើញវត្តមានរបស់ពួកបរទេស ភាគច្រើន គឺមានចិន និងកូរ៉េ។ ជាអ្នកមកហ្វឹកហ្វឺនផ្នែកមុខវិជ្ជាពេទ្យ ហើយអ្នកដែលចេះដឹង អ្នកដែលដឹងជាងគេ ខ្ញុំមើលឃើញច្បាស់ គេហៅថាលោកគ្រូរបស់ខ្ញុំផ្ទាល់តែម្ដងគឺលោកៗតា ជួន ជឿន។ លោកតា ជួន ជឿន ខ្ញុំស្គាល់បាន បើឃើញមុខឥឡូវ ក៏ស្គាល់ដែរ ព្រោះខ្ញុំស្គាល់ គាត់ចាស់ៗយូរដែលហើយ។ នោះមិនខ្ពស់ទេ ទាបទេ តែធាត់។ លោកគ្រូហ្នឹងអ្នកបង្រៀន។ ឯចិនគេមកបង្រៀនពិសេសបំផុតផ្នែកម្ហូលវិទ្យាសាស្ត្រ។ ហើយកូរ៉េ គេភាគច្រើនចូលក្នុងមន្ទីរវះកាត់ ឯកទេសវះកាត់។ ហើយដុកទ័រនៅក្នុងស្រុកខ្មែររបបនោះ បានន័យថា អ្នកទៅរៀនបើៗអ្នកណា បុគ្គលណាយកចិត្តទុកដាក់បុគ្គលនុ៎ងចេះ។ មូលហេតុព្រោះគេរៀនចំគោលដៅរបស់គេថា បើផ្នែកជំងឺរបេង គឺគេឲ្យអ្នកដែលជំនាញរបេងទៅបង្រៀន។ អ្នកដែលជំងឺឃ្លង់ គេឲ្យអ្នកជំងឺឃ្លង់ទៅបង្រៀន បណ្ឌិតខាងជំងឺឃ្លង់ទៅបង្រៀន។ អ៊ីចឹងចេះ ឬមិនចេះស្ថិតនៅអ្នកទៅរៀននោះឯង។ ការពិតអ្នកហ្វឹកហ្វឺនបង្ហាត់ហ្នឹងពិតជាការរឿងពិត នោះក្នុងឱកាសរៀនសូត្រ។ អ៊ីចឹងគេអត់រៀនស្មានទេ បានន័យថាចប់ពីជំងឺស្ត្រី ទៅដល់ជំងឺស្អី ជំងឺវះកាត់។ ចប់ពីវះកាត់ទៅដល់ជំងឺរបេង។ ចប់ពីរបេងទៅដល់ជំងឺគ្រុនចាញ់។ ចប់គ្រុនចាញ់ទៅដល់គ្រុនពោះវៀន។ ហែបន្តបន្ទាប់។ ប្ដូរគ្រូអ៊ីចឹងឯងហើយ ដែលធ្វើឲ្យខ្ញុំចាំគ្រូមិនបាន។ អ៊ីចឹងឱកាសនោះ ខ្ញុំគ្រាន់បានចាំថាឈ្មោះមួយ គឺឈ្មោះ នី លោកគ្រូរបស់ខ្ញុំ។ មួយទៀត ខ្ញុំមិននេះទេ លោកៗ ចាន់ ស្អីៗ ម៉េចថាម៉េចនេះ។ តា ជួន ជឿន ហ្នឹងតែម្ដងផ្ទាល់ អ្នកបង្ហាត់បង្រៀនខ្ញុំ។ លោកអ៊ំ ជួន ជឿន ព្រមទាំងលោក នី ហ្នឹង ផ្នែករបេង។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ លោកអ៊ំអាចបញ្ជាក់បានទេថា នៅក្នុងមន្ទីរពេទ្យរបស់លោកអ៊ំហ្នឹង បុគ្គលិកដែលធ្វើការនិងរៀនសូត្រហ្នឹងមានចំនួនប៉ុន្មាននាក់ ហើយអ្នកទាំងអស់ហ្នឹងនៅរស់ទាំងអស់ ឬក៏យ៉ាងម៉េចដែរ?

[១៥:២០:៤៤]

**ឆ៖** សូមទោស អ្នករស់ប្រហែលជាគ្មានទេឥឡូវ ខ្ញុំអត់ដែលជួបផង។ ហើយបុគ្គលិកហ្នឹងនិយាយពីសម័យនោះច្រើន មិនតិចទេ ច្រើននាក់។ អ៊ីចឹងតែការរស់នៅប៉ុន្មាននាក់ ស្លាប់បាត់បង់អស់ហើយនោះប៉ុន្មាននាក់។ កុំថាឡើយអ្នកណា សូម្បីតែលោកគ្រូខ្ញុំហៅថា លោកតា លោកអ៊ំ ជួន ជឿន

ហ្នឹងក៏មិនដែលស្គាល់មិនដឹងផង ឥឡូវ មិនដឹងស្លាប់ ឬរស់មិនដឹងទេ និយាយត្រង់រឿងពិត ព្រោះមិនបានដឹងថា គាត់នៅរស់ ឬនៅស្លាប់នៅឡើយទេ។ អ៊ីចឹងគ្រាន់តែដឹងថា លោកគ្រូនេះ គឺជាគ្រូរបស់ខ្ញុំ។ គាត់បានបង្ហាត់បង្រៀនខ្ញុំផ្ទាល់ គឺគាត់ហ្នឹងជាអ្នកបង្រៀនខាងផ្នែកវះកាត់ ព្រោះគាត់ឯកទេសវះកាត់ និងបេះដូង លោកអ៊ំ ជួន ជឿន ហ្នឹង។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ តើមានការចាប់ខ្លួនបុគ្គលិកពេទ្យ នៅមន្ទីរពេទ្យហ្នឹងដែរឬទេ?

**ឆ៖** ក្នុងការសិក្សារបស់ខ្ញុំ អាហ្នឹងបើនិយាយពីបញ្ហាហ្នឹង ខ្ញុំមិនអាច -- ខ្ញុំនិយាយខ្លះៗទៅតាមលក្ខណៈដែលខ្ញុំឃើញជាក់ស្ដែង ភាពពិត។ ក្នុងឱកាសដែលខ្ញុំសិក្សាហ្នឹង បុគ្គលិកក៏ចាប់ អ្នកឡើងមករៀនក៏ចាប់ អ្នកដែលទទួលខុសត្រូវនៅទីនោះក៏ចាប់។ ខ្ញុំមើលទៅក្នុងការសិក្សារបស់ខ្ញុំ ខ្ញុំមិនមែនទៅតាមដានវិធីហ្នឹងទេ តែខ្ញុំឃើញដោយសារខ្ញុំរស់នៅនឹងមន្ទីរពេទ្យ។ អ៊ីចឹង ខ្ញុំឃើញអ្នកដែលគ្រោះថ្នាក់ខ្លាំងជាងគេ គឺខាងដើមឡើយ គឺភូមិភាគនិរតី ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ និងភូមិភាគពិ្ឋសាន។ គ្នាមករៀនហើយក៏នៅតែឡានដឹក កំពុងរៀនចេញដែរ ដល់សួរទៅថាដឹកយកទៅណា? គេថា ហ្នឹងហើយពួកមិត្តដែលក្បត់បក្ស។ ហើយខ្ញុំកាលខ្ញុំឃើញនោះ ខ្ញុំមិននិយាយពន្លើសទេ សូមព្រះពុទ្ធ ព្រះសង្ឃដឹងឮ ថាខ្ញុំកាលណា សូមនិយាយការពិត គឺខ្ញុំឃើញពេលដែលចាប់ដាក់ឡាន មិនដឹងជាគាត់ដោះខោអាវចោល ទុកធ្វើអី មិនឲ្យគ្នាទៅឲ្យផុតចាំធ្វើទារុណកម្ម។ អ៊ីចឹងស្រីគួរសម -- បើប្រុសគួរសម បើស្រីដោះរលីងៗ ខ្ញុំចេះតែឆ្ងល់។ អ៊ីចឹងហេតុផលនេះ ខ្ញុំអាណោចអាធ័ម បើនិយាយឲ្យអស់សាច់រឿង ប្រហែលជាខ្ញុំនិយាយអត់រួច ដោយសារ អីបង្ហូរទឹកភ្នែក ឃើញពិតៗនឹងភ្នែក។ សូមទោសបាទ។

[១៥:២៣:១៣]

**ស៖** សូមលោកអ៊ំសម្រួលអារម្មណ៍បន្តិចទៅបាទ។ គឺថារឿងអ្វីដែលកើតឡើងជាការពិត គឺអ្វីដែលលោកអ៊ំបានឃើញ សូមលោកអ៊ំបញ្ជាក់នៅក្នុងសវនាការនេះ ហើយខ្ញុំ -- ដូច្នេះ ខ្ញុំសួរថាតើខ្ញុំអាចសួរលោកអ៊ំបន្តទៀតទេ បាន ឬលោកអ៊ំត្រូវការសម្រាក សម្រួលអារម្មណ៍បន្តិច ឬក៏យ៉ាងម៉េច? សូមលោកអ៊ំបញ្ជាក់មក។

**ឆ៖** និយាយត្រង់ណោះ ខ្ញុំសូមផ្ដល់យោបល់ថា ខ្ញុំមិនបិទទេការសាកសួរ សួរចុះតែខ្ញុំសូមទោសទុកជាមុន ចំណុចណាដែលខ្ញុំទៅមិនរួច ខ្ញុំមិនទៅ ចំណុចណាទៅរួច ខ្ញុំនិយាយបន្ថែម។ សូមទោសទុកជាមុនបាទ។

**ស៖** បាទ អរគុណលោកអ៊ំ។ ខ្ញុំសួរសំណួរលោកអ៊ំ ពាក់ព័ន្ធនឹងការចាប់ខ្លួននេះបន្តទៀត តើ

នៅពេលដែលលោកអ៊ំបានឃើញអ៊ីចឹង តើលោកអ៊ំខ្លួនឯងផ្ទាល់ មានអារម្មណ៍យ៉ាងម៉េចដែរនៅពេលនោះ? ហើយបានដឹងថាពីមូលហេតុដែលគេចាប់ខ្លួនអ្នកទាំងអស់ហ្នឹងដែរឬទេពេលនុ៎ង?

**ឆ៖** ភាពពិតជាក់ស្តែងការចាប់នេះ ខ្ញុំពិតជាបានឃើញ ប៉ុន្តែការឃើញមិនមែនបានទាំងស្រុងទេ ឃើញកន្លែងណាដែលឃើញ ឃើញបុគ្គលណាចាប់ខ្ញុំឃើញ។ អ៊ីចឹងឯងហើយ ការដឹងឮទាំងអស់នោះខ្ញុំមិនធានាថាដឹងអស់ទេ ប៉ុន្តែអាទិដ្ឋភាពហ្នឹង ខ្ញុំធានាថាពិតជាឃើញ រឿងពិត។ ខ្ញុំពិតរបស់ខ្ញុំ ខ្ញុំឃើញគាត់ហ្នឹងដូចជាអ្នកគណៈកម្មការសាលាខ្ញុំទេ គឺអ្នកស្រីម្នាក់ លោកជំទាវម្នាក់ឈ្មោះថា ឡេង សី។ គាត់ជាគ្រូ បង្ហាត់ខាង -- គាត់អប់រំមើលការខុសត្រូវផ្នែកនយោបាយ។ ប៉ុន្តែ មិនដឹងថៃ្ងដន្យអី ថ្ងៃនោះខ្ញុំដើរទៅឃើញគាត់គេចាប់ឡានៅក្រោយសាលាមួយ សាលាពេទ្យនៅក្នុងពេទ្យរុស្ស៊ីនេះ។ រហូតដល់គ្មានខោអាវ ដល់ខ្ញុំតាមសួរ អ្នកស្រីហ្នឹងជាអ្នកណា? ដល់សួរអ្នកស្គាល់ គេថា "អ្នកស្រីគឺជាប្រពន្ធរបស់លោក ទីវ អុល"។ អ៊ីចឹងការសួរ ខ្ញុំបានត្រឹមឃើញ ការសួរនាំអត់ប៉ានសួរទេ។ ខ្ញុំសូមជម្រាបត្រង់បាទ។

[១៥:២៦:០១]

**ស៖** តើលោកអ៊ំបានដឹងថា តើគេចាប់ ឡេង សី ហ្នឹងដោយមូលហេតុអីទេ? ហើយលោកអ៊ំបានរៀបរាប់ថាប្តីគាត់ឈ្មោះ ទីវ អុល ហ្នឹង ទីវ អុល ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ទីវ អុល ហ្នឹងនិយាយតាមដំណើរពិត ខ្ញុំស្គាល់ពីខាងដើមទេ ដល់នាទីដែលខ្ញុំទៅឃើញហ្នឹង អត់ដឹងថាគាត់ធ្វើអីទេ តែខ្ញុំដឹងថាហ្នឹងគឺអ្នកនិពន្ធខាងដើមមក។ អ្នកចេះដឹង អ្នកបញ្ញវន្ត ម្ល៉ោះហើយខ្ញុំតែងតែគោរពគាត់។ ប៉ុន្តែភាពតែគាត់ធ្វើអីនៅពេលបច្ចុប្បន្ន អ៎! ពេលនោះគឺខ្ញុំមិនបានដឹងច្បាស់ទេ បាទ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកអ៊ំសម្រាប់ខ្ញុំ។ នៅពេលនេះខ្ញុំអស់សំណួរសួរទៅលោកអ៊ំហើយ។ សូមថ្លែងអំណរគុណលោកអ៊ំចំពោះការឆ្លើយបំភ្លឺ ពាក់ព័ន្ធទៅនឹងការអ្វីដែលយើងខ្ញុំបានសួរពីដើម ហើយខ្ញុំទុកឱកាសនេះឲ្យលោកមេធាវី ពេជ អង្គ គាត់បន្តសំណួរបន្ថែមទៀតនូវចំណុចដែលលោកអ៊ំបានសរសេរនៅក្នុងពាក្យបណ្តឹងនេះ បាទ។ សូមអរគុណលោកអ៊ំ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គ

សវនាការទាំងមូល។ ខ្ញុំសូមបន្ត លើកសំណួរបន្តទៀត។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោក អែម អឿន។ ខ្ញុំចង់សុំសួរបញ្ជាក់ បន្តិចនៅពេលដែលលោក បានមកដល់មន្ទីរពេទ្យកម្ពុជា-សូវៀតនោះ ថាតើលោកចាប់ផ្តើមរៀនភ្លាម ឬក៏មានកម្មវិធីអ្វីមុននឹងចូល ទៅដល់រៀនមុខវិជ្ជាពេទ្យនោះ?

[១៥:២៨:១៦]

**លោក អែម អឿន៖**

**ឆ៖** ត្រង់នេះ ខ្ញុំសូមបើកផ្លូវទុកឲ្យបានមុន ទុកមុនឲ្យហើយថា ការបានរៀនមុន។ ខ្ញុំគ្រាន់តែ ដឹងថា ខ្ញុំបានមិនគិតឲ្យដល់ថា ត្រង់នុំងបានធ្វើអីខ្លះខាងដើម។ ប៉ុន្តែខ្ញុំជឿថា មុននឹងចូលសាលាវះកាត់ នៅក្នុងមន្ទីរពេទ្យមួយឆ្លងពីរបេងទៅដល់វះកាត់ ខ្ញុំដូចជាជួបថា សិក្សានយោបាយក៏មិនដឹង អីមិនដឹង ព្រោះ ឆ្ងាយហើយភ្លេចៗ ភ្លេចភ្លាំងខ្លះ។ អ៊ីចឹងសូមទោសទុកជាមុន។ មិនមែនៗជារឿងប្រឌិតមកទេ ប៉ុន្តែខ្ញុំគិតមិនឃើញថា តើអារៀនហ្នឹងមុន ឬក៏រៀនហ្នឹងក្រោយនយោបាយ។ ចូលរៀនតែម្តង ឬក៏ខ្ញុំ រៀន កំពុងរៀនពេទ្យមកចូលនយោយបាយ អាហ្នឹងមិនច្បាស់។ ប៉ុន្តែតាមការសន្និដ្ឋានពិត ប្រហែលជា ខ្ញុំបានរៀនពេទ្យ បានខ្ញុំចូលផ្នែកនយោបាយ ទៅរៀននយោបាយ។

[១៥:២៩:០៨]

**ស៖** វគ្គនយោបាយដែលលោកនិយាយនេះគឺ វគ្គនយោបាយនៅបុរីកីឡា ឬវគ្គនយោបាយនៅទី កន្លែងផ្សេង?

**ឆ៖** វគ្គនយោបាយផ្នែក -- ក្រៅពីផ្នែកពេទ្យ ខ្ញុំមិនបានជួបវគ្គនយោបាយឯណាទេ គឺមានតែ នយោបាយតែមួយនេះឯង។

**ស៖** តើមានកម្មវិធីជាការបើកវគ្គសិក្សាទេ នៅពេលដែលលោកបានមកដល់ពេទ្យកម្ពុជា-សូវៀត ហ្នឹង? ថាតើមានកម្មវិធីបើកវគ្គសិក្សាដែរឬទេ ឬក៏ទៅដល់ចូលរៀនតែម្តង?

**ឆ៖** វគ្គសិក្សា មុននឹងចូលសិក្សាវិជ្ជាពេទ្យ ហើយបែងចែកទៅតាមជំនាញគឺ មានធ្វើកម្ម វិធី បើកសាលា។ មិនមែនចូលទៅរៀនតែម្តងទេ គឺមានកម្មវិធីបើកសាលា។

**ស៖** កម្មវិធីបើកសាលាហ្នឹង តើអ្នកណាជាអ្នកមកបើកកម្មវិធី បើសាលាហ្នឹង? ហើយលោក អាចរៀបរាប់បានទេ អ្នកណាដែលជាគណៈអធិបតីនៅក្នុងការបើកកម្មវិធី បើកសាលានេះ?

**ឆ៖** វគ្គៗពេទ្យនេះ មុននឹងចូលរៀនវិជ្ជាពេទ្យគឺ បើកសាលាក្រោមអធិបតីភាពរបស់ប្រធានមន្ទីរពេទ្យ ១៧មេសា ខ្ញុំពិនិត្យទៅឃើញលោកស្រី ឡេង សី ហ្នឹងមួយ លោក ជួន ជឿន ហ្នឹងមួយ ហើយនិងក្រុមរបស់គាត់ជាវេជ្ជបណ្ឌិត វេជ្ជបណ្ឌិតអ្នកបង្រៀនហ្នឹងចូលរួមប្រហែលជា -- សរុបទៅប្រហែលជា ១០នាក់ជាង តែខ្ញុំមិនបានចាំអស់ទេ។

[១៥:៣១:២៧]

**ស៖** តើមានអ្នកណាគេផ្សេងទៀត ក្រៅពីអ្នកទាំងអស់នោះទេ ដែលចូលរួមនុ៎ង?

**ឆ៖** ក្រៅពីនោះមិនមានអ្នកណាចូលរួមទេ។ បាទ ក្រែងខ្ញុំមិនស្គាល់ ឬភ្លេចបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបន្តទៅបន្តិច នៅពេលដែលចាប់ផ្តើមរៀននៅសាលា ឬក៏ធ្វើការនៅសាលា នៅពេទ្យរុស្ស៊ីនេះ ថាតើប្រហែលជារយៈពេលប៉ុន្មានបានជា -- បានលោកទៅចូលរួមវគ្គនយោបាយនៅបុរីកីឡានោះ? ពីពេលចាប់ផ្តើមរហូតទៅដល់ពេលមានវគ្គសិក្សានយោបាយហ្នឹង ថាតើរយៈពេលប្រហែលជាប៉ុន្មាន?

**ឆ៖** រយៈពេលបើកវគ្គនយោបាយក្នុងឱកាស ខ្ញុំសិក្សាពេទ្យហ្នឹង បើតាមខ្ញុំចាំបានរយៈពេលប្រហែលជាក្រោយខ្ញុំចូលមន្ទីរពេទ្យហ្នឹងបានប្រហែលជា១១ខែ បើវែងប្រហែលជា ២ខែ ហ្នឹងប្រហែលទេ។ ខ្ញុំមិនប៉ានកំណត់បានទេ បាទ។

[១៥:៣៣:០១]

**ស៖** ហើយបន្ទាប់ពីរៀន វគ្គនយោបាយហ្នឹង ហើយរយៈពេលប៉ុន្មានបានលោកបញ្ចប់វគ្គសិក្សាពេទ្យហ្នឹង ហើយត្រឡប់ទៅទីកន្លែងដើមវិញ?

**ឆ៖** ក្រោយពេលបើកវគ្គសិក្សាពេទ្យនេះ ហើយប្រហែលជា ៦ឬ៧ខែ ចប់។ ដល់ចប់ទៅខ្ញុំត្រឡប់ទៅមូលដ្ឋានដើមវិញ។ ហ្នឹងគ្រាន់តែនិយាយថា ប្រហែលទេ តែពិតខ្ញុំមិនប៉ាននិយាយពិតទេ ព្រោះថា វែងឆ្ងាយណាស់ យូរណាស់ដែរទៅហើយបាទ។

**ស៖** លោកបានមានប្រសាសន៍ពីដើមថា វគ្គសិក្សានេះ គឺរយៈពេល១ឆ្នាំ ហើយក្រោយមកលោកបានមានប្រសាសន៍ថាបានសិក្សាតែរយៈពេល ៩ខែទេ សរុបទាំងអស់។ អ៊ីចឹងថាតើវគ្គសិក្សានេះត្រូវបានបញ្ចប់ដោយកម្មវិធីចប់តែម្តង ឬក៏វគ្គសិក្សានៅមន្ទីរពេទ្យហ្នឹងត្រូវបានចប់ដោយមានព្រឹត្តិការណ៍អ្វីផ្សេងទៀត ដែលធ្វើឲ្យលោកត្រូវបញ្ចប់ការសិក្សារបស់ខ្លួននៅមន្ទីរពេទ្យនោះ?

[១៥:៣៤:២៨]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំមើលទៅហាក់ឃើញដូចមិនមែនចប់ទេ ប៉ុន្តែថ្ងៃនោះ គឺប្រធានមន្ទីរពេទ្យ ១៧ មេសា បានប្រាប់ខ្ញុំថា មិត្តត្រូវមាននាទីមួយគឺត្រូវទទួលជំងឺយ៉ាងច្រើនដែលកើតសង្គ្រាមនៅវៀតណាម និងកម្ពុជានៅព្រំដែលខាងកើត។ អ៊ីចឹងតម្រូវ សមមិត្តតម្រូវទទួលខុសត្រូវព្យាបាលយុទ្ធមិត្តរបស់យើង ដែលបានរបួសនៅក្នុងសង្គ្រាម។ អ៊ីចឹងមិនបាន អាហ្នឹងឯងហៅថា ក្លាយជាទៅមិនបានពេញ១ឆ្នាំ គឺទៅជារយៈ ៩ខែ។ នេះបានខ្ញុំថា ការរៀនរបស់ខ្ញុំទៅពីជនបទទៅរយៈពេល១ឆ្នាំ។ ប៉ុន្តែទៅតាមការគិតទៅ ឃើញប្រហែលជាបានតែត្រឹម៩ ឬ១០ខែប៉ុណ្ណោះទេ។ អ៊ីចឹងដោយសារចប់នេះ មិនមែនដោយការបិទ ដោយចប់ការសិក្សាទេមើលទៅថ្ងៃហ្នឹង។ ប្រហែលជាការត្រូវការ។ ព្រោះខ្ញុំ មនុស្សខ្ញុំទៅរៀនរនយោ-បាយក៏មិនបានចប់ ដល់មករៀនពេទ្យក៏មិនបានចប់។ សុទ្ធតែដំណាក់កាលត្រូវការរបស់អង្គភាព។ អាហ្នឹងសូមជម្រាបលោកមេធាវីបាទ។

[១៥:៣៥:៣៤]

**ស៖** លោកបាននិយាយថា ត្រូវត្រឡប់ទៅវិញដោយសារមានអ្នករបួសច្រើន ដោយសារសង្គ្រាមជាមួយវៀតណាម តើលោកអាចនិយាយបានទេ ថាតើអំឡុងពេលដែលលោកត្រឡប់ទៅវិញហ្នឹងប្រហែលជាឆ្នាំណា?

**ឆ៖** ខ្ញុំនិយាយ សូមនិយាយអំពីភាពប៉ាន់ស្មាន មិនមែនជារឿងពិតរបស់ខ្ញុំ ព្រោះខ្ញុំបានចាំការរៀនពិតជារៀន ប៉ុន្តែវាមិនបានចាំពេលវេលាច្បាស់ អ៊ីចឹងខ្ញុំប្រហែលជាក្នុងចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨។ សូមជម្រាបជូនលោកមេធាវីបាទ។

**ស៖** បាទ សូមអរគុណចំពោះការបញ្ជាក់នេះ។ ខ្ញុំនឹងសួរបន្ថែមបន្តិចដោយសារថា ដៃគូរបស់ខ្ញុំបានសួរលោករួចហើយពាក់ព័ន្ធទៅនឹងការសិក្សានៅបុរីកីឡា។ ខ្ញុំចង់សួរបន្ថែមបន្តិចអំពីនៅបុរីកីឡាហ្នឹង ដើម្បីឲ្យមានព័ត៌មានកាន់តែច្បាស់។ តើលោកអាចបញ្ជាក់បានទេនៅពេលដែលលោករៀននៅបុរីកីឡាហ្នឹង ថាតើគ្នាមាន -- អ្នកដែលជាអ្នកចូលរួមហ្នឹងមានគ្នាប៉ុន្មាននាក់ អ្នកដែលជាសិក្ខាកាមហ្នឹង ហើយលោកអាចអត្ថាធិប្បាយអំពីបន្ទប់រៀន ឬកន្លែងរៀនហ្នឹងបានទេ ថាតើមានលក្ខណៈយ៉ាងដូចម្ដេច?

[១៥:៣៧:១៦]

**ឆ៖** ការខ្ញុំទៅជួបការសិក្សានៅក្នុងបុរីកីឡានេះ បើនិយាយពីលក្ខណៈសាលា គេមាន។ ប៉ុន្តែនៅឱកាសនោះ ប្រហែលជាឱកាសនោះ បក្សនឹកឃើញថា បង្រៀនឲ្យបានច្រើន យកមនុស្សឲ្យបាន

ច្រើនបែរទៅបង្កើតសាលាមួយដែលមានប្រក់ស័ង្កសី រួចរៀបខាងក្រោមជាក្ដារបន្ទះ ហើយរៀបដាក់តុលើគ្រប់តុ។ វាមើលទៅលក្ខណៈទ្រង់ទ្រាយអ្នកចូលរៀនស្មើនឹង១ពាន់ជាង ឬក៏ប្រហែលជាលើស២ពាន់តិចតួច។ ហ្នឹងការស្មានទេ ដោយសារតាមស្មានទិន្នន័យតាមដំណើរដែលថា មួយស្រុកយកប៉ុន្មាននាក់ៗ មួយកន្លែងយកប៉ុន្មាននាក់ គឺបូកបោះទៅ វាឃើញច្រើនដែលផង ហើយឃើញរូបភាពពិតហ្នឹងច្រើនដែរអាហ្នឹងពីការសិក្សា។

រីឯការរស់នៅ ជាក់ស្ដែងនៅក្នុងរស់នៅក្នុងឱកាសកម្មវិធីសិក្សានេះ ខ្ញុំមើលទៅហេតុផល ខ្ញុំមើលទៅអត់យល់ ព្រោះថាមនុស្សខ្ញុំវាមាននាទីមួយនៅក្នុងមន្ទីរពេទ្យផង ហើយមើលការងារសិស្សដែលខ្ញុំទទួលខុសត្រូវផង។ អ៊ីចឹងឱកាសខ្លះ ខ្ញុំដេកនៅក្នុងសាលា ជាមួយសាលា ជាមួយអ្នកដែលស្គាល់ៗ។ ឱកាសខ្លះខ្ញុំវិលមកដេកមន្ទីរពេទ្យ។ អ៊ីចឹងការប្រាកដនិយម ខ្ញុំយល់ថា សាលានេះមានក្រឹតក្រមច្បាស់ណាស់ ចុះហេតុអីបានខ្ញុំចេញចូលបាន? ដោយសារខ្ញុំមាននាទីមួយ គឺនាទីមើលសិស្សផង ខ្លួនឯងជាពេទ្យផង។ ដូច្នេះ ការដេកនៅ ខ្ញុំមើលទៅទិដ្ឋភាពមិនអាចបែកគ្នាបានទេ គឺដេកជារួមតាមផ្ទះល្វែងអ៊ីចឹងទៅ កន្លែងវ៉េជញ្ជាំងចោល បង្កើតជាកន្លែងល្វែងនេះ។ អាហ្នឹងការដេកអ៊ីចឹង បានន័យថា បើមើលស្ថានភាពអស់ហ្នឹង គឺការយកចិត្តទុកដាក់ និងការសិក្សានយោបាយរបស់អ្នកកម្មាភិបាលជំនាន់នោះហាក់ដូចជាបក្សហ្នឹងយកចិត្តទុក។ មិនមែនហាក់ទេ គឺយកចិត្តទុកដាក់ខ្លាំងដែរនៅក្នុងដំណាក់ទៅរៀន ឡើងរៀននយោបាយ។ ព្រោះថ្នាក់នោះ អ្នករៀននោះមិនមែនជាអ្នកធម្មតាទេ ទាបបំផុតត្រឹមប្រធានមន្ទីរស្រុក ប្រធាន អនុប្រធាន១ និងប្រធានស្រុក និងប្រធានមន្ទីរជុំវិញភូមិភាគ។ ប្រធាន អនុប្រធាន ហើយនិងប្រធាន ដែលគេថា នាយកដ្ឋានជុំវិញមជ្ឈិមនៅក្នុងក្រសួងភ្នំពេញហ្នឹងបានន័យថាសុទ្ធតែប្រធាន អនុប្រធាន រហូត។ អ៊ីចឹងដល់បូកបោះទៅ ស្មើ-លើស ឬខ្វះបន្តិចបន្តួចប្រហែលជា២ពាន់នេះឯង។ ដល់ការរស់នៅ ដេកនៅស៊ីចុក ស៊ីចុកជារួម ការហូបចុករួម។ ប៉ុន្តែដល់ការដេកនៅ ក៏ជារួមដែរ តែលក្ខណៈដេករួម ខ្ញុំមិនបានដេកជាមួយដោយសារអី? ខ្ញុំមានអង្រឹង ចូលចិត្តដេកអង្រឹង អាងមានអង្រឹងខ្ញុំដេកត្រង់ណាក៏ដោយដែរ ព្រោះថាកាលហ្នឹងកំលោះម្នាក់ឯង ខ្ញុំនៅម្នាក់ឯង។ ខ្ញុំសូមជម្រាបលោកមេធាវី បាទ។

[១៥:៣៩:៥៩]

**ស៖** ខ្ញុំចង់ជម្រាបសួរបន្តិច ថាតើបន្ទប់នៅក្នុងការសិក្សាហ្នឹងធំប៉ុនណាទៅ ព្រោះលោកនិយាយថាមានគ្នាពី ១០០០នាក់ រហូតដល់ ២០០០នាក់ ហើយអាចលើសពីហ្នឹងថែមទៀត។ ថាតើបន្ទប់

សម្រាប់សិក្សាហ្នឹងធំប៉ុនណា ហើយថាតើគេរៀបតុ រៀបកៅអីយ៉ាងដូចម្ដេចនៅពេលនោះ ដែលអាចធ្វើផ្ទុកមនុស្សរហូតទៅដល់រាប់ពាន់នាក់នោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីថា មិនមែនការនិយាយស្មានទេ គឺខ្ញុំសូមនិយាយត្រង់ថា គ្មានការអាច មានការខុសខ្លះ មិនមែនថាត្រូវទាំងអស់ទេ។ សាលាដែលបើកជាសាលារៀន ដូចនិយាយអម្បាញ់មិញនេះ មិនមែនជាបន្ទប់អ៊ីចឹងលំហ ម៉ាហ្នឹងទេ ម៉ាសិក្ខាកាមទៅទេ។ ការពិតទៅហាក់ដូចជាគេ បើកជាផ្ទាំងផ្ទះ បានន័យថា ទីតាំងមួយសម្រាប់ធ្វើការរៀនសូត្រផង ប្រជុំផង។ អ៊ីចឹងដូចគ្នានៅក្នុងមន្ទីរពេទ្យរុស្ស៊ីដែរ ព្រោះថាពេទ្យរុស្ស៊ីមិនមែនរៀនក្នុងសាលាពេទ្យទេ គឺរៀនក្នុងសាលាមួយដែលធ្វើដំបូលថ្មី រៀបក្ដារថ្មី ដាក់សសរថ្មី ដាក់កន្លែងតុ។ ឯតុអង្គុយនេះ គឺគ្មានតុដូចក្មេងរៀនទេ គឺតុអ៊ីចឹងៗ ហើយដាក់ក្ដារសរសេរធម្មតា។ ម្នាក់គឺតុមួយៗ ដូចកន្លែងតុកុនអ៊ីចឹងឯង។ នេះសូមជម្រាបលោកប្រធាន។

[១៥:៤១:២៩]

ឯការប៉ាន់ស្មានមិនមែនការប៉ាន់ហ្នឹង ប៉ាន់ខុសឆ្ងាយពេកទេ ព្រោះខ្ញុំមើលទៅសាលាដែលខ្ញុំរៀនពេទ្យនៅក្នុងពេទ្យរុស្ស៊ីក៏ជាង ២០០០នាក់ដែរ លោកមេធាវី។ ដល់មកផ្នែកនយោបាយក៏រូបភាពដូចគ្នាសាលាហ្នឹងក៏ប្រហែលជាប៉ុណ្ណឹងដែរ។ និយាយឲ្យត្រង់ៗ សាច់រឿងពិតរបស់ខ្ញុំ ឃើញពិតបាទ។

**ស៖** លោកបាននិយាយថា ម្នាក់តុមួយៗ តើតុហ្នឹងប៉ុនណា?

**ឆ៖** ម្នាក់តុមួយ សូមបង្ហាញរូបភាពឲ្យលោកមេធាវីដឹង តុដូចទំហំប៉ុណ្ណឹងអង្គុយម្នាក់ឯង។ គ្រាន់តែមានក្ដារមួយបន្ទះប៉ុន អ៊ីចឹងទៅដាក់ៗសៀវភៅដាក់អីពីលើមានតែប៉ុណ្ណឹង។ មានទំហំប៉ុណ្ណឹងៗ គ្រាន់ថាតុហ្នឹងអត់មានវិលបានអ៊ីចឹងទេ គឺតុដូចតុអ៊ីចេះ របៀបនេះ តាមរូបភាព ក្រឡាទ្រដៃយើងដូចកៅអីនៅក្រោយ -- នៅខាងក្នុងសវនាការនេះ ដូចគ្នា រូបភាពដាក់អ៊ីចឹងក្ដារហ្នឹង ប៉ុន្តែមិនមែនតុអ៊ីចឹងទេ គឺតុរបៀបអ៊ីចេះ មិនដូចអ៊ីចឹងទេ ដូចអារូបភាពហ្នឹង អ៊ីចឹងអាហ្នឹងបត់បានអីបានដែរ។ អ៊ីចឹងម្នាក់ៗមួយរហូតគ្រប់ អត់ពិបាកសែងតុជើងមួយដំប តែប៉ុណ្ណឹងទេ។ ខ្ញុំជម្រាបលោកមេធាវីតែប៉ុណ្ណឹង។

[១៥:៤៣:០០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ទំនងជាពេលវេលាដូចជាបែបវាច្រើនពេកមើលទៅ បានជាសំណួរហ្នឹងដូចជាសួរដល់តុ ដល់កៅអីហ្នឹង ដូចជាពាក់ព័ន្ធកម្រិតណាដែរជាមួយនឹងអង្គហេតុដែលចោទប្រកាន់ដ៏ធំធេងរបៀប

នេះ? សូមរៀបរាប់ រៀបរយនូវសំណួរដើម្បីឱ្យចូលទៅពាក់ព័ន្ធនឹងអង្គហេតុ ដែលចោទប្រកាន់ ហើយដែលកំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១ នេះ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធានដែលរំឭកដល់ខ្ញុំចំពោះដល់ការងារនេះ ខ្ញុំសួរបញ្ជាក់ដូច្នេះ ដើម្បីឱ្យឃើញពីទិដ្ឋភាពពិតថា សាក្សីនេះបានចូលរួមពិតប្រាកដមែនហើយដែលបញ្ជាក់ -- ដើម្បីរឹតតែឱ្យមានតម្លៃទៅលើសក្ខីកម្មរបស់គាត់ថែមទៀត។ សូមទោសមិនមែនជាសាក្សី ជាដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំសួរលោកទៅចំណុចមួយទៀតទៅលើអ្វីដែលលោកបាននិយាយក្នុងព័ត៌មានរបស់លោកដែលបានដាក់នៅអង្គភាពគាំពារជនរងគ្រោះ។

**លោក ពេជ អង្គ៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធាន លើកពីឯកសារមួយដែលមានលេខ D22/3963 ដែលមានលេខ ERN ជាភាសាខ្មែរ 00573979, លេខ ERN ជាភាសាអង់គ្លេស 0071 -- សូមទោស 00751867, និងលេខ ERN ជាភាសាបារាំង គឺលេខ 00786186 ដែលឯកសារនេះបានដាក់នៅក្នុង *អាំងទែរហ្វាស* រួចទៅហើយ។ ខ្ញុំសូមលើកចំណុចមួយនៅក្នុងឯកសារនេះ។ សូមលោកប្រធានអនុញ្ញាត។

[១៥:៤៥:២៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ នៅក្នុង១ទំព័រនេះ លោកបាននិយាយថា “ជាដំបូងលោក ខៀវ សំផន -- កម្មាភិបាលដោយផ្តោតអារម្មណ៍នៅលើប្រជាជនថ្មីជាងគេនៅចំណុច ជាខ្លាង ព្រោះ ខៀវ សំផន ឱ្យតម្លៃថាប្រជាជនថ្មីនេះ ជាប់កម្ពែលសក្តិភូមិយូរជាងគេ។ ខៀវ សំផន បានបញ្ជាក់យ៉ាងច្បាស់ៗថា ទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់ ដើម្បីឱ្យខ្មាំងដែលបង្កប់ក្នុងផ្ទៃក្នុងរបស់ប្រជាជនឆាប់ចេញមុខ វាទាល់តែយើងបង្កើតការងារឱ្យធ្ងន់ៗ និងច្រើន នោះពិតជាវាមិនអាចលាក់ខ្លួនក្នុងជួរយើងបានយូរទៀតបានឡើយ។ រួចគេក៏បានបញ្ជាក់ទៀតដែរថា ចំពោះកម្មាភិបាលយើង ពិសេសចំពោះអស់មិត្តដែលកំពុងរៀននេះឯង បើមិត្តណាមិនប៉ានធ្វើតាមគោលដៅនេះ បុគ្គលនោះក៏ជាសត្រូវផងដែរ។ បើជាសត្រូវ

យើងត្រូវតែកម្ទេចផងដែរ ដោយខានមិនបាន"។

[១៥:៤៧:០៦]

សំណួរខ្ញុំចង់សួរថា តើប្រជាជនថ្មីនេះ លោក ខៀវ សំផន -- ហេតុអ្វីបានជា -- សូមទោស សូមលោកជាសំណួរសាជាថ្មី។ តើការអនុវត្តពាក់ព័ន្ធនឹងប្រជាជនថ្មីនេះ តើមានអនុវត្តដែរឬទេនៅក្នុងរបបពាឆ្នាំហ្នឹង អំពីគំនិត ឬក៏គោលការណ៍ដែលបាននិយាយអម្បាញ់មិញដែលលោកបានទទួលពីលោក ខៀវ សំផន នោះ? ថាតើគំនិតនេះមានបានអនុវត្តនៅក្នុងពេល៣ឆ្នាំហ្នឹងដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសុំសូមសួរបញ្ជាក់ថា ៣ឆ្នាំយ៉ាងម៉េច? ៣ឆ្នាំក្រោយ១៧ មេសា ឬក៏៣ឆ្នាំក្រោយ៧៥ បាទ? ឯក្រោយ ១៧មេសា ឬក៏មុន៣ឆ្នាំហ្នឹង។ សូមសួរបញ្ជាក់បន្ថែមបាទ ស្រួលឆ្លើយ។

**ស៖** បាទ សូមអរគុណចំពោះការបញ្ជាក់។ ចង់សួរថា ចាប់ពី១៧ មេសា ១៩៧៥ រហូតទៅដល់ ០៦ មករា ឆ្នាំ១៩៧៩ ហ្នឹង ថាតើគេមានសម្គាល់ថាអ្នកណាជាប្រជាជនថ្មី ហើយអ្នកណាជាប្រជាជនចាស់? ហើយការតម្រូវឲ្យមានធ្វើការធ្ងន់ៗចំពោះអ្នកដែលជាប្រជាជនថ្មីហ្នឹង មានដែរឬទេនៅក្នុងពេលនោះ? ការអនុវត្តជាក់ស្តែង ចង់និយាយសំដៅលើការអនុវត្តជាក់ស្តែង មានអនុវត្តគំនិតនេះដែរឬទេ?

[១៥:៤៩:០៥]

**ឆ៖** ត្រង់ចំណុចនេះ ក្រៅពីពេលខ្ញុំត្រឡប់ទៅៗពីភ្នំពេញទៅដល់ជនបទវិញ គឺអនុវត្ត ដូចខ្ញុំនិយាយគោលការណ៍អម្បាញ់មិញ ក្នុងឯកសារបានដាក់ថា ពិសេសបំផុត ប្រជាជននៅភូមិជាខ្លាង។ ភូមិជាខ្លាង នេះគឺជាភូមិមួយដែលមន្ទីរពេទ្យយោធារបស់តំបន់២០ ស្ថិតនៅទីនោះឯង។ គឺខ្ញុំបានចូលរួមក្នុងការព្យាបាលជំងឺ បានខ្ញុំដឹង។ អ៊ីចឹងអំមិញ ដែលខ្ញុំនិយាយអំមិញថា កើតឡើងខ្លាំងដែលយកជំងឺ យកមនុស្សរស់ធម្មតាទៅពិសោធ គឺពិសោធស្ថិតនៅក្នុងចំណុចនេះឯង។ នេះឯងហើយ គឺជាមន្ទីរពេទ្យដែលខ្ញុំទៅ ត្រូវទទួលខុសត្រូវក្នុងរយៈកាលនោះឯង។ អ៊ីចឹង ខ្ញុំឃើញទិដ្ឋភាពនេះ មិនមែនឃើញក្រៅពីមន្ទីរពេទ្យរបស់ខ្ញុំទេ គឺក្នុងមន្ទីរពេទ្យរបស់ខ្ញុំដែលបានចូលរួមជាមួយពេទ្យយោធានេះឯង។

[១៥:៤៩:៥៧]

អ៊ីចឹង ទិដ្ឋភាពដែលនិយាយថាបើ "ទុកមិនចំណេញ យកចេញមិនខាត" ពាក្យនេះ មិនមែនថាប្រើបានតែនៅក្នុងភូមិជាខ្លាង ឬឃុំជាខ្លាង ទេ មានន័យថា ជាទូទៅ ក្នុងក្រោយពីពេល៧៥មក តែងតែ

ឮសំឡេងសម្ដីនេះ ជារឿងស្មើរតែគ្រប់ទីកន្លែង។ អ៊ីចឹងសួរថា ការអនុវត្តមានអនុវត្តដែរឬទេ? ចំណុចនេះខ្ញុំ បើសិនជាខ្ញុំនិយាយទាំងអស់ទៅ ហាក់ដូចខ្ញុំបំប៉ោងពាក្យ ប៉ុន្តែបើខ្ញុំជាអ្នកបំបាត់រឿង ហាក់ដូចជាអ្នកបំបាត់រឿង។ ប៉ុន្តែមិនត្រឹមតែៗ បង្កើនសកម្មភាពទេ លោកមេធាវី ការពិត ខ្ញុំគាំទ្ររហូតដល់គាំទ្រមិនបាន។ ខ្ញុំបានជម្រាបក្នុងឯកសាររបស់ខ្ញុំហើយថា រហូតដល់ខ្ញុំដឹកដៃប្រពន្ធរត់ចេញពីមន្ទីរពេទ្យចោលស្រុកនេះឯង។

[១៥:៥០:៥៥]

**ស៖** នៅពេលដែលគេ -- នៅក្នុងវគ្គអប់រំនយោបាយ នៅបុរីកីឡារនេះដែរ តើលោកអាចបញ្ជាក់បានទេថាតើលោក ខៀវ សំផន មានបាននិយាយអំពីការ -- មានបាននិយាយរំឭក ឬក៏វាយតម្លៃអំពីវាគ្មិនមុនៗ ដែលគេបាននិយាយមុនគាត់ដែរឬទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំបាននិយាយរួចម្ដងហើយថា មុននឹងបុគ្គលប្ដូរគ្នា ប្ដូរក្នុងការមានយោបល់ មុននឹងបន្តយោបល់ដែលគាត់លើកឡើងគោលដៅរបស់គាត់ ភាគច្រើនច្រើនតែនិយាយប្រធានបទខាងដើមបានមួយគ្រួស ចប់ហើយបានបន្ត គឺលោក ខៀវ សំផន ក៏បានប្រើបាទ។

**ស៖** ខ្ញុំសូមចូលទៅវគ្គថ្មីដែលលោកបានមានប្រសាសន៍ថា នៅចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨ លោកបានត្រឡប់ទៅតំបន់២០ វិញ ហើយធ្វើការនៅទីនោះ។ ថាតើលោកទៅធ្វើការនៅក្នុងទីនោះជាពេទ្យធម្មតា ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលដែលខ្ញុំត្រឡប់ពីភ្នំពេញរហូតដល់មូលដ្ឋានរបស់ខ្ញុំវិញ គឺខ្ញុំទទួលធ្វើពេទ្យ ព្យាបាលជំងឺជាធម្មតា ជាក្របខ័ណ្ឌដែលខ្ញុំធ្លាប់ធ្វើកន្លងមកអី គឺធ្វើហ្នឹង។ ប៉ុន្តែខ្ញុំត្រូវទទួលតំណែងមួយទៀត ក្នុងឱកាសនោះគឺខ្ញុំទទួលតំណែងជាអ្នកបណ្ដុះបណ្ដាលវិជ្ជាជីវៈពេទ្យនេះនៅក្នុងតំបន់២០ គឺខ្ញុំទទួលបន្ទុកទទួលបច្ចេកទេសសាលានយោបាយ សាលាពេទ្យតំបន់២០។ ក្នុងហ្នឹងដែរ គឺខ្ញុំទទួលបន្ទុកផងដែរ គឺខ្ញុំបានដើរត្រួតពិនិត្យតាមជំងឺដែលកើតឡើង គេហៅថា តាមពេលវេលា ឧបមាកើតពេលកញ្ជ្រឹលច្រើន ចុះរាកច្រើន ខ្ញុំមានសកម្មភាពដើរតាមមន្ទីរពេទ្យគ្រប់ស្រុក និងគ្រប់ភូមិដើរដែរ បើមានពេលដើរគ្រប់ភូមិ ស្រុក និងឃុំបាទ។

[១៥:៥៣:១៦]

**ស៖** បាទ លោកបាននិយាយថា នៅក្នុងព័ត៌មានដែលលោកឱ្យនៅក្នុងឯកសាររបស់លោកបានសរសេរខ្លួនឯងនោះ គឺនៅទំព័របន្ទាប់នៃទំព័រដែលខ្ញុំបានលើកពីមុននោះ គឺក្នុងឯកសារដដែល លោកបាន

និយាយថា "ខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការ"។ ថាតើលោកអាចនិយាយអំពីបញ្ហាហ្នឹងបានដែរឬទេ? តើវាកើតឡើងយ៉ាងដូចម្ដេច?

**ឆ៖** ត្រង់នេះ ខ្ញុំសូមអភ័យទោសទុកជាមុនដល់លោកមេធាវី ក៏ដូចជាតុលាការ បើសិនខ្ញុំនិយាយមានពេលវេលាវែង សូមមេត្តាប្រាប់ថាវែង ប៉ុន្តែការនិយាយអំពីរឿងពិស្ដាររបស់ជីវិតខ្ញុំផ្ទាល់តែម្ដង។ ក្នុងនាមខ្ញុំជាយុវជនម្នាក់ស្ថិតនៅក្នុងសង្គម អ្នកណាក៏ដូចអ្នកណា ស្រលាញ់ណាស់ អំពីមានសិទ្ធិសេរីភាពក្នុងការរើសគូស្រករ។ ប៉ុន្តែនៅក្នុងឱកាសដែលខ្ញុំមិនៗចង់បាន បែរទៅជាបាន អាហ្នឹងខ្ញុំមិនពេញចិត្តទេ តែគេចមិនបាន។ ដូច្នេះតម្រូវពេលវេលានោះឯង មើលលក្ខណៈហាក់ មិនហាក់ទេ គឺរឿងពិត គឺបិទសិទ្ធិមនុស្សប្រើប្រាស់មិនបានទេ ព្រោះគេតម្រូវឲ្យខ្ញុំយកប្រពន្ធៗ ហើយចង្អុលចំដែលមនុស្សដែលខ្ញុំអត់ស្រលាញ់។ អ៊ីចឹង ខ្ញុំប្រកែកចុះ ប្រកែកឡើង ក្នុងឋានៈខ្ញុំជាសមាជិកបក្សក្នុងក្រសួងរបស់ពេទ្យផងដែរ គឺខ្ញុំត្រូវទទួលបន្ទុកមួយ បានន័យថា ដូចជាទទួលទោស។ គេដកចេញពីពេទ្យ ឲ្យខ្ញុំទៅការដ្ឋាន រយៈពេលប្រហែលជាពីរទៅបី, ពីរខែជាង បើជាង វាជាងតិចតួច បើខ្វះក៏ខ្វះតិចតួច។

[១៥:៥៥:១២]

ខំធ្វើតាមលក្ខណៈបញ្ចេញពលកម្ម បានន័យថា អ្នកទទួលទណ្ឌកម្ម គឺស្រេចអំពើចិត្តគេធ្វើ។ គេបញ្ជូនខ្ញុំទៅការដ្ឋាន រយៈពេលប៉ុណ្ណឹងខែ បាន -- ក្នុងឱកាសនោះដោយសារមិនមែនថៃដន្យអស់កម្មនោះទេ មើលទៅប្រហែលជាតម្រូវការខានមិនបាន ព្រោះខ្ញុំជាពេទ្យវះកាត់ផង ជំងឺក៏ឆ្កួត ឈឺអ្វីពូកែគួរសមដែរ។ ម្ល៉ោះហើយជំងឺយ៉ាងច្រើននៅក្នុងពេញមន្ទីរពេទ្យនោះ។ ដល់អ៊ីចឹងរបួសក៏ច្រើន ជំងឺក៏ច្រើន វាត្រូវការខ្វះពេទ្យ អ៊ីចឹងតម្រូវឲ្យ -- មុននឹងហៅឲ្យខ្ញុំមក គេសួរបញ្ជាក់មួយថា "មិត្តឯងព្រមទទួលពាក្យចាស់របស់មិត្តឯងដែរឬអត់?" ខ្ញុំពិចារណាចុះឡើង ពិចារណាវែង សូមនិយាយមិនបរិយាយវែងទេ ហៅថាពិចារណាវែងបន្តិច អស់រយៈពេលពីរ ប្រហែលជាពីរៗខែ អ៎! ២ថ្ងៃ ឬ២អាទិត្យ។ ចុះឡើងៗ ខ្ញុំសម្រេចចិត្តថា បើខ្ញុំមិនយកជីវិតខ្ញុំអត់ដឹងថា ខ្ញុំរស់ឬស្លាប់។ អ៊ីចឹងដាច់ចិត្តបង្ខំៗចិត្តទទួលពាក្យបង្ខំនេះ ថាត្រូវព្រមទទួល។ ប៉ុន្តែការទទួលនេះ ខ្ញុំសូមនិយាយដល់អស់ប្អូនៗ ក្មួយៗឲ្យដឹងឮថា គួរថាធ្វើយ៉ាងម៉េច? ទាំងៗនារីជាភរិយារបស់ខ្ញុំ ទាំងខ្ញុំដេក ពេលចូលដំណេកដេកជាមួយគ្នា បង្ហូរទឹកភ្នែកដាក់គ្នា តើសមរម្យនឹងយកដែរឬអត់? ខ្ញុំសួររឿងពិត សមខ្ញុំយកដែរឬអត់? ហើយយើងសមនឹងរស់បានដែរឬក៏អត់? ថ្ងៃនោះគឺខ្ញុំ--

[១៥:៥៦:៣៦]

*(សម្រាករយៈពេលខ្លី)*

[១៥:៥៧:៣១]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំនឹងដោយសារគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបន្តទៀតខ្ញុំនឹងសួរគាត់អំពីបញ្ហាព្យសនកម្ម ហើយប្រហែលពីពេលនេះទៅត្រូវចំណាយពេល១០នាទី អ៊ីចឹងប្រហែលជាលើសម៉ោងបួនប្រាំនាទី។ សូមលោកប្រធានអនុញ្ញាត។

**លោក អែម អឿន៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ ដូចអត់និយាយអត់មានក្បាលមីក្រូផង។ អត់ៗ ក្បាលមីក្រូអត់ប្រតិបត្តិការផងនិយាយអត់ប្រយោជន៍ទេ។ លោកអាចបន្តផ្ដល់ចម្លើយបានទេ?

[១៥:៥៨:៣៦]

**លោក អែម អឿន៖**

**ឆ៖** សូមទោសត្រង់ហ្នឹង ខ្ញុំអាចផ្ដល់បាន ប៉ុន្តែផ្ដល់បានតែតាមដំណើរដែលខ្ញុំធ្វើបាន ដូចខ្ញុំបានសូមទោសទុកជាមុនរួចហើយ។ អ៊ីចឹងក្នុងចំណុចនេះ ពេលដែលខ្ញុំស្រក់ទឹកភ្នែក ដោយសារទាំងប៉ុន្មានដោយសារនឹកឃើញរឿងអតីតកាល ថាខ្ញុំចុះជាបុរស ប៉ុន្តែគ្នាជាស្រីក៏ជួបរឿងដូចខ្ញុំដែរ រហូតដល់គ្នាបង្ខំចិត្តមនុស្សមិនស្រឡាញ់។ ប៉ុន្តែក្នុងឱកាសនោះ ខ្ញុំគិតឃើញ ប៉ុន្តែសួរគ្នា ដេកសួរគ្នា តើយើងធ្វើម៉េច? បើយើងដកដៃយើងនឹងងាប់ តើយើងធ្វើម៉េច? ហើយការនិយាយនេះ មិនបាននិយាយឲ្យគេឮទៀត។ មើល៍តើពិចារណា ហ្នឹងមានតែយើងពីរនាក់បង្ខំចិត្ត ទាំងងាប់ ទាំងរស់ដើម្បីបំពេញបំណងៗអ្នកត្រូវការដើម្បីជីវិតរបស់យើង យើងគួរធ្វើអ៊ីចឹងដែរឬអត់?

[១៥:៥៩:២៤]

មុននឹងការរួមដំណេកជាមួយប្រពន្ធខ្ញុំនេះ ខ្ញុំត្រូវប្រើអស់ជាងកន្លះខែ ទំរាំការរួមដំណេកសម្រេចចិត្តថាត្រូវតែយក។ ទាំងគាត់ក៏អ៊ីចឹង ទាំងខ្ញុំក៏អ៊ីចឹង អ៊ីចឹងមានរឿងៗកំសត់វេទនាលំបាកវេទនានេះរហូតដល់ថ្ងៃនេះ ខ្ញុំនៅតែមិនទាន់រកឃើញអំពើទាំងហ្នឹងថាមកពីណា? ហើយខ្ញុំឃើញអំពើទាំងអស់នេះខ្ញុំមិនមែនមានន័យថា ខ្ញុំចង់សងសឹក ខ្ញុំចង់ចងកម្មពារជាមួយ អត់ទេ តែខ្ញុំគ្រាន់មានគំនិតមួយថា បុគ្គល

E1/113.1

ដែលនាំធ្វើអ៊ីចឹងគួរនាំដល់ណាទៀត? ហើយគួរប្រាប់គេប្រាប់ឯងថា អំពើនេះយើងមិនបានចង់ទេ តែបើការបង្ខំដោយថាគេ គាបសង្កត់មកពីណាៗ គួរតែយើងអ្នកដឹកនាំធ្វើអ៊ីចឹង សូមទោស មិនបានប្រដៅទេ។ តែខ្ញុំនឹកឃើញថ្ងៃនេះ បើសិនជាជួបអ៊ីចឹងទៀត តើបុគ្គលដែលអ្នកជួបរបបប្រភេទនេះ តើអ្នករងគ្រោះប៉ុន្មានទៀត? ហ្នឹងសូមទោសបាទ។

**ស៖** បាទ សូមយឺតៗបន្តិច លោកពូណា៎ះ! តើនៅពេលដែលរៀបការហើយមានការតាមដានទៅលើគូទាំងពីរនាក់ហ្នឹងដែរឬទេ ថាតើមានការរស់នៅជាមួយយ៉ាងម៉េច អីក៏យ៉ាងម៉េចៗ មានការតាមដានដែរឬទេ?

**ឆ៖** ដល់ចំណុចត្រង់នេះ លោកមេធាវី ខ្ញុំសូមជម្រាបហេតុផលត្រង់ហ្នឹងដែរហើយដែលខ្ញុំទៅពិចារណាជាមួយមនុស្សដែលត្រូវជាប្រពន្ធខ្ញុំថា តើយើងដោះស្រាយយ៉ាងណា? ស្រឡាញ់អត់ស្រឡាញ់មកដេកនៅ បើយើងមិនស្រឡាញ់គេតាមដានទាំងថ្ងៃ ទាំងយប់ រកតែនិយាយគ្នាអត់រួចទេ។ អ៊ីចឹងដោយសារគាំទ្រអំពើការគាបសង្កត់នេះមិនបាន ខ្លាចងាប់ផង ក៏ខ្ញុំសម្រេចចិត្តពីរនាក់ធ្មេចភ្នែកយក និយាយត្រង់ សូមទោស។ ដល់ពេលប៉ះពាល់ហើយ មនោសញ្ចេតនានឹងកើត តែងមានការអាណិតអាសូរគ្នាទៅវិញទៅមក គឺយកបានកូនបានចៅដោយសារការមានចិត្តអាណិតអាសូរ។ តែការចិត្តដែលស្រឡាញ់គឺនៅតែមិនទាន់ស្រឡាញ់រហូត។ សូមនិយាយត្រង់ៗលោកមេធាវី។

[១៦:០១:៤៣]

**ស៖** តើលោកមានរួមរស់នៅជាមួយគ្នាជាបន្តទៀតដែរឬទេ បន្ទាប់ពីដាច់របបខ្មែរក្រហមនេះហើយនេះ?

**ឆ៖** ក្រោយពេលដាច់របបខ្មែរក្រហមហើយ ចន្លោះពេលនោះ គឺខ្ញុំស្ថិតនៅរឿងមួយទៀត ប៉ុន្តែខ្ញុំបានរក្សាគាត់ ដោយសារមានការភាពអាណិតអាសូរគាត់ រួមរស់ជាមួយគ្នារហូតបានកូនពីរនាក់។ បាទ ដោយសារអី តបស្នងនៃការខូចខាតរបស់គាត់វិញ គឺខ្ញុំត្រូវតែទទួលខុសត្រូវលើគាត់ ដោយសារខ្ញុំភាពអាណិតអាសូរដល់គាត់ ហ្នឹងនិយាយរឿងពិតរបស់ខ្ញុំ។ តែថាឲ្យស្រឡាញ់អត់ទេ នៅនឹកឃើញដដែល។ នៅនឹកឃើញតែរឿងអំពើមិនស្រឡាញ់នៅដដែល។ សូមទោស ប្រាប់និយាយរឿងត្រង់។

ដល់ក្រោយមក ខ្ញុំហាក់ដូចជាធ្វើមិនពេញចិត្តគំនិតខ្លួនឯងផង ធ្វើៗចុះឡើងៗរហូតដល់គាត់អន់ចិត្ត។ អន់ចិត្តសុំលែង ហ្នឹងសិទ្ធិមានហើយ នៅពេលក្រោយ៧៩។ ក្រោយមកឥឡូវនេះ គាត់សុំលែងដល់សុំលែង ខ្ញុំសូមធ្វើការមួយសូមទោសទុកជាមុនថា លែង ប៉ុន្តែសុំទុកជាមិត្ត ជាភក្តិ ជាបង ជាប្អូន

នាងត្រូវការពេលណា ត្រូវការខ្ញុំជួយបំពេញរឿងអីមួយសូមប្រាប់ចុះ។ នេះដោយសារខ្ញុំមានមនោសញ្ចេតនា។ រហូតដល់ឥឡូវខ្ញុំកសាងគ្រួសារមួយថ្មីហើយ។

[១៦:០៣:១២]

**ស៖** សូមបញ្ជាក់ថែមបន្តិច លោកបាននិយាយថា លោកបានរៀបការនៅថ្ងៃទី១៧ មេសា ឆ្នាំ ១៩៧៧ នៅក្នុងទំព័របន្ទាប់ថែមទៀតនៃឯកសារដដែលនេះ។ តើលោកអាចបញ្ជាក់បានទេ លោកថា ឆ្នាំ១៩៧៧ លោកនៅរៀននៅភ្នំពេញ ក៏ប៉ុន្តែនៅក្នុងឯកសាររបស់លោកដែលបានសរសេរដោយអក្សរផ្ទាល់របស់លោកគឺ ១៧ មេសា ឆ្នាំ៧៧ ដែលរៀបការហ្នឹងខាង នៅតំបន់២០ ទេ តើលោកអាចបញ្ជាក់អំពីថ្ងៃខែឆ្នាំរៀបការហ្នឹងសាជាថ្មីបានទេ?

**ឆ៖** ត្រង់ហ្នឹងហើយដែលខ្ញុំបានសុំអភ័យទោសជាមួយតុលាការ ក៏ដូចជាមេធាវីថា បើសិនជាខ្ញុំនិយាយលើក្រោម តិចច្រើនៗអាចនឹងខុស។ ក្នុងនេះខ្ញុំយល់បានច្បាស់ថា កំណត់យកថា ថ្ងៃ១៧ មេសា ដោយខ្ញុំនឹកឃើញថា នៅពេលនោះអ្នកដែលមានកម្មវិធីគាំទ្រ ស្រឡាញ់រាប់អានខ្ញុំជាបង ជាប្អូនខ្ញុំនោះ អ្នកមុខអ្នកការក្នុងតំបន់ទាំងអស់ទៅធ្វើពិធីការខ្ញុំ។ ដោយអ្នកទាំងអស់នុំងហាក់ដូចជាយល់គំនិតមួយថា បើសិនមិនអប់ -- បើមិនយកគំនិតហ្នឹងទៅការវាទេ ប្រហែលអាហ្នឹងវាមានទឹកចិត្តផ្សេង ព្រោះអស់លោកដឹង។ ដឹងថា ខ្ញុំនឹងមិនចូលចិត្តស្តាប់អ្នកណាទាំងអស់។ អ៊ីចឹងឯងហើយថា កំណត់យកថា ថ្ងៃ ១៧មេសា ឬក៏ថ្ងៃអីនោះ ខ្ញុំសូមទោសបើសិនជាមានខុស។ ប៉ុន្តែព្រឹត្តិការណ៍ហ្នឹងពិតជាអ៊ីចឹង ប៉ុន្តែខ្ញុំមិនទាន់ដឹងថា ពេលនោះ ១៧មេសា ៧៨ ឬ ១៧មេសា ៧៧។ អ៊ីចឹងសូមលោកមេធាវីជួយ សរ៉េពេលវេលាហ្នឹងតាមដំណើរដែលពិតចុះបាទ។ ព្រោះថាខ្ញុំពិតជាមានរឿងអ៊ីចឹងមែន តែខ្ញុំមិនមានច្បាស់ថា ១៧មេសា? ១៧ ខែ៧? ឬ១៧ ខែ៨? អាហ្នឹងសូមបញ្ជាក់លោកមេធាវី សូមជួយកែលម្អ។ ព្រោះថារឿងហ្នឹងពិតជាមានអ៊ីចឹងមែន។

**ស៖** ១៧ មេសា ឆ្នាំ១៩៧៨។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៦:០៥:៣៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមចាប់អារម្មណ៍ផងដែរថា កាលពីយើងកំណត់នូវអង្គហេតុ ធ្វើសវនាការពិភាក្សាដេញដោលនៅវគ្គដំបូង សំណុំរឿង០០២/០១ នេះ គឺអំពើអមនុស្សធម៌ផ្សេងៗទៀតហ្នឹង អង្គ

ជំនុំជម្រះបានដកចេញ បានន័យថាមិនរាប់បញ្ចូលនូវការរៀបការដោយបង្ខំទេ។ កម្រិតត្រឹមតែការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ប៉ុណ្ណោះ។ អ៊ីចឹងការរៀបចំនូវសំណួរ សុំចៀសវាងនូវការតាំងសំណួរក្រៅអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់បំបែកមកធ្វើសវនាការនៅដំណាក់កាលដំបូង សំណុំរឿង០០២/០១។

[១៦:០៦:២៥]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ដើម្បី ដោយសារមានព័ត៌មានខុសគ្នាបន្តិច ដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

ការបញ្ជាក់របស់លោក គប្បីឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើសវនាការ មិនមែនបញ្ជាក់លើបញ្ហាក្រៅអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការទេ។ បានន័យថា ការបញ្ជាក់ហ្នឹងក្រៅអង្គហេតុទេ។ វាមិនពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ។

[១៦:០៦:៥៦]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** មានសំណួរបន្តិចបន្តួចចុងក្រោយ។ តើលោកអាចនិយាយបានទេ ថាលោកមានធ្លាប់រងគ្រោះដោយសារការជម្លៀស ឬក៏សាច់ញាតិរបស់លោកមានធ្លាប់ត្រូវបានជម្លៀសដែរឬទេ? ហើយតើការជម្លៀសហ្នឹង តើលោកមានបញ្ហាការខូចខាត ឬការឈឺចាប់ដោយសារការជម្លៀសរបស់លោក ឬក៏សាច់ញាតិរបស់លោកដែរឬទេ? ហើយតើមានការបាត់បង់សាច់ញាតិរបស់លោកដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** ក្នុងគ្រួសាររបស់ខ្ញុំ ឈ្មោះថាជម្លៀសមិនមានទេ។ ប៉ុន្តែការបាត់បង់ ពិតជាមាន។ ប៉ុន្តែភាពបាត់បង់នេះ ខ្ញុំមិនដឹងនិយាយយ៉ាងណាអស់។ បើនិយាយតិចវាមិនអស់ បើនិយាយវែង វាវែង។ អ៊ីចឹងបានន័យថា បើបូកបោះនៃការបាត់បង់ សាច់ឈាមផ្ទាល់តែម្តងដែលមិនគិតខាងប្រពន្ធផង គឺអស់បើខ្ញុំបូកបោះសរសេរទៅ រាប់ទៅឃើញអស់ជាង២០នាក់រួចទៅហើយ គ្រាន់តែសាច់សាលោកហិតថ្នាក់ត្រឹមជីដូនមួយអស់ជាង២០នាក់។ មិនទាន់រាប់ដល់ខាងប្រពន្ធដែរទេ សាច់ឈាមប្រពន្ធនៅ។ ប៉ុន្តែ

បើនិយាយរៀបរាប់របស់ខ្ញុំទៅ ជាង២០ ស្មើនឹងជិត៣០ តិចតួចបាទ។ មានសាច់ឈាមបាត់បង់ជីវិតក្នុងឱកាស អំឡុងឆ្នាំមុន៧៥ និងក្រោយ៧៥ ទើបច្រើនបាទ។ មុន៧៥ក៏មាន ក្រោយ៧៥កាន់តែច្រើន។

[១៦:០៨:៤៧]

**ស៖** បាទ សំណួរចុងក្រោយថាតើការបាត់បង់នេះ ធ្វើឲ្យលោកឈឺចាប់ដែរទេ? នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ហើយសូមអរគុណចំពោះការឆ្លើយរបស់លោក។

**ឆ៖** ត្រង់នេះ ខ្ញុំសូមឱកាសនិយាយបានវែងខ្លះ ព្រោះថាចំណុចនេះមួយដែលខ្ញុំចង់បាន។ អ៊ីចឹងខ្ញុំសូមអភ័យទោសលោកមេធាវី តើអាចនិយាយបានដែរឬអត់?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី អ៊ំ!លោកដើមបណ្តឹងរដ្ឋប្បវេណី គឺលោកនឹងមានឱកាសនិយាយចុងក្រោយលើបញ្ហានេះ។ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យលោកនៅពេលដែលការតាំងសំណួរដេញដោលចំពោះលោកចប់សព្វគ្រប់ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅលោក និងសម្តែងអំពីស្ថានភាពព្យសនកម្ម និងទុក្ខវេទនារបស់លោក។

[១៦:០៩:៤៨]

**លោក ពេជ អង្គ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណចំពោះការផ្តល់ឱកាសដើម្បីសួរលើដើមបណ្តឹងរដ្ឋប្បវេណីនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។

ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ លោក អែម អឿន ដើមបណ្តឹងរដ្ឋប្បវេណី កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅព្រឹកថ្ងៃចន្ទ ទី២៧ ខែសីហា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយនេះនឹងបន្តស្តាប់សក្ខីកម្មរបស់លោក អែម អឿន ដែលនឹងបន្តដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅរសៀលថ្ងៃ ថ្ងៃចន្ទ ទី២៧ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះមិនធ្វើសវនាការលើសំណុំរឿងក្តីទេ ដោយអង្គជំនុំជម្រះត្រូវបន្តធ្វើនូវកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើ

កាលពីថ្ងៃ១៧ ខែសីហា ឆ្នាំ២០១២ កន្លងមកមិនទាន់ចប់នៅឡើយ។ កិច្ចប្រជុំរៀបចំសវនាការនឹងប្រព្រឹត្តទៅជាអសាធារណៈ។ សូមភាគី និងសាធារណជនជ្រាប។

[១៦:១០:០៦]

លោក អែម អឿន ការផ្តល់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយទៀត។ ដូច្នេះអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយ។

មន្ត្រីរដ្ឋបាលតុលាការសម្រាបសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនដើមដណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែង ដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ឲ្យត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១១ នាទី)*